៦

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៨ ខែ មិថុនា

ព.ស. ២៥០៨ គ.ស. ១៩៦៦

# កម្ពុជសុរិយា

## ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
## ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

### បញ្ជីរឿង


*ផ្នែកសាសនា* — ទំព័រ

១— ជីវិតធម្មកថា ព្រះមុនីកោសល សួរ-ហាយ រៀបរៀង (ត) . . . . ៥៦៥
២— ការពិសេសនៃអភិណ្ហប្បច្ចវេក្ខណធម៌ លោក ផល-ទិត រៀបរៀង . . . ៥៨១

*ផ្នែកអក្សរសាស្ត្រ*

៣— ជីវប្រវត្តិ សម្តេចព្រះពោធិវង្ស ហ.តាត លោក ដា-ទន់ រៀបរៀង . . . ៦០៨
៤— វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង—ខាត់ រៀបរៀង (ត) . . ៦៣១
៥— ឥទ្ធិពលនៃកង់ លោក ធុង-សារឿន រៀបរៀង . . . . . ៦៣៥
៦— ព្រះរាជនិពន្ធភាមកេរ្តិ៍ លោក ឌ. តាម ស្រាវជ្រាវ (ត) . . . . ៦៤៥
៧— កាព្យនិទានរំលឹកដល់ព្រហ្មមុខ ៤ នៅអង្គរ លោក ទៀក-អំ រៀបរៀង . . ៦៥១
៨— ឯកសារ សាស្ត្រាស្ទឹករាំងនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ៦៥៤
៩— រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ–កន ប្រែរៀបរៀង(ត) . . . ៦៥៨
១០— លុយនៅប្រទេសខ្មែរ លោក ឌ.តាម ស្រាវជ្រាវ . . . . . ៦៦៦

## ផ្នែកកំណត់ទិនប្បវត្តិការណ៍


១១— បុគ្គលិកឃ្ញាយថ្វាយព្រះរាជកុសល ចំពោះសម្ដេចព្រះមហាក្សត្រិយានី . . . ៦៣០

១២— បុគ្គលិកឃ្ញាយ ឯ.ឧ. អគ្គនាយកក្រសួងព្រះបរមរាជវាំង . . . . . ៦៣៤

១៣— សេចក្ដីជូនដំណឹងអំពីលទ្ធផលប្រឡងទំនៀមទម្លាប់ឆមាសទី ១ ឆ្នាំ ១៩៦៦ . . ៦៣៦

១៤— ប្រកាសប្រឡងទំនៀមទម្លាប់ ឆមាសទី ២ ឆ្នាំ ១៩៦៦ . . . . . ៦៨០


---

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ។

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការណាមក, ឲ្យធ្វើល្អទៅ,
ឲ្យផុសភាគចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

## ជីវិតធម្មកថា

ព្រះមុនីកោសល សួរ-ហាយ រៀបរៀង

( តមកពីលេខ ៥ )

បើឥរិយាបថទាំង ៤ នោះ នៅប្រើបានមិនស្មើគ្នាទេ គឺអង្គុយច្រើន ឬដេកច្រើន ឈរច្រើន ដើរច្រើន ជ្រុលដោយឥរិយាបថណាមួយហើយ ក៏ជាហេតុនាំឲ្យអាយុនោះតិចចុះ ជីវិតនេះ ជាប់ដោយការក្តៅនិងត្រជាក់ផង កាលបើក្តៅនិងត្រជាក់ តាំងនៅស្មើគ្នាល្អ ជីវិតក៏រស់នៅប្រព្រឹត្តទៅបានស្រួល, បើក្តៅ ឬត្រជាក់ ហួសហេតុពេក អាយុ ទឹងដាច់សូន្យទៅ, ជីវិតនេះ ជាប់ដោយមហាភូតរូប ៤ គឺធាតុទាំង ៤, កាលបើធាតុទាំង ៤ នោះ ប្រព្រឹត្តទៅស្មើគ្នាល្អ ជីវិតក៏ចម្រើននៅបាន, បើធាតុទាំង ៤ ប្រការ ធាតុណាមួយប្រព្រឹត្តពុំបានស្មើគ្នាទេ អាយុនឹងដាច់សូន្យទៅ ទុកជាបុគ្គលណាបរិបូណ៌ដោយកម្លាំងច្រើនប៉ុណ្ណា បើមានធាតុណាមួយ ខ្សោយជាងហើយ ក៏មានកាយគ្រាំគ្រា ដោយ

ពេលផ្សេង ៗ មានអតិសាររោគ គឺរោគចុះឈាមជាដើម មានកាយនោះ ឈឺចុកចាប់សៅហ្មង ក្តៅក្រហាយសព្វសព៌ាង្គកាយ បណ្តាលឲ្យក្ស័យជីវិតទៅក៏មាន, ជីវិតនេះ ជាប់ដោយសារអាហារ បើបានអាហារបរិភោគចូលទៅ ជីវិតក៏ប្រព្រឹត្តទៅបាន បើមិនមានអាហារបរិភោគ ឬក៏ល្មោភបរិភោគឲ្យច្រើនកើនលើសប្រមាណពេក ភ្លើងធាតុក៏ពុំអាចកំដៅ ឲ្យទ្រុឌទ្រោមទៅបាន អាយុក៏ត្រូវដាច់សូន្យទៅ ៗ អាស្រ័យហេតុនេះ ទើបព្រះពុទ្ធសំដែងថា " ជីវិតិន្ទ្រិយ របស់សត្វទាំងឡាយ ជាប់ដោយអស្សាសប្បស្សាសៈផង ជាប់ដោយកំដៅ និងត្រជាក់ផង ជាប់ដោយមហាភូតរូបផង ជាប់ដោយអាហារផង" ៗ

ម្យ៉ាងទៀត តាមការពិនិត្យ ជីវិតនៃមនុស្សទាំងឡាយ ក្នុងកាលសម័យសព្វថ្ងៃនេះ រស់នៅដល់ ១០០ ឆ្នាំ ឬជាង ១០០ ឆ្នាំនោះ ក៏ឃើញជាមានតិចណាស់ សឹងតែពុំមានផង តែបើមនុស្សដែលមានអាយុតិចថយចុះពី ១០០ ឆ្នាំមកវិញ ឃើញមានច្រើន ដូចមានបាលីក្នុងវិសុទ្ធិមគ្គថា យោ ភិក្ខវេ ចិរំ ជីវតិ សោ វស្សសតំ អប្បំ ភិយ្យោ ម្នាលភិក្ខុទាំងឡាយ មនុស្សណារស់នៅយូរឆ្នាំ មនុស្សនោះរស់នៅយ៉ាងយូរអស់ ១០០ ឆ្នាំ លើសពីនេះមានតិចទេ ៗ កាលបើយើងដឹងច្បាស់ថា អាយុនៃមនុស្ស មានប្រមាណតិចយ៉ាងនេះហើយ គប្បីយើងពិនិត្យ

មើលអាយុរបស់ខ្លួន កុំស្រវឹងដោយអាយុ កុំចូលចិត្តយល់ថា អាយុនេះ ឋិតនៅយឺនយូរឡើយ ។ ត្រូវឧស្សាហ៍ព្យាយាម បំពេញសុចរិតធម៌ ខ្វល់ខ្វាយក្នុងគុណធម៌ ដែលនឹងឲ្យសម្រេចដល់ព្រះនិព្វាន ជាទីរម្ងាប់នូវទុក្ខ សោក រោគ ភ័យ គ្រប់ជំពូក ត្រូវធ្វើអាការៈដូចបុគ្គលដែលមានក្បាលតីភ្លើងកំពុងឆេះ ហើយខំខ្វល់ខ្វាយរកឧបាយ ដើម្បីនឹងរំលត់ភ្លើងដែលឆេះនៅលើសិរ្សៈនៃខ្លួន គប្បីឧស្សាហ៍គិតក្នុងធម្មសង្វេគ ចំពោះសេចក្តីស្លាប់ ព្រោះថាយើងកើតមកជាសត្វជាបុគ្គលហើយ មច្ចុរាជតែងបៀតបៀន មិនមានខានម្នាក់ឡើយ ដូចព្រះពុទ្ធម្ចាស់ កាលកើតជាគ្រូម្នាក់ឈ្មោះអរកៈ បានសំដែងធម៌ប្រោសព្រាហ្មណ៍ម្នាក់ឈ្មោះ អលង្គតៈថា ជីវិតនៃសត្វទាំងឡាយនេះ មិនបានតាំងនៅយូរឡើយ ប្រៀបដូចដំណក់នៃទឹកសន្សើម ដែលជាប់នៅដោយចុងស្មៅ ហើយឆាប់នឹងស្ងួតហួតបាត់ទៅ ដោយកំដៅនៃព្រះអាទិត្យ ឬ ដូចពពុះទឹកដែលប៉ោងឡើង ដោយអំណាចកម្លាំងនៃខ្សែទឹកជួបគ្នា ហើយឆាប់បែករលាយទៅវិញ ឬថា ជីវិតនៃសត្វទាំងពួងនេះ ឆាប់រលត់រលាយទៅ ដូចស្នាមគំនូសដែលគេគូសទឹក ហើយឆាប់រលាយទៅ ឬ ជីវិតនេះ ប្រៀបដូចខ្សែទឹក ដែលហូរចុះបាក់កំពូលភ្នំ តែងបន្សាត់យកនូវវត្ថុទាំងពួងយ៉ាងឆាប់រហ័ស ឬ ដូចទឹកមាត់ ដែលបុគ្គលស្តោះចេញទៅ នឹង

ឆាប់ហួតបាត់ ពុំនោះសោត ដូចដុំសាច់ ដែលបុគ្គលដាក់ចុះក្នុងខ្ទះដែក ដែលក្តៅឆេះ ឆាប់ធ្វើឲ្យអស់ទៅយ៉ាងណា, ជីវិតនៃសត្វទាំងពួង ក៏ យ៉ាងនោះដែរ ។

ព្រោះហេតុនេះ ជនទាំងឡាយ កាលបើដឹងថា ជីវិតតិចយ៉ាង នេះហើយ គប្បីធ្វើការកុសលឲ្យបានច្រើន តាមទ្រឹស្តីព្រះពុទ្ធម្ចាស់ដែល មានសព្វថ្ងៃនេះចុះ ពីព្រោះសត្វកល់រូប ដែលកើតមកមានការចាស់ ឈឺ ស្លាប់ នៅជាមួយគ្នាស្រេចមកស្រាប់ហើយ ពុំមែនថា ការ ចាស់ ឈឺ ស្លាប់ នៅឆ្ងាយដាច់ដោយឡែក អំពីការកើតនោះទេ ។ ធម្មជាតិទាំង ៤ យ៉ាង គឺ ជាតិ ជរា ព្យាធិ និងមរណៈនេះ តែង មាននៅប្រចាំគ្រប់រូបមនុស្សសត្វ សម្រាប់ធ្វើជីវិតឲ្យតិចចុះ ឲ្យឆាប់ ស្លាប់ទៅវិញ ព្រោះហេតុនោះ បានជាព្រះពុទ្ធ ទ្រង់សំដែងថា "បរិត្តញ្ច ជីវិតតិចណាស់" ។

អត្ថបទទី ៥ ថា តញ្ច ទុក្ខេន សំយុត្តំ ជីវិតនោះ គឺ សេចក្តីទុក្ខ តែងគ្របសង្កត់ត្រូវគ្រប់រូប សេចក្តីថា ជីវិតនៃមនុស្សសត្វ ត្រូវសេចក្តីទុក្ខជាច្រើនយ៉ាង ហោមពេមព័ទ្ធជុំវិញ រុករានលុកចូលជ្រៀត ជ្រែក រៀងរាល់ពេលឥតស្រាកស្រាន្តឡើយ ។ ឯសេចក្តីទុក្ខដែលហោម ពេមព័ទ្ធជុំវិញជីវិតនោះ គឺសេចក្តីទុក្ខព្រោះត្រជាក់ពេក ព្រោះក្តៅស្អុះ

ពេក ព្រោះស្រេក ព្រោះឃ្លាន ព្រោះឧច្ចារៈ ព្រោះបស្សាវៈ ព្រោះការបង់មានបាន ព្រោះខុសបំណង នាំឲ្យឈ្លោះទាស់ទែង ព្រោះការព្រាត់ប្រាស ព្រោះជរា ព្រោះព្យាធិ ព្រោះមរណៈ ។ សេចក្ដីទុក្ខទាំងអស់នេះ លោកពោលថា ជាផលដែលកើតអំពីហេតុ គឺអវិជ្ជាតណ្ហាជាដើម ដោយមានហេតុជាប្រភព ។

មូលហេតុនៃសេចក្ដីទុក្ខទាំងអស់នោះ បានដល់ធម៌ជាបច្ច័យតាក់តែង មានអវិជ្ជាតណ្ហាជាដើម ដែលមានក្នុងអរិយសច្ច ដូចសេចក្ដីតទៅ ប៉ុន្តែពុំបានអធិប្បាយអំពីអវិជ្ជាទេ អធិប្បាយចំពោះតណ្ហា ។

## តណ្ហា ៣ យ៉ាងគឺ

១– កាមតណ្ហា តណ្ហាប្រព្រឹត្តទៅ ក្នុងកាម ។

២– ភវតណ្ហា តណ្ហាប្រព្រឹត្តទៅ ក្នុងរូបភព ។

៣– វិភវតណ្ហា តណ្ហាប្រព្រឹត្តទៅ ក្នុងការប្រាសចាករូបភព ។

សេចក្ដីអន្ទះអន្ទែងក្នុងវត្ថុកាមទាំង ៥ មានរូបជាដើម ហៅថា "កាមតណ្ហា" គឺសេចក្ដីប្រាថ្នា ជាប់ជំពាក់ ក្នុងការកើតក្នុងកាមភពទាំង ១១ ជាន់ គឺអបាយភូមិ ៤ មនុស្ស ១ និងសួគ៌ទេវលោក ៦ ជាន់ ។ សេចក្ដីប៉ុនប៉ងនឹកនារបស់សត្វ ដែលជាប់ស្អិតនៅក្នុងកាមភព ១១ ជាន់

មិនទាន់ឃើញទោសដោយជាក់ច្បាស់នៅឡើយ គឺជាតណ្ហានាំចិត្តសត្វឲ្យញ៉ាំមលិចលង់ ឲ្យត្រាញនៅក្នុងកាមភព ដែលមិនទាន់អាចនឹងរលាស់ខ្លួនចេញចាកកាមភពបាន ។

សេចក្តីអន្ទះអន្ទែងប្រាថ្នាចង់កើត ក្នុងរូបភពទាំង ១៦ ជាន់ ហៅថា "ភវតណ្ហា" គឺជាកិលេសជាតិដែលនាំចិត្តយោគាវចរ ឲ្យចម្រើនរូបជ្ឈាន ដើម្បីទៅកើត ក្នុងរូបព្រហ្ម ដោយអំណាចនៃចិត្តនឿយណាយចាកកាមភព ។

សេចក្តីអន្ទះអន្ទែងប្រាថ្នាចង់កើត ក្នុងអរូបភព ៤ ជាន់ ហៅថា "វិភវតណ្ហា" គឺជាកិលេសជាតិដែលនាំចិត្តយោគាវចរ ឲ្យចម្រើនអរូបជ្ឈាន ដើម្បីចង់ទៅកើត ក្នុងអរូបភព ដោយការមិនចង់ឲ្យមានរូបកាយប្រាកដជាគំណែងយសស័ក្តិទៅទៀត ។

ពុទ្ធភាសិតដែលសំដែងអំពីទុក្ខទាំងអស់នោះ មានទុក្ខ ៤ កង់ខាងដើម គឺ ជាតិ ជរា ព្យាធិ និង មរណៈ ជាទុក្ខដ៏ក្រៃលែងជាងទុក្ខដទៃទៀតសម្រាប់ជីវិត ។ ដូច្នេះឃើញថា ក្នុងលោកនេះ ទោះបីមនុស្សមានឋានៈបែបណាក៏ដោយ សុទ្ធតែប្រកបដោយសេចក្តីទុក្ខទាំងអស់ សមនឹងពុទ្ធភាសិតថា " តញ្ច ទុក្ខាន សំយុតំ ជីវិតនោះ គឺសេចក្តីទុក្ខគ្របសង្កត់" ។ ព្រោះហេតុនោះ បានជាព្រះអរិយបុគ្គល នានព្រះ

ពុទ្ធជាដើម មិនត្រូវការជីវិត គឺជាតិកំណើតនេះទៀតទេ ទើបព្រះអង្គទ្រង់លះបង់ព្រះរាជសម្បត្តិ ព្រះបល្ល័ង្ក ព្រះអគ្គមហេសី ព្រះរាជបុត្រ និងព្រះវរមាតាបិតា ស្រីស្នំក្រមការ យាងចេញចាកប្រាង្គប្រាសាទដ៏ស្អាត ទៅបំពេញព្រះផ្នួស បានព្យាយាម ធ្វើទុក្ករកិរិយាយ៉ាងតឹងបំផុត អស់រយៈកាល៦វស្សា លុះត្រាតែបានត្រាស់ជាព្រះពុទ្ធ ដល់បានត្រាស់ដឹងហើយ ព្រះអង្គក៏មានការរវល់ជាច្រើន តាំងយប់-ថ្ងៃ ដើម្បីជួយដោះស្រាយជីវិត ជួយចម្លងសត្វលោកឲ្យផុតពីជីវិតមានទុក្ខ ដោយពុទ្ធចរិយា និងពុទ្ធកិច្ចអស់ថេរវេលា៤៥វស្សា ឥតមានខ្លាចនឿយហត់ព្រះអង្គឡើយ ៗ

ការវែកញែកចំពោះជីវិត ព្រមតាំងសេចក្ដីអធិប្បាយ ដែលមានមកក្នុងគម្ពីរបាលីនិងអដ្ឋកថា ដូចសេចក្ដីពណ៌នាតទៅនេះទៀត :

ព្រះពុទ្ធសាសនា គឺធម៌វិន័យ ដែលព្រះសម្ពុទ្ធបរមគ្រូ ទ្រង់សំដែងទុកមក សុទ្ធតែប្រព្រឹត្តទៅ ដើម្បីដោះស្រាយបញ្ហាជីវិត ជួយឧបត្ថម្ភជ្រោមជ្រែងជីវិត បោសសំអាតលាងជម្រះនូវមន្ទិលរបស់ជីវិត នៃសត្វលោកទាំងអស់ ពុំមែនប្រយោជន៍ក្រៅពីការដោះស្រាយជីវិត ជួយជីវិតនៃសត្វលោកឡើយ ៗ ធម្មទេសនា នៃព្រះសម្មាសម្ពុទ្ធ ដោយឧបាយផ្សេង ៗ ច្រើនយ៉ាង ដើម្បីដឹកនាំសត្វលោក ឲ្យជ្រះថ្លាចូលចិត្តដោយខ្លួនឯងចំពោះហេតុផល ក្នុងការរៀបចំកសាងជីវិត ឲ្យបរិសុទ្ធផូរផង់ សមដូចពុទ្ធភាសិត ក្នុងគម្ពីរធម្មបទខុទ្ទកនិកាយថា

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

ប្រែថា ជីវិតគឺការរស់នៅ តែមួយថ្ងៃ របស់បុគ្គលអ្នកមានសីល មានឈាន ប្រសើរជាងជីវិតបុគ្គលគ្មានសីល គ្មានសមាធិ ដែលរស់នៅអស់ ១០០ ឆ្នាំ ។

យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។

ប្រែថា ការរស់នៅតែមួយថ្ងៃ របស់បុគ្គលកាលពិចារណាឃើញនូវទីកើតទីរលត់ ( នៃសង្ខារ ) ប្រសើរជាងជីវិតនៃបុគ្គលកាលមិនបានពិចារណាឃើញនូវទីកើតទីរលត់ ដែលរស់នៅអស់ ១០០ ឆ្នាំ ។

ពុទ្ធភាសិតដែលប្រារព្ធពាក់ព័ន្ធនឹងជីវិតនេះ មានច្រើនន័យ ប៉ុន្តែបានយកពុទ្ធភាសិតតែពីរគាថាប៉ុណ្ណោះ ដើម្បីជាឧទាហរណ៍ ។

ពុទ្ធភាសិតខាងលើនេះ បញ្ជាក់ឲ្យឃើញថា ព្រះសម្មាសម្ពុទ្ធសំដែងសរសើរជីវិតរបស់បុគ្គលប្រព្រឹត្តសុចរិតដោយកាយវាចាចិត្ត និងជីវិតរបស់បុគ្គលអ្នកមានប្រាជ្ញា បេះពិចារណាឃើញសេចក្ដីចំរើននិងសេចក្ដីវិនាស ។

ជីវិតនេះ ជាធម្មជាតពិសេសមួយ ដែលអាចញុំាងសរីរយន្តៈឲ្យមានចលនា ដើម្បីប្រកបកិច្ចការបាន ។ ជីវិតនេះជាសហជាតធម៌ នៃរូប

មនុស្សសត្វ មាននាទីទាងការប្រស់ព្រំរូបធម៌ ឲ្យប្រព្រឹត្តទៅស្រួល ប៉ុន្តែដូចយ៉ាងសង្ខារ ៣ មានកាយសង្ខារជាដើម គ្រាន់តែជាសម្ភារៈនៃជីវិត ឯនាមក្ខន្ធ ៤ មានវេទនាជាដើមដោយរួមគ្នា ទើបឈ្មោះថាជាជីវិត, ន័យមួយទៀត លោកប្រមូលយកធម្មជាត ក្នុងពួកនាមធម៌ទាំងអស់ មានចិត្តចេតសិកជាដើម ជាឈ្មោះនៃជីវិត ។

ជីវិតនេះ ជាធម្មាធិដ្ឋាន ប៉ុន្តែលោកអាចលើកឡើងនិយាយទៅជាបុគ្គលាធិដ្ឋាន ដើម្បីឲ្យស្រួលស្តាប់ក៏បាន ។ ការវែកញែកចំពោះជីវិតនេះទៅជា ២ យ៉ាង ក៏មាន, ៤ យ៉ាង ក៏មាន, ៦ យ៉ាង ក៏មាន ដែលត្រូវអធិប្បាយបន្តគ្នា ជាលំដាប់តទៅទៀត :

ការវែកញែកជីវិតព្រមទាំងអធិប្បាយ

## ជីវិត ២ យ៉ាងគឺ

១- ភោគជីវិត ជីវិតផ្ទូវផង់ ។

២- សំកិលិដ្ឋជីវិត ជីវិតៈសៅហ្មង ។

អដ្ឋកថាសុត្តន្តបិដក ដែលកែពាក្យថា ជីវិតនោះ ដូច្នេះ ។

«ជីវិតន្តិ អរូបសេស្សវេតំ ហិ អធិវចនំ ចតូសុ ឥរិយាបថេសុ វត្តមានាយ ចលនាយ បវត្តិ តស្មា តំ នាមំ ហោតិ ។ ជីវិតញ្ហិ ទុវិធំ ភោគជីវិតំ ច

សំកិលិដ្ឋជីវិតំ ច ។ តត្ថ ភោគាជំ នាម ជីវិតំ សទ្ធាយ សិក្ខាយ បដិបត្តិយា ចាតិ តីហិ ធម្មេហិ បវត្តិតំ សំកិលិដ្ឋំ នាម ជីវិតំ សទ្ធាយ សិក្ខាយ បដិបត្តិយា ចាតិ តីហិ ធម្មេហិ អប្បវត្តិតំ ។

ពិតណាស់ ពាក្យថា ជីវិតន្ទ្រិយ៍ ជាឈ្មោះនៃអរូបធម៌ តែងប្រព្រឹត្តទៅដោយចលនា កាលប្រព្រឹត្តក្នុងឥរិយាបថ ៤ ព្រោះហេតុនោះ ជីវិតនោះឈ្មោះថាជានាមធម៌ ។ ពិតណាស់ជីវិតមានពីរយ៉ាងគឺ ភោគាជ-ជីវិត ១ សំកិលិដ្ឋជីវិត ១ ។ បណ្តាជីវិតទាំងនោះ ជីវិតដែលបុគ្គលឲ្យប្រព្រឹត្តទៅដោយធម៌ ៣ យ៉ាងគឺ សទ្ធា ១ សិក្ខា ១ បដិបត្តិ ១ ឈ្មោះថា ភោគាជៈ, ជីវិតដែលបុគ្គលមិនបានឲ្យប្រព្រឹត្តទៅដោយធម៌ ៣ យ៉ាងគឺ សទ្ធា ១ សិក្ខា ១ បដិបត្តិ ១ ឈ្មោះថា សំកិលិដ្ឋៈ ។

ពាក្យថា "ភោគាជជីវិត" ប្រែថា ជីវិតផូរផង់ សំដៅយកជីវិតដែលគេដោះស្រាយដោយធម៌ ៣ យ៉ាង ដូចសេចក្តីរៀបរាប់ ព្រមទាំងអធិប្បាយៈដោយសង្ខេប តទៅនេះ ៖

១) សទ្ធា ការជឿចំពោះកម្មផល ជឿចំពោះព្រះសម្មាសម្ពុទ្ធ ។ សទ្ធានេះ ដែលពុទ្ធបរិស័ទអ្នកធ្លាប់សិក្សា ធ្លាប់ស្តាប់ បានយល់ច្បាស់

ណាស់ហើយ ។ សទ្ធាកន្លងនេះ លោកសំដៅយកសទ្ធាសោកណៈ-ចេតសិក គឺលុះណាតែជំនឿប្រកបដោយហេតុផល ត្រូវតាមគតិបណ្ឌិតក្នុងទ្រឹស្ដីព្រះពុទ្ធសាសនា ដែលប្រៀនប្រដៅឲ្យជឿហេតុនិងផល គឺឲ្យអាន ឲ្យប្រកាន់ថា ហេតុល្អ នឹងឲ្យផលល្អ ហេតុអាក្រក់ នឹងឲ្យផលអាក្រក់ ។ អ្វីទាំងអស់ក្នុងលោក សុទ្ធសឹងតែប្រកបដោយហេតុនិងផល សមដូចជាគាថាដែលព្រះអស្សជិត្ថេរ សំដែងអាងឡើងថា

យេ ធម្មា ហេតុប្បភវា តេសំ ហេតុំ តថាគតោ
តេសញ្ច យោ និរោធោ ច ឯវំវាទី មហាសមណោ ។

ព្រះតថាគតត្រាស់សំដែងនូវធម៌ទាំងឡាយណា ដែលជាធម៌មានហេតុជាប្រភព ( ដែនកើតមុន ) ត្រាស់សំដែងនូវសេចក្ដីរលត់ និងឧបាយរលត់ នូវធម៌ទាំងឡាយនោះ ព្រះមហាសមណៈ តែងមានប្រក្រតីពោលយ៉ាងនេះ ។

មួយទៀត ការជឿកម្មនិងផលរបស់កម្ម គឺជឿថា "កម្មល្អ នឹងឲ្យផលល្អ កម្មអាក្រក់ នឹងឲ្យផលអាក្រក់ សេចក្ដីល្អអាក្រក់ សុខ ទុក្ខ ចម្រើន វិនាស ស្រេចហើយតែកម្មរបស់ខ្លួនដែលបានធ្វើទុក ឥតមានអ្វីជួយឲ្យគេខ្ទង់ផុត ចាកកម្មនិងផលនៃកម្មទៅបានឡើយ" ។ ករណីនេះ សមដូចពុទ្ធភាសិតថា

អត្តនា ហិ កតំ បាបំ អត្តនា សំកិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា ហិ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អំពើអាក្រក់ដែលខ្លួនឯងធ្វើហើយ ទឹងសៅហ្មងចំពោះខ្លួនឯង, អំពើអាក្រក់ដែលខ្លួនមិនបានធ្វើ ទឹងបរិសុទ្ធចំពោះខ្លួន, សេចក្ដីបរិសុទ្ធិនិងមិនបរិសុទ្ធិស្រេចលើខ្លួន, បុគ្គលដទៃមិនអាចធ្វើអ្នកដទៃឲ្យបរិសុទ្ធបានទេ ។

សទ្ធាក្រៅពីនេះ ដែលប្រាសចាកហេតុផល មិនហៅថាសទ្ធាក្នុងព្រះពុទ្ធសាសនា ដើម្បីដោះស្រាយជីវិត ឲ្យរួចចាកទុក្ខបានឡើយ ។

២) សិក្ខា ការសិក្សាចំណេះវិជ្ជាផ្លូវលោក និងចំណេះវិជ្ជាផ្លូវព្រះពុទ្ធសាសនា ។ វិជ្ជាផ្លូវលោកនោះ បានដល់វិជ្ជាច្រើនយ៉ាង មានអក្សរសាស្ត្រ គណិតសាស្ត្រជាដើម ។ វិជ្ជាផ្លូវព្រះពុទ្ធសាសនានោះ បានដល់ការសិក្សាផ្នែកគន្ថធុរៈ (ការរៀនព្រះត្រៃបិដក) គឺព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម ឬ ផ្នែកវិបស្សនាធុរៈ (សិក្សា សីល សមាធិ បញ្ញា) ។ សិក្ខានេះ ជារបស់ចាំបាច់បំផុត ដោយហេតុថាជាអង្គការមួយ របស់ប្រទេសជាតិ សាសនា រាប់ថាជាករណីយកិច្ចមួយផ្ទាល់ខ្លួន ដើម្បីលើកតំកើងជីវិត ដោះស្រាយបញ្ហាជីវិត ឲ្យមានឋានៈខ្ពង់ខ្ពស់ ។ សិក្ខាចាត់ជាជំហានទី ១ ក្នុងការឧបត្ថម្ភជ្រោមជ្រែងជីវិត ។

៣) បដិបត្តិ ការប្រតិបត្តិ, សំដៅយកការប្រព្រឹត្តិប្រឆាំងនឹងបាប អកុសល ទុច្ចរិត គ្រប់យ៉ាង ដោយការមិនព្រមបណ្ដោយខ្លួនឲ្យថ្លស់ធ្លោយ ធ្លាក់ទៅក្នុងផ្លូវទុច្ចរិត ៣ យ៉ាង គឺកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ទុច្ចរិតណាមួយ ។

ជីវិត ដែលបុគ្គលជាបព្វជិត ឬគ្រហស្ថ បានបោសសំអាត លាងជម្រះ ប្រស់ព្រំ អប់រំដោយធម៌ ៣ យ៉ាង ដូចបានសំដែងខាងលើនេះ ឈ្មោះថា វោទាតជីវិត ។

ពាក្យថា « សំកិលិដ្ឋជីវិត » ប្រែថាជីវិតសៅហ្មង, សំដៅយកជីវិត ដែលគេមិនបានដោះស្រាយដោយធម៌ ៣ យ៉ាង មានសទ្ធាជាដើម ដូចសំដែងខាងលើនេះដែរ ។ ជីវិតរបស់បព្វជិត ឬ គ្រហស្ថ ដែលបណ្ដោយឲ្យប្រឡាក់សៅហ្មង ដោយបាប អកុសល ទុច្ចរិត គ្រប់យ៉ាង មិនព្រមបោសសំអាត លាងជម្រះ អប់រំដោយធម៌ ៣ យ៉ាង ឈ្មោះថា ជីវិតសៅហ្មង គគ្រល្អក់ ប្រកបដោយមន្ទិល ឈ្មោះថា សំកិលិដ្ឋជីវិត ។

ជីវិត ២ យ៉ាង ដូចសំដែងមកនេះ ឈ្មោះថាជីវិតចាស់ក្នុងបច្ចុប្បន្ន, ជីវិតទាំងនេះហើយ ទុកថាជាថ្នូរមួយ សម្រាប់ដូរយកជីវិតថ្មី ក្នុងកាលអនាគត ។ កាលបើជីវិតក្នុងបច្ចុប្បន្នបរិសុទ្ធផូរផង់ ត្រូវបានថ្នូរជីវិតថ្មី

ក្នុងអនាគតដ៏ប្រសើរពុំខាន, កាលបើជីវិតក្នុងបច្ចុប្បន្ន សៅហ្មងប្រឡាក់ដោយមន្ទិល ត្រូវបានថាជីវិតថ្មីក្នុងអនាគត ក៏សៅហ្មងថោកទាប តាមហេតុដើមពុំខានដែរ ។ ក្នុងករណីនេះ គួរបុរសស្ត្រីរក់ប្រយ័ត្នដោយម៉ត់ចត់ ចំពោះជីវិតគ្រប់ៗគ្នា គួរតែកសាងជីវិត រៀបចំជួសជុលជីវិតឲ្យបរិសុទ្ធផូរផង់ដោយផ្លូវសុចរិត តាំងអំពីបច្ចុប្បន្ននេះ ដរាបតទៅ ។

## ជីវិត ៤ យ៉ាង

ជីវិត ៤ យ៉ាង ដែលត្រូវសំដែងតទៅនេះ លោកប្រៀបដូចដើមឈើមានខ្លឹម មានលក្ខណៈស្រទាប់ ៤ បែបគឺ បប្បដិកា ក្រមរ ១, តចៈ សំបក ១, ផេគ្គុ ស្រាយ ១, សារៈ ខ្លឹម ១ ។

ឈើមានខ្លឹម មានលក្ខណៈ ស្រទាប់ ៤ បែប យ៉ាងណាមិញ, ឯលក្ខណៈជីវិត របស់សត្វលោកនោះ ក៏មាន ៤ យ៉ាង ដូច្នោះដែរ គឺ

១– បប្បដិកាជីវិត ជីវិតដូចក្រមរឈើ ។

២– តចជីវិត ជីវិតដូចសំបកឈើ ។

៣– ផេគ្គុជីវិត ជីវិតដូចស្រាយឈើ ។

៤– សារជីវិត ជីវិតដូចខ្លឹមឈើ ។

ជីវិតទី ១ ដែលប្រៀបដូចក្រមរឈើ សំដៅដល់ជីវិតរបស់មនុស្សថោកទាប ដោយការប្រព្រឹត្តទុច្ចរិត ដោយការក្រខ្សត់ទុគ៌ត ដែល

ជាអ្នករកស៊ីបានដោយលំបាក ត្រដាបត្រដួស រកបានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក គ្មានដីស្រែចំការ ដីភូមិ គ្មានផ្ទះសម្បែងសម្រាប់ដេកទៅ ច្រើនតែដេកនៅតាមសំយាបផ្ទះអ្នកដទៃ ឬតាមចិញ្ចើមថ្នល់ បើមានការឈឺចាប់ ក៏ស្លាប់បានដោយងាយ ឥតអ្នកណាជួន ជួយព្យាបាលជម្ងឺនោះឡើយ, ដូចយ៉ាងនៅប្រទេសដទៃ ដែលមានទឹកកកធ្លាក់ ព្រឹកឡើង ស្រាប់តែឃើញមនុស្សស្លាប់ ដេកស្តូកស្តឹងតាមសំយាបផ្ទះគេខ្លះ តាមចិញ្ចើមថ្នល់ខ្លះ ។ មួយទៀត ជីវិតរបស់មនុស្សមានទោសទុក្រិដ្ឋ ដែលគេបង្ខំឲ្យធ្វើការរហូតដល់អស់ជីវិត ឬមនុស្សដែលជាទាសាទាសីទៅបំរើគេ ត្រូវគេជេរស្តីវាយដំប្រើដាក់ដូចសត្វតិរច្ឆាន ពុំដែលបានធ្វើតាមរក្សាសីលទឹងគេទេ មានជីវិតរស់នៅក្រៀមក្រស់ ដូចជាក្រមរឈើជាប់នៅលើសម្បកឈើដូច្នោះ ។ ជីវិតបែបនេះ ហៅថា ជីវិតក្រមរ ឬជាជាជីវិតមោឃៈ ដូច្នេះក៏បាន ។

ជីវិតទី ២ ដែលប្រៀបដូចសំបកឈើ សំដៅយកជីវិតមានកម្រិតខ្ពស់ជាងជីវិតទី ១ បន្តិច គឺបានដល់ជីវិតមនុស្សក្រខ្សត់សាមញ្ញ ដែលមានដីស្រែចំការដីភូមិ តិចតួចដែរ ទ្រព្យសម្បត្តិជាសង្ហារិម ក៏តិចតួច មានមុខរបរដូចកសិកម្ម ពាណិជ្ជកម្ម គោរក្ខកម្ម ក៏ស្តួចស្តើងរលើបរលាប ឥតគ្រប់គ្រាន់ចិញ្ចឹមជីវិតបានទេ ទាំងផ្ទះសម្បែងសម្លៀកបំពាក់

កំពុំបានថ្លៃថ្លាប្រសើរឡើយ ។ ការធ្វើភាវនា រក្សាសីល ក៏បានធ្វើតិចតួច សភាពនៃការរស់នៅបែបនេះ ចាត់ថាជាជីវិតសំបក ដោយហេតុថា គ្រាន់តែមានជីវិតអបស្លុប នៅជាមួយនឹងគេប៉ុណ្ណោះ ។

ជីវិតទី ៣ ដែលប្រៀបដូចស្រាយនៃឈើ សំដៅយកជីវិតរបស់មនុស្ស ដែលមានកម្រិតខ្ពស់ជាងជីវិតទី ២ បន្តិចទៀត ។ ជីវិតនេះ បានដល់ឋានៈនៃមនុស្សមានគោតទ្រព្យ ថ្នាក់កណ្ដាល ឬសុកស្ដម្ភ ទាំងទ្រព្យជាសង្ហារិម និង អសង្ហារិម ក៏គ្រប់គ្រាន់ ប៉ុន្តែមិនមានអរិយទ្រព្យ សម្រាប់កំដរជីវិតរបស់ខ្លួននោះឡើយ ព្រោះទ្រព្យសម្បត្តិទាំងអស់ មានមាសប្រាក់ ផ្ទះសម្បែងជាដើម លោកចាត់ថា ជាទ្រព្យស្រាយ ។ ខាងក្រៅ ពុំរាប់ថា ជាទ្រព្យខ្លឹមខាងក្នុងសន្ដានទៅឡើយ ។

ជីវិត ដែលប្រៀបដូចស្រាយនៃឈើនេះ បានដល់ជីវិតនៃកុដុម្ពិក សេដ្ឋី ឥស្សរជនជាដើមពិតមែន, ប៉ុន្តែកម្រិតនៃជីវិតនេះ លោកពុំទាន់រាប់ថាប្រសើរខ្ពង់ខ្ពស់ដល់ទីបំផុតទេ ព្រោះថាជីវិតនោះ ពុំភាន់មានអរិយទ្រព្យ គឺពុំទាន់មានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា ជឿកម្មនិងផលនៃកម្ម ពុំទាន់មានហិរិឱត្តប្បៈ ជាដើមនៅឡើយ ឈ្មោះថាជាជីវិតស្រាយ ដែលអាចពុកផុយបានដោយងាយណាស់ ជាជីវិតប្រកបដោយបាបទុច្ចរិត មិនអាចរាប់ថា ជាជីវិតជាប់មាំមួនរឹងប៉ឹងបានឡើយ ។ (នៅមានត)

# ការពិសេសនៃអភិណ្ហប្បច្ចវេក្ខណធម៌

លោក ឆិល - មិត នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង
ព្រះសាសនមុនី កិម - ទួរ ក្រុមជំនុំព្រះត្រៃបិដក ពិនិត្យ

១– ជរាធម្មោម្ហិ ជរំ អនតីតោ អាត្មាអញ មានការចាស់គ្រាំគ្រាជាធម្មតា មិនកន្លងនូវការចាស់គ្រាំគ្រាបានឡើយ ,

២– ព្យាធិធម្មោម្ហិ ព្យាធឹ អនតីតោ អាត្មាអញ មានជម្ងឺតំកាត់ជាធម្មតា មិនកន្លងនូវជម្ងឺតំកាត់បានឡើយ ,

៣– មរណធម្មោម្ហិ មរណំ អនតីតោ អាត្មាអញ មានការស្លាប់ជាធម្មតា មិនកន្លងនូវការស្លាប់បានឡើយ ,

៤– សព្វេហិ មេ បិយេហិ មនាបេហិ នានាភាវោ វិនាភាវោ អាត្មាអញ មានការព្រាត់ប្រាសចាកសត្វនិងសង្ខារជាទីស្រឡាញ់ពេញចិត្ត ,

៥– កម្មស្សកោម្ហិ កម្មទាយាទោ កម្មយោនិ កម្មពន្ធុ កម្មប្បដិសរណោ, យំ កម្មំ ករិស្សាមិ កល្យាណំ វា បាបកំ វា, តស្ស ទាយាទោ ភវិស្សាមិ អាត្មាអញ មានកម្មជារបស់ផ្ទាល់ខ្លួន មានកម្មជាមតិកផ្ទាល់ខ្លួន មានកម្មជាអ្នកឲ្យកំណើតផ្ទាល់ខ្លួន មានកម្មជាពូជផ្ទាល់ខ្លួន មានកម្មជាទីពំនាក់

ផ្ទាល់ខ្លួន អាត្មាអញ នឹងធ្វើនូវកម្មណា ល្អក្ដី អាក្រក់ក្ដី, អាត្មាអញ នឹងជាអ្នកទទួលមតិកនៃកម្មនោះឯង ។

## អធិប្បាយ

ជរា ១ ព្យាធិ ១ មរណៈ ១, ធម៌ ៣ យ៉ាងនេះ លោកពោលថា " តែងមានជាធម្មតា ដល់មនុស្សសត្វគ្រប់រូបប្រាណ " ។

ជរា គឺការចាស់គ្រាំគ្រា, ព្យាធិ គឺការឈឺថ្កាត់, មរណៈ គឺការស្លាប់ ។ មនុស្សគ្រប់រូបច្រើនយល់ថា " មិនមែនមានជាធម្មតា ដល់មនុស្សសត្វគ្រប់ប្រាណទេ " ពីព្រោះមនុស្សសត្វ មានពីរប្រភេទ ដោយសង្ខេប គឺមានក្មេង មានចាស់, មានជា មានឈឺ, មានរស់ មានស្លាប់ ។ ដូច្នេះ ការចាស់គ្រាំគ្រា ក៏មានសម្រាប់តែមនុស្សចាស់, ជម្ងឺតំកាត់ មានសម្រាប់តែមនុស្សឈឺ, ការស្លាប់ មានចំពោះតែមនុស្សស្លាប់ប៉ុណ្ណោះ, ការចាស់គ្រាំគ្រា គ្មានចំពោះមនុស្សនៅក្មេង, ជម្ងឺតំកាត់ គ្មានចំពោះអ្នកជា, ការស្លាប់ គ្មានចំពោះអ្នករស់ឡើយ ។

លោកពោលនេះ មានទំនងសមហេតុ-ផលណាស់ ព្រោះតាំងយើងតាំងគេក៏តែងតែនិយាយថា "ក្មេង-ចាស់, ជា-ឈឺ, រស់ ស្លាប់" ដូច្នេះដែរ ។

បើដូច្នោះ អភិណ្ហប្បច្ចវេក្ខណធម៌ មិនជួយគ្នាពីយោបល់មនុស្ស

ទៅហើយឬ ? ពិតមែនហើយ, ចំពោះមនុស្សដែលមិនបានប្រើវិចារណញ្ញាណ តែងយល់ផ្ទុយពីអកិណ្ហប្បច្ចវេក្ខណធម៌នេះ, តែវិញ្ញូជនវិញលោកយល់ស្របថា មនុស្សសត្វ សុទ្ធតែមានការចាស់គ្រាំគ្រា, ជម្ងឺ តំកាត់ និងការស្លាប់នេះជាធម្មតា គឺត្រូវមានធម៌ ៣ យ៉ាងនេះ តាំងតែពីប្រថមខណៈនៃបដិសន្ធិ ( ជំបូង ) មកម៉្លេះ ។ បានសេចក្ដីថា មនុស្សសត្វក្មេងក៏មានការចាស់គ្រាំគ្រា, មនុស្សជាក៏មានជម្ងឺ, មនុស្សរស់ក៏មានការស្លាប់ នៅក្នុងខ្លួនដែរ ។

គ្រាប់ពូជ របស់ឈើផ្សេង ១ ដូចជាគ្រាប់ផ្លែស្វាយជាដើម, តើយើងធ្លាប់បានឃើញដើមស្វាយ, ស្លឹកស្វាយ, សំបកដើមស្វាយ, មែកស្វាយ . . . នៅនឹងគ្រាប់ស្វាយនោះដែរឬ? ចំពោះភ្នែកធម្មតា គេមើលពុំឃើញទេ ឃើញតែសាច់គ្រាប់ និងសំបកគ្រាប់ដ៏គគ្រាត តែប៉ុណ្ណោះ, តែចំពោះបញ្ញាចក្ខុ (ភ្នែកគឺបញ្ញា) វិញ, គេអាចមើលដឹងថា គ្រាប់ស្វាយនោះ មានដើម មានស្លឹក មានសំបក-ក្រមរ មានមែក មានផ្លែ-ផ្កា នៅក្នុងនោះទាំងអស់ ។

បើមានមែន, ហេតុអ្វីក៏មើលពុំឃើញ ? បានជាពុំឃើញ ពីព្រោះកម្រប្របល់គ្នា ទាល់តែយើងលែងដឹងដល់ស្គាល់បានទៅហើយ, ប៉ុន្តែដើម្បីនឹងពិសោធឲ្យឃើញច្បាស់, គេយកគ្រាប់ស្វាយនោះ ទៅបណ្ដុះ

នឹងដី ដែលប្រកបដោយដីជាតិ ប្រកបដោយរដូវទឹកជ្រើម, មិនយូរប៉ុន្មានឡើយ យើងនឹងបានឃើញយ៉ាងជាក់ច្បាស់នូវស្លឹកស្វាយ ពន្លកចេញពីគ្រាប់ស្វាយ, ហើយក្រោយមក, គ្រាប់ស្វាយនោះ ក៏ក្លាយទៅជាមានដើម មានមែក-ក្រមរ យ៉ាងធំខ្ពស់ ចេញផ្កា ផ្លែ រយោន រយោនពុំខាន ។

ចំណែកមនុស្សសត្វវិញ ក៏ដូច្នោះដែរ គឺក្នុងខណៈចាប់បដិសន្ធិជាដំបូងនោះ មកទល់នឹងប្រថមវ័យ, គេមើលដោយភ្នែកធម្មតា ឃើញថានៅក្មេងមែន, ប៉ុន្តែព្រះពុទ្ធបរមគ្រូ ទ្រង់បានឃើញការចាស់គ្រាំគ្រានៅក្នុងរូបក្មេងនោះស្រេចទៅហើយ ។ ការចាស់គ្រាំគ្រានោះ ក៏នៅលាយជាមួយនឹងរូបក្មេងនោះជាធម្មតា តែមនុស្សមើលពុំឃើញ ព្រោះវាពុំទាន់ចេញរូបសណ្ឋានឲ្យឃើញប្រត្យក្ស ដូចជាគ្រាប់ស្វាយដែរ ។ លុះដល់ពេលណា វាមានកម្លាំងខ្លាំងចេញមុខមកបង្ហាញដល់ភ្នែកយើង ដូចជាធ្មេញបាក់ សក់ស្កូវ ស្បែកយុរយារ ភ្នែកងងឹត កម្លាំងខ្សោយ ខ្នងកោង ។ល។ ពេលនោះ ទើបយើងលាន់មាត់គ្រប់គ្នាថា ចាស់គ្រាំគ្រាមែន ៗ តែបើតាមពិត, ការចាស់គ្រាំគ្រានេះ ពុំមែនទើបនឹងមានទេ គឺ វាមាននៅប្រចាំក្នុងរូបកាយយើងជានិច្ច រង់ចាំតែពេលរដូវនឹងចេញមុខឲ្យយើងឃើញ ក្នុងខណៈដែលកម្លាំងយើងទន់ខ្សោយប៉ុណ្ណោះ ។

ចំពោះជម្ងឺគាំកាត់វិញក៏ដូចគ្នា, មនុស្សដែលជាសុទ្ធតែមានជម្ងឺគាំកាត់ទៅជាប់ក្នុងខ្លួនជាធម្មតា, មិនដែលថាគ្មានជម្ងឺម្តងណាៈឡើយ ។ ដំណើរនេះពិតប្រាកដណាស់, ពីព្រោះមនុស្សយើង, បើពិនិត្យឲ្យម៉ត់ចត់បន្តិចទៅ ក៏គង់ឃើញច្បាស់ថា មួយថ្ងៃ ៗ ភ័យណាស់ ពីរឿងឈឺថ្កាត់ចេញមុខមកក្រៅ គឺខំប្រឹងណាស់ខាងការបង្កប់ជម្ងឺគាំកាត់នោះ ឲ្យលិចមុខទៅក្នុងរូបកាយវិញ ។ ហេតុអ្វីក៏ដូច្នោះ? បានជាដូច្នោះ ព្រោះថា –

មនុស្សយើង ភ័យអំពីជម្ងឺឃ្លាន, ត្រូវប្រឹងស្វែងរកអាហារមកបរិភោគបំពែតប្រាណ, ភ័យអំពីជម្ងឺក្តៅ, ជម្ងឺរងា, ប្រឹងស្វែងរកគ្រឿងការពារដូចជាសំលៀកបំពាក់ជាដើម មកអបស្បូបកាយ, ភ័យអំពីការឈឺចាប់ព្រោះកាកអាហារ, ប្រឹងទៅបន្ទោបង់ពេល, ភ័យអំពីការចុកចាប់ឈឺថ្កាត់ផ្សេង ៗ ប្រឹងស្វែងរកថ្នាំមកប្រកប ។ល។ ពិសេសទៅទៀត រូបកាយយើងនេះ គ្រាន់តែប្រើឥរិយាបថពុំស្មើ ក៏បណ្តាលឲ្យឈឺចាប់ដែរ, ដូចឈរយូរ - អង្គុយយូរ - ដេកយូរ - ដើរយូរជាដើម សុទ្ធតែបណ្តាលឲ្យឈឺចាប់ទាំងអស់ ហើយការឈឺចាប់នេះ មិនមែនបំពេញវាតែម្តងហើយបាត់សោះសូន្យជារហូតទៅទេ គឺដល់អស់អំណាចគ្រឿងប្រកបវា, វាក៏ឈឺចាប់ផ្តើមឡើងទៀតគ្មានពេលស្រាកស្រាន្ត ។ ដូច្នេះ បានជាមនុស្ស ត្រូវបរិភោគក៏ញឹកញាប់, ត្រូវបន្ទោបង់ក៏ញឹកញាប់ ត្រូវ

រក្សាឥរិយាបថ គឺការផ្លាស់ប្តូរកើញកញាប់ដែរ, ព្រោះតែខ្លាចជម្ងឺតំកាត់ចេញមុខមកជំនួសការសុខជាហ្នឹងឯង ។ ក្នុងគម្ពីរវិសុទ្ធិមគ្គលោកប្រាប់ថា "ឥរិយាបថេហិ បដិច្ឆន្នំ ទុក្ខំ សេចក្តីទុក្ខ ត្រវបិទបាំងដោយឥរិយាបថ" ។ ត្រង់នេះក៏រឹតតែបញ្ជាក់ថែមទៀតថា មនុស្សយើងបើមិនចេះប្រើឥរិយាបថ, នឹងឃើញទូវការឈឺចាប់ភ្លាម ៗ , ដូចជាអង្គុយបត់ជើងយូរ, ជើងក៏ចាប់ស្រពន់រោយឈឺចុកឡើងយ៉ាងតានតឹង, ប៉ុន្តែដល់យើងចេះតែផ្លាស់ប្តូរ គឺបត់ម្តង លាម្តង, បត់ម្តង លាម្តងទៅ, ជើងយើងក៏គ្មានរោយស្រពន់ឈឺចាប់អ្វីដែរ, ត្រង់ដែលមិនឈឺចាប់ហ្នឹងហើយ ដែលយើងមើលទុក្ខពុំឃើញ, បានជាយើងមើលពុំឃើញ ព្រោះមានឥរិយាបថ គឺការផ្លាស់ប្តូរលា-បត់នោះរាំងបាំងយើង ។ ដូច្នេះយើងអាចបញ្ជាក់បានថា មនុស្សសត្វ តាំងជាតាំងឈឺ សុទ្ធតែមានជម្ងឺតំកាត់នៅក្នុងរូបកាយគ្រប់ពេលជាធម្មតា ។

ចំណែក មរណៈ គឺសេចក្តីស្លាប់វិញ ក៏មិនខុសពី ជរា និងព្យាធិ នេះដែរ ។ មនុស្សយើងតែងយល់ថា មនុស្សដែលរស់ គឺមនុស្សដែលពុំទាន់មានការស្លាប់ ។ ឯអភិធម្មត្ថវិភាវនីធម៌វិញប្រាប់ថា មនុស្សរស់ហ្នឹងឯង មានការស្លាប់ជាប់នៅក្នុងរូបកាយជាធម្មតា គ្មានពេលណាដែលពុំទាន់មាននោះឡើយ ។

ដំណើរអះអាងនេះ យើងអាចវែកញែកបានដូច្នេះ ការរស់និងស្លាប់ ជាធម្មតាដែលនៅជាប់តៀកនឹងគ្នាជានិច្ច មនុស្សដែលរស់ គឺមនុស្សហ្នឹងឯងប្រឹងបំបិទការស្លាប់កុំឲ្យចេញមុខ តាមបែបដូចគ្នានឹងការបិទជម្ងឺតំកាត់ដូច្នោះដែរ ៗ ជារៀងរាល់ថ្ងៃ, មនុស្សសត្វភ័យណាស់អំពីរឿងស្លាប់, ខំថែជួនខ្លួនប្រាណ បំប៉នអាហារ រកគ្រឿងការពារផ្សេងៗ មកបិទបាំងរូបកាយ ព្រោះតែខ្លាចស្លាប់នោះវាចេញមុខមកជំនួសការរស់ ៗ តែទុកជាយ៉ាងណាក៏ដោយ, ការស្លាប់នៅតែមានអានុភាពបិតនៅក្នុងរូបកាយមនុស្សជានិច្ចនិរន្តរ៍, រង់ចាំតែពេលនឹងបញ្ចេញឥទ្ធិ-ពលមកជំនួសការរស់ប៉ុណ្ណោះ ៗ ឧទាហរណ៍ដូចជា សត្វជ្រូក ដែលគេចិញ្ចឹមយកសាច់ ៗ ជ្រូកនេះ ចាប់កើតឡើង ត្រូវគេផ្គត់ផ្គង់ថែរក្សាការពារវាដល់គំរិត ប៉ុន្តែការថែរក្សានេះ គឺដើម្បីការឆាប់របស់វាជាចុងក្រោយប៉ុណ្ណោះ ៗ អ្នកចិញ្ចឹម តែងពោលភ្នែកមើលរូបកាយវាជានិច្ច តែគេសំឡឹងមើលដុំសាច់វា ដោយការទន្ទឹងថា តើល្មមសម្លាប់យកផលប្រយោជន៍បានហើយឬនៅ ? តែប៉ុណ្ណោះ ៗ រួមមកថា ជ្រូកដែលគេចិញ្ចឹមនោះ គ្រាន់តែចាប់បុចកើតឡើង វាមានសាលក្រមកាត់ទោសប្រហារជីវិតជាស្រេចទៅហើយ, ម្ចាស់វាត្រូវការសម្លាប់ថ្ងៃណាក៏បានមិនចាំបាច់ដល់ពេលវាធំហើយនោះទេ ៗ ដូច្នេះ ជ្រូកនោះវាមានការស្លាប់

នៅជាប់និងការរស់របស់វាជាធម្មតា តាំងតែពីចាប់កើតឡើងមក, វារង់ចាំតែដល់កាលៈនៃការស្លាប់ចេញមុខមកផ្ដួលការរស់របស់វាប៉ុណ្ណោះ ។ រីឯមនុស្សសត្វទៅវិញ ដូច្នេះឯង, មនុស្សរស់ គឺមនុស្សមានការស្លាប់ជាប់ៈនៅជាមួយជាធម្មតា ។ ម្យ៉ាងទៀត ជញ្ជីងដែលមានថាសសង-ខាង, កាលណាម្ខាងធ្ងន់ ចំណែកម្ខាងទៀតគឺបះឡើង, បើចំណែកម្ខាងនេះធ្ងន់វិញ, ឯម្ខាងដែលស្រាលក៏ត្រូវបះឡើងវិញដែរ ។ មនុស្សសត្វ មានការរស់និងការស្លាប់ដូចជញ្ជីង គឺកាលណាការរស់មានកម្លាំងខ្លាំងជាង ការស្លាប់ក៏ត្រូវនៅសម្ងំក្នុងរូបកាយសិន ទម្រាំតែការរស់នោះខ្សោយកម្លាំងទៅជាងវាវិញ ទើបវាចេញមុខមកធ្វើការផ្ដួលការរស់ម្ដងវិញ ។ ហេតុដូច្នេះ ឃើញថា មនុស្សសត្វមានការស្លាប់នេះនៅជាប់ក្នុងខ្លួនជាធម្មតាពិតណាស់ ។

បើពោលឲ្យល្អិតទៅទៀត, ការស្លាប់នេះ ក្នុងគម្ពីរវិសុទ្ធិមគ្គលោកចែកជា ៤ បែបគឺ កាលមរណៈ ១ អកាលមរណៈ ១ ខណិកមរណៈ ១ សមុច្ឆេទមរណៈ ១ ។

១– កាលមរណៈ: ការស្លាប់តាមកាល គឺស្លាប់តាមកំរិតអាយុរបស់មនុស្ស ។ ដូចជាសម័យពុទ្ធកាល, មនុស្សជំនាន់នោះ មានអាយុមធ្យម ១២០ ឆ្នាំ បើមនុស្សសម័យនោះ ស្លាប់ក្នុងអាយុ ១២០ ឆ្នាំ ឬលើសខ្វះពីនោះខ្វះ, ការស្លាប់នេះ ហៅថា ស្លាប់តាមកាល ។

រីឯមនុស្សសម័យសព្វថ្ងៃវិញ, បរិមាណកាយុមធ្យមប្រហែលជា ៧០ ឬ ៨០ ឆ្នាំ ឬ ក៏ខ្វះលើសខ្វះ, បើមនុស្សស្លាប់ក្នុងចំនួនទាំងនេះ, ការស្លាប់នោះ ហៅថា កាលមរណៈ ដូចគ្នា ។

២ – អកាលមរណៈ ការស្លាប់មិនត្រូវតាមកាល គឺស្លាប់ផ្ទុយពីកាលមរណៈខាងលើនេះ, ដូចជាស្លាប់ក្នុងវ័យនៅក្មេង ព្រោះរោគាពាធ, ព្រោះត្រូវប្រហារ, ព្រោះលង់ទឹក, ព្រោះគ្រោះថ្នាក់យន្ត, ព្រោះធ្លាក់ពីលើដើមឈើ, ព្រោះខ្ទុះបាញ់ជាដើម; ការស្លាប់បែបនេះ ហៅថា អកាលមរណៈ ទាំងអស់ ។

៣ – ខណិកមរណៈ ការស្លាប់មួយខណៈៗ ។

៤ – សមុច្ឆេទមរណៈ ការស្លាប់របស់ព្រះអរហន្ត ដែលអស់កិលេសហើយ ដែលមានចិត្តជាលោកុត្តរៈ គឺចិត្តចូលកាន់និព្វានបានហើយ, សំដៅយក អនុបាទិសេសបរិនិព្វាន របស់ព្រះអរហន្ត ។

បណ្ដាការស្លាប់ទាំង ៤ នេះ, សូមលើកយកតែការស្លាប់ទី ៣ គឺ ខណិកមរណៈ មកបញ្ជាក់ថែម ។ ខណិកមរណៈ ការស្លាប់មួយខណៈៗ គឺស្លាប់មួយគ្រែត ហើយកើតឡើងភ្លាម ។ ស្លាប់គ្រែត កើតភ្លាម, ស្លាប់គ្រែត កើតភ្លាម យ៉ាងនេះហៅថា ខណិក-

មរណៈ ។ មនុស្សសត្វ មានការស្លាប់កើតតាមនេះ នៅជាធម្មតាអចិន្ត្រៃយ៍ក្នុងរូបកាយ ។

មែនពិត, មនុស្សសត្វប្លែកពីធម្មជាតិឯទៀត ។ ព្រោះមនុស្សសត្វមានវិញ្ញាណ–ចិត្ត នៅឃុំគ្រងរូបកាយ ។ រូបកាយ គ្រាន់តែជាលំនៅរបស់ចិត្ត, កាលបើចិត្តចេញផុតពីរូបកាយហើយ, រូបកាយនោះមិនខុសពីផ្ទះគ្មានមនុស្សនៅឡើយ គឺជារូបកាយអសារបង់ ដែលហៅថា ស្លាប់, ក្នុងគម្ពីរមហាវគ្គលោកបានប្រាប់ថា

អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ
អបវិទ្ធោ តទា សេតិ និរត្ថំវ កលិង្គរំ ។

« ក្នុងខណៈណាដែល អាយុ ១ ឧស្មា ១ វិញ្ញាណ ១ (ធម៌ តាំង ៣ យ៉ាងនេះ) លះបោលនូវកាយនេះហើយ ក្នុងខណៈនោះកាយនេះក៏ដេកស្តូកស្តឹងរកប្រយោជន៍គ្មាន ដូចជាអង្កត់ឧសដូច្នោះ ។

សេចក្តីថា អាយុ គឺដំណើរប្រព្រឹត្តទៅនៃជីវិត, ឧស្មា គឺចំហាយកំដៅរបស់ភ្លើងធាតុ និង វិញ្ញាណ គឺ ចិត្ត ដែលអាស្រ័យជាប់នៅនឹងរូបកាយនេះ កាលបើត្រូវរលត់អស់ពីរូបកាយហើយ, រូបកាយនោះ ក៏ត្រូវស្លាប់ ព្រោះរូបកាយមិនអាចនៅបែកជាប់ដោយឡែកពីធម៌ ៣ យ៉ាងនេះបានឡើយ ។ អង្កត់ឈើ ដែលភ្លើងឆេះពេលតាំងសង

ខានទៅសល់តែបន្តិច ហើយប្រឡាក់លាមកដ៏អសោចទៀត, ក៏ស្ថិតនៅកណ្ដាលព្រៃដ៏សម្បូរដោយទុស តើក៏មានប្រយោជន៍ដល់អ្នកទេទុសដែរឬ? គឺពិតជាអ្នកទេទុសគ្មានខ្វល់ត្រូវការទេ ដូច្នោះដែរ ។

សេចក្ដីនេះ យើងចង់បញ្ជាក់ថា រូបកាយ គឺពិតជាលំនៅរបស់ចិត្តកាលបើចិត្តរលត់, រូបកាយក៏ត្រូវរលត់ដូចគ្នា ។ ចំណែកដំណើរចិត្តវិញ អ្នកប្រាជ្ញ លោកបានកំណត់ឲ្យស្គាល់ថា ក៏មានការគោងអារម្មណ៍បានទើបកើតឡើងបាន ព្រោះអារម្មណ៍ជាវត្ថុធាតុឲ្យចិត្តកើត ។ ដូច្នេះ បើអារម្មណ៍មួយកើតឡើង ចិត្តមួយក៏កើតឡើង, លុះអារម្មណ៍នោះរលត់ទៅវិញ ចិត្តនោះក៏រលត់ទៅជាមួយគ្នាដែរ ។ ដូចជា យើងឃើញគោ, ចិត្តមួយក៏កើតឡើងដោយគោងគោនោះជាអារម្មណ៍, តែបើយើងឈប់ឃើញគោ បែរមកឃើញក្របីម្ដងវិញ, ចិត្តដែលគោងគោជាអារម្មណ៍ ក៏រលត់ទៅភ្លាម, ចិត្តថ្មីដែលគោងក្របីជាអារម្មណ៍ ក៏កើតឡើងថ្មីទៀតដែរ ។

ក្នុងមួយថ្ងៃ ៗ ចិត្តយើងកើតរលត់ រាប់មិនបាន ប្រមាណមិនត្រូវព្រោះយើងជួបប្រទះនឹងអារម្មណ៍ច្រើនណាស់, អារម្មណ៍ខ្លះ ជួបតាមផ្លូវភ្នែក, ខ្លះជួបតាមផ្លូវត្រចៀក, ខ្លះតាមផ្លូវច្រមុះ, ខ្លះតាមផ្លូវអណ្ដាត ខ្លះតាមផ្លូវរូបកាយ, ខ្លះតាមផ្លូវទឹក ។ ដូច្នេះហើយ បានជាក្នុងគម្ពីរព្រះអភិធម្ម លោកលំអិតចែកជាខណៈរបស់ចិត្តមាន ៣ គឺ ឧប្បាទ-

ខណៈ ១ ឋិតិខណៈ ១ ភង្គខណៈ ១ ៗ ឧប្បាទខណៈ គឺខណៈដែលចិត្តតោងអារម្មណ៍ជាប់កើតឡើង, ឋិតិខណៈ គឺខណៈដែលចិត្តកំពុងត្រិះរិះអារម្មណ៍, ភង្គខណៈ គឺខណៈដែលចិត្តត្រូវបែកធ្លាយរលត់ទៅជាមួយនឹងអារម្មណ៍វិញ ៗ អារម្មណ៍នីមួយ ៗ មានខណៈនៃចិត្តទាំង ៣ នេះជាប់ជានិច្ច ហើយត្រូវរលត់ទៅជាមួយនឹង ភង្គខណៈទាំងអស់គ្នាជាធម្មតា ៗ

បើចិត្តយើងកើតរលត់ ក្នុងមួយថ្ងៃ ៗ រាប់លានដងដូច្នេះ តើរូបកាយយើង មិនឈ្មោះថាស្លាប់រាប់លានដងដែរទៅហើយ ?

ច្បាស់ជាស្លាប់រាប់លានដងមែន បានជាអ្នកប្រាជ្ញលោកកំណត់ឈ្មោះការស្លាប់ប្រភេទនេះ ថា ខណិកមរណៈ គឺការស្លាប់មួយភ្លែត ៗ ៗ ប៉ុន្តែត្រូវយល់តទៅទៀតថា រូបកាយយើង ពិតមែនតែស្លាប់ញឹកញូសដល់ម្ល៉ោះ តែពុំត្រូវសូន្យវិនាសទាន់ទេ ព្រោះខណៈចិត្តនោះ រហ័សលឿនពន់ពេក ប្រៀបដូចជាកង់ ៗ ធម្មតាកង់ មានកាំ, កាំនោះ ពុំមែននៅជាប់នឹងគ្នាជាផ្ទាំងមួយទេ គឺបើគេដាក់វាឲ្យនៅស្ងៀម គេអាចមើលឃើញចន្លោះ ៗ របស់កាំកង់ជាច្រើន, ប៉ុន្តែបើគេបង្វិលកង់នោះឲ្យវិលយ៉ាងខ្លាំងទៅ ក្នុងពេលនោះ គេពិតជាមើលពុំឃើញចន្លោះកាំទាំងនោះសោះឡើយ យ៉ាងណាមិញ, ខណៈចិត្ត

ដែលកើតលើតញាប់ខ្លាំងពេកទៅ, រូបកាយ ក៏ទៅជាទៅដូចសភាពធម្មតា, មិនអាចទៅជារបស់ឥតប្រយោជន៍ ដូចជាអង្កត់ៗសដូច្នោះទាន់ឡើយ ក៏យ៉ាងនោះដែរ ។

ដូច្នេះ មនុស្សសត្វមានការស្លាប់ទៅជាប់នឹងខ្លួនជាធម្មតា រឹតតែច្បាស់លាស់ណាស់ទៅទៀត ។

ចំណែកអភិណ្ហប្បច្ចវេក្ខណធម៌ទី៤ ថា "យើងមានការព្រាត់ប្រាសនិងសព្វសត្វនិងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្ត" ។ ត្រង់ពាក្យថា សត្វ ក្នុងទីនេះ សំដៅយកមនុស្សសត្វដែលមានវិញ្ញាណចិត្តនៅឃុំគ្រង់រូបកាយ, រីឯពាក្យថា សង្ខារ សំដៅយកវត្ថុដែលគ្មានវិញ្ញាណ ដូចជា ផ្ទះសម្បែង ទ្រព្យសម្បត្តិ និងសម្ភារៈផ្សេងៗ ។

មែនពិត, មនុស្សយើង លោកប្រៀបបាននឹងសំណាក់ឈើដែលហូរតាមដងស្ទឹង ឬ ទន្លេក្នុងរដូវទឹកជំនន់ ។ សំណាក់ឈើទាំងនោះ, កំណើតកើត នៅនាព្រៃភ្នំ ទីតំបន់ផ្សេងៗ គ្នា, លុះដល់មានភ្លៀងធ្លាក់ជោរជន់, សំណាក់ឈើនោះៗ ដែលត្រូវទម្ងន់ខ្យល់បក់បោកបំបាក់ខ្លះ ពុកផុយរបេះធ្លាក់ខ្លះ ត្រូវគេកាប់រំលំចោលខ្លះ ។ល។ ក៏រអិលហូរធ្លាក់តាមខ្សែទឹកពីទីខ្ពស់មកកាន់ទីទាបទំនាប, ខ្លះហូរអណ្តែតតាមអូរ ព្រែកប្រឡាយផ្សេងៗ រហូតធ្លាក់ចូលដល់ដងស្ទឹងទន្លេ ។ សំណាក់ទាំង

នោះ ខ្លះក៏ធំជ្រឹងជ្រេង ខ្លះតូចៗ ខ្លះទៀតកំណាត់កំណាត់ល្អិត ៗ ហូរកាត់ទីផ្សេង ៗ គ្នា តាមផ្លូវរៀង ៗ ខ្លួន, លុះចូលមកដល់ដងស្ទឹង-ទន្លេ ក៏ស្រាប់តែមកជួបជាប់គ្នាជាក្រុម ៗ ហូរហែអណ្តែតរសាត់ដេរដាសពាសពេញដងស្ទឹង-ទន្លេ មិនដឹងជាទីដៅត្រូវទៅកន្លែងណាឡើយ ៗ ពោះបីសំណាត់ឈើទាំងនេះ ចំបេញពីកន្លែងរៀងខ្លួនបានមកជួបផ្តុំគ្នាជាកង ៗ រសាត់កៀកកិតជិតគ្នា កកកុញ តាមខ្សែទឹក ក្នុងដងស្ទឹង-ទន្លេ បេះតែកើនចំនួនឡើងបន្តិចម្តង ៗ ឥតស្រាកស្រាន្ត ដោយផ្លូវទឹកឯទៀត ៗ បេះតែបន្សាត់សំណាត់ឯទៀត ៗ ឲ្យមកជួបគ្នាកាន់តែច្រើនឡើង យ៉ាងនេះហើយក៏ដោយ, ការជួបផ្តុំគ្នានេះ ពុំបានស្ថិតស្ថេរអស់កាលដល់ទីបំផុតទេ, កាលដែលសំណាត់ឈើទាំងនោះកំពុងរសាត់ទៅ ជួនកាលទៅប៉ះនឹងអូរ ព្រែក ប្រឡាយណាមួយ ដែលមានខ្សែទឹកញែកហូរចូល, សំណាត់ឈើទាំងនោះ ក៏ត្រូវខ្សែទឹកមួយបែក ហូរប្រទាញកាត់បញ្ចូលទៅក្នុងព្រែក អូរ ប្រឡាយនោះ ៗ ណាដែលត្រូវខ្សែទឹករុញច្រានឲ្យហួសទៅតាមដងស្ទឹង-ទន្លេដដែល ក៏ញែកគ្នារសាត់ទៅ ៗ ម៉្លោះហើយ ក៏មានការប្រទាញប្រទង់គ្នា ហាក់ដូចអាឡោះអាល័យមិនចង់បែកបាក់គ្នាសោះ ជួនកាលដាច់ចេញពីគ្នា ដោយស្រួល, ជួនកាលត្រូវដាច់យ៉ាងដំណាំលាន់ឮផ្លូងផាងរំពងលើផ្ទៃទឹក ៗ បើមិនដូច្នោះទេ

ដួនកាលក៏ត្រូវពួកមនុស្ស ចុះស្កាត់ស្រង់យកធ្វើជាឧសដុត, ដួនកាលរសាត់ទៅទាក់ជាប់នឹងអ្វីមួយ ក៏នៅជាប់ទើរក្អងទីនោះទៅ ។ សំណាក់ឈើទាំងនោះ ក៏ត្រូវព្រាត់ប្រាសទិសបែកពីគ្នា គួរឲ្យអាណោចអធ័មក្រៃលែង យ៉ាងណាមិញ ។ មនុស្សសត្វ ក៏ដូច្នោះដែរ ។ កាលដែលមកចាប់កំណើត, មនុស្សសត្វទាំងនោះ ត្រូវចេញពីប្រភពផ្សេង ៗ គ្នា មិនដឹងជាមកពីណាខ្លះទេ, លុះមកកើតហើយ ក៏មានម៉ែឪ ជីដូន ជីតា ម្ដាយមីងមា ភរិយាស្វាមី បងប្អូន ហើយថែមទាំងមានមិត្រភក្ដិ ញាតិសន្ដាន ព្រៀងលាន ជាគូគនគ្នា ហូរទៅតាមខ្សែជីវិត ក្នុងកាលវដ្ដសង្សារ, តែការជួបជុំគ្នានេះ មិនយូរប៉ុន្មាន ក៏ត្រូវវិនាសទៅវិញ គឺត្រូវស្លាប់ព្រាត់ប្រាសគ្នា, ត្រូវជេរចោលគ្នា ត្រូវបែកសាមគ្គីពីគ្នា ទៀសពុំផុត ដូចជាសំណាក់ឈើទាំងនោះដែរ ។

ដូច្នេះ ការព្រាត់ប្រាសចាកសត្វនិងសង្ខារនេះ ពិតជាមានប្រាកដណាស់, គ្មានមនុស្សសត្វណាមួយគេចបានឡើយ ។

អភិណ្ហប្បច្ចវេក្ខណធម៌ទី ៥ ថា យើងមានកម្មជារបស់ខ្លួន, មានកម្មជាទាយាទ, មានកម្មជាយោនិ, មានកម្មជាពន្ធុ, មានកម្មជាបដិសរណៈ, យើងធ្វើកម្មណា ទោះល្អក្ដី ទោះអាក្រក់ក្ដី យើងនឹងបានជាទាយាទនៃកម្មនោះ ។

ត្រង់នេះ ជាខសំខាន់ណាស់, ពីព្រោះកម្មនេះ, បើតាមផ្លូវពុទ្ធសាសនា លោកលើកជាតួឯក ។ បានជាពុទ្ធសាសនា មាននាមថា ជា កម្មនិយម គឺកំណត់យក កម្ម ជាគោលធំរបស់សាសនា ៗ

ចុះអ្វីទៅ ដែលហៅថា កម្ម? តាមធម្មតា, វត្ថុនីមួយ ៗ សុទ្ធតែមានគ្រឿងសម្ភារៈផ្សំគ្នាទើបកើតឡើងបាន, ដូចយ៉ាងរទេះ, ទាល់តែមានកង់-កាំ តួ-ទូក-នឹម ។ល។ ផ្សំគ្នា ទើបកើតទៅជារទេះ ចុះសម្ភារៈអ្វីខ្លះផ្សំគ្នា ទើបបានឈ្មោះថា កម្ម? ៗ

គួរឲ្យចំឡែកដែរ ដែលមកនិយាយជជីកពីគ្រឿងផ្សំឲ្យកើតជាកម្មដូច្នេះ ប៉ុន្តែបើតាមការវែកញែក, កម្ម នេះ មានសម្ភារៈ ២ យ៉ាង គឺ វិញ្ញត្តិសម្ភារៈ ១ ចិត្តសម្ភារៈ ១ ផ្សំគ្នា បានកើតទៅជា កម្ម ៗ

វិញ្ញត្តិ គឺការកម្រើក, បានដល់ការកម្រើកដៃ កម្រើកជើង-ក្បាល-មុខ-មាត់-ខ្លួនប្រាណ ៗ ចិត្ត សំដៅយកចេតនាដែលបង្គាប់បញ្ជាឲ្យដៃ-ជើង-ខ្លួនប្រាណកម្រើក ៗ មានពេលខ្លះ ដៃ-ជើង-ខ្លួនប្រាណយើងកម្រើកដោយឥតមានចិត្តបង្គាប់ទេ ដូចជានៅពេលដេកលក់ជាដើម ដែលពេយស្រពន់ ក៏ផ្លាស់ប្តូរដៃ-ជើង-ខ្លួនប្រាណទៅឥតដឹងខ្លួន ឬដូនជាមមើមមាយគ្រោក-ស្រែកជាដើម ឬក៏ពេលខ្លះទៀត ដូចជាយើងភ្ញាក់ផ្អើល គ្រវាត់គ្រវែងដៃ-ជើងទៅឥតទាំងដឹងខ្លួនក៏មាន ៗ

ការដែលគ្រាន់តែកម្រើកដៃ-ជើង-ខ្លួនប្រាណដូច្នេះ មិនទាន់ឈ្មោះថាជាកម្ម ទេ ពីព្រោះខ្វះសម្ភារៈ ១ គឺ ចិត្តសម្ភារៈ ។

ដូច្នេះ, ដែលហៅថា កម្ម គឺបានដល់ការកម្រើកដៃ-ជើង-ខ្លួនប្រាណ ដែលមានចិត្តចេតនាបង្គាប់ឲ្យកម្រើក ។

តាមយើងយល់ថា កម្ម នេះ ជាពាក្យជ្រៅជ្រះណាស់, ចុះបើគ្រាន់តែកម្រើកខ្លួនប្រាណប៉ុណ្ណឹង ហៅថា កម្ម ដែរ, តើពិតប្រាកដមែនឬ ?

ពិតប្រាកដណាស់, ព្រោះថា ទីងធ្វើអ្វីមួយ បើយើងមិនកម្រើកនោះ តើយើងធ្វើអ្វីកើតដែរឬ? មិនកើតទេ, ទាល់តែកម្រើកដៃ ទើបចាប់អ្វីបាន, កម្រើកជើង ទើបដើរទៅរួច, កម្រើកមាត់ ទើបនិយាយចេញ ។ល។

កម្ម មាន ២ យ៉ាង គឺ កម្មល្អ (បុញ្ញកម្ម)១ កម្មអាក្រក់ (បាបកម្ម)១ ។ កម្មល្អ គឺការកម្រើកខ្លួនប្រាណដោយចិត្តគិតល្អ, កម្មអាក្រក់ គឺការកម្រើកខ្លួនប្រាណ ដោយគំនិតអាក្រក់ ។ យើងឮចាស់ៗ និយាយថា អ្នកណាមួយចង់ទៅវត្តដើម្បីស្ដាប់ទេសន៍ គ្រាន់តែឈានជើងមួយជំហានដើរទៅ ក៏បានបុណ្យមួយអនន្ត, ពីរជំហាន បានពីរអនន្ត ... មួយរយជំហាន បានមួយមួយរយអនន្ត, មួយពាន់ជំហាន បានមួយពាន់អនន្ត ។ល។ មិន

ទាន់តាំងបានស្តាប់ធម៌ផង គ្រាន់តែកម្រើកជើងឈានដើរទៅ ក៏បានបុណ្យទៅហើយ នេះ មិនបញ្ជាក់តែច្បាស់ថា ការកម្រើកចាត់ជា កម្ម ទេឬ? ចំណែក កម្មអាក្រក់ វិញ ក៏ដូចគ្នា, គឺបើយើងមានគំនិតអាក្រក់ ចង់ទៅលួចគេ, គ្រាន់តែកម្រើកជើងមួយជំហានដើរទៅ បានបាបមួយអនន្ត, ពីរជំហាន ពីរអនន្ត ជាលំដាប់ដូចគ្នានឹងបុណ្យដែរ ។

ដូច្នេះ កម្មល្អ និង កម្មអាក្រក់ ទាំងពីរនេះ ត្រូវមានសម្ភារៈផ្សំ ២ យ៉ាង គឺការកម្រើក ១ ចិត្តបង្គាប់បញ្ជា ១ ។ តែបណ្តាសម្ភារៈទាំងពីរនេះ សម្ភារៈទី ២ គឺចិត្តសម្ភារៈ មានអានុភាពខ្លាំងជាង, ពីព្រោះក្នុងពេលខ្លះ មិនចាំបាច់មានការកម្រើកខ្លួនប្រាណទេ កម្រើកត្រឹមតែចិត្តឯកឯងហ្នឹង ក៏ចាត់ជា កម្ម បានដែរ ដែលហៅថា មនោកម្ម, ដូចជាយើងមានគំនិតក្នុងរឿងចង់តែលួច ប្លន់យកទ្រព្យសម្បត្តិ កូនប្រពន្ធគេ, មានគំនិតគិតប្រទូស្តរ៉ាយព្យាបាទគេ, មានគំនិតយោបល់យល់ខុសពីការពិត, គ្រាន់តែគិតប៉ុណ្ណឹង ក៏ចាត់ថាយើងធ្វើកម្មអាក្រក់ជាស្រេច, ហើយបើមានគំនិត ផ្ទុយពីគំនិតខាងលើនេះវិញ ក៏បែរជាឈ្មោះថា យើងធ្វើកម្មល្អវិញដែរ ។

ដូច្នេះ វិញ្ញត្តិ ចែកជា ៣ គឺ កាយវិញ្ញត្តិ កម្រើកកាយ ១ វចីវិញ្ញត្តិ កម្រើកវាចា ១ មនោវិញ្ញត្តិ កម្រើកចិត្ត ១ ។ អ្នកមាន

កាយវិញ្ញត្តិ ឈ្មោះថាធ្វើកាយកម្ម, អ្នកមានវចីវិញ្ញត្តិ ឈ្មោះថាធ្វើវចីកម្ម, អ្នកមានមនោវិញ្ញត្តិ ឈ្មោះថាធ្វើមនោកម្ម, ប៉ុន្តែ ត្រូវចាំឲ្យជាក់ថា កាយវិញ្ញត្តិ និង វចីវិញ្ញត្តិ ទាល់តែមានមនោវិញ្ញត្តិ នៅធ្វើការជាមួយផង ទើបហៅថា កម្ម, បើគ្មានមនោវិញ្ញត្តិ នៅជាមួយទេ (ការកម្រើកឥតដឹងខ្លួន) មិនហៅថាកម្មបានទេ, រីមនោវិញ្ញត្តិ វិញ តែម្នាក់ឯងប៉ុណ្ណោះ ហៅថាកម្ម បាន, មិនចាំបាច់មាន វិញ្ញត្តិ ឯទៀតធ្វើជាមួយគ្នាទេ ។

នេះ ជាសេចក្តីអធិប្បាយដោយសង្ខេបអំពីពាក្យថា កម្ម ដែលអភិណ្ហប្បច្ចវេក្ខណធម៌ប្រាប់ថា "មនុស្សយើង ត្រូវតែមាន" ។ ម្យ៉ាងទៀត ក្នុងអភិណ្ហប្បច្ចវេក្ខណធម៌ លោកចែកឈ្មោះ កម្ម ដល់ទៅ ៥ យ៉ាង គឺ កម្មស្សកោ ១ កម្មទាយាទោ ១ កម្មយោនិ ១ កម្មពន្ធុ ១ កម្មប្បដិសរណោ ១, ប៉ុន្តែ បើពិនិត្យទៅ, ឈ្មោះទាំង ៥ នេះ ក៏គ្រាន់តែជានាមសំដែងឲ្យឃើញ នូវ អានុភាព របស់កម្ម តែមួយប៉ុណ្ណោះ ។ អានុភាពនៃកម្មនោះ ដូច្នេះ —

១— កម្មស្សកោ: មានកម្មជារបស់ខ្លួន ។ សេចក្តីថាតាមធម្មតា, បើអ្នកណាមួយ បានធ្វើកម្មណាមួយហើយ, កម្មនោះឯងជារបស់ជាប់ចំពោះអ្នកធ្វើនោះ ពុំមែនដែលក្លាយទៅជារបស់អ្នកដទៃដែល

ពុំបានធ្វើអំពើនោះឡើយ ។ ប្រៀបដូចជាអ្នកណាមួយជាន់បន្លា, បន្លាត្រូវតែមុតជើងអ្នកដើរជាន់នោះ, វាមិនមែនទៅមុតជើងអ្នកដែលមិនបានជាន់វិញទេ ។ អ្នកណាលូកភ្លើង, អ្នកនោះត្រូវក្តៅរលាក, អ្នកណាស៊ីបាយ, អ្នកនោះត្រូវបានឆ្អែត, ភ្លើងនិងបាយ មិនដែលទៅរលាកឬឆ្អែតដល់មនុស្សអ្នកពុំបានលូក ឬ ពុំបានស៊ីនោះឡើយ យ៉ាងណាមិញ ។ កម្ម នេះក៏ដូច្នោះ គឺអ្នកណាធ្វើ, វាក៏ជារបស់អ្នកនោះឯង ។ មួយវិញទៀត មនុស្សម្នាក់ជាន់បន្លា, មនុស្សម្នាក់ទៀតលូកភ្លើង, បន្លាត្រូវតែមុតជើងមនុស្សដែលជាន់វា, ឯភ្លើងក៏ត្រូវរលាកដៃមនុស្សដែលលូកដែរ បន្លាមិនដែលទៅមុតជើងមនុស្សអ្នកលូកភ្លើង ឬភ្លើងទៅរលាកដៃមនុស្សអ្នកជាន់បន្លាវិញឡើយ យ៉ាងណាមិញ ។ កម្ម ក៏មិនដែលដូរគ្នាឲ្យទៅជារបស់អ្នកដទៃ ឬប្តូរពីរបស់អ្នកដទៃ មកជារបស់ខ្លួនបាន ក៏យ៉ាងនោះដែរ ។

៤– កម្មទាយាទ: មានកម្មជាមត៌ក ។ មត៌ករបស់ឪពុកម្តាយត្រូវតែធ្លាក់ទៅលើកូន, អ្នកដទៃក្រៅពីកូន គ្មានសិទ្ធិនឹងទៅទាមទារយកមត៌កនោះបានឡើយ យ៉ាងណាមិញ, កម្ម ណា ដែលយើងធ្វើហើយ, កម្ម នោះ ត្រូវផ្តល់ផលសម្រាប់តែយើង, អ្នកដទៃពុំអាចមានសិទ្ធិនឹងមកទាមទារ ផលកម្ម ដែលយើងធ្វើនោះបានឡើយ ក៏យ៉ាងនោះដែរ ។ ចំពោះអ្នកខ្លះដែលថា ខំធ្វើល្អណាស់ ស្រាប់តែ

បានគាប់ប្រសើរទៅអ្នកឥតធ្វើទៅវិញនោះ, សូមកុំឲ្យយល់អស់សង្ឃឹម ដូច្នោះ, ពីព្រោះការគាប់ប្រសើរដែលកើតឡើងដល់អ្នកដទៃនោះ វាមិនមែនជា ផលកម្ម របស់យើងផ្តល់ទៅឲ្យគេទេ, តាមពិត គឺជាផលបោកប្រាស ឬជាផលនៃការកន្តប្រឡំរបស់គេទេ, ឯយើង គង់តែពេលណាមួយ នឹងបានទទួលនូវ ផលកម្ម របស់យើង ពិតជាពុំខានសោះឡើយ ។

៣– កម្មយោនិ មានកម្មជាអ្នកឲ្យកំណើត ។ មែនពិត, មនុស្សសត្វ ព្រោះតែមាន កម្ម ទើបត្រូវមានកំណើតតទៅទៀត, បើគ្មាន កម្ម ទេ ក៏លែងកើតតទៅទៀតដែរ ។ ព្រះអរហន្ត លោកលះអស់កម្មហើយ (បុញ្ញបាបប្បហីនៈ) បានជាចូលនិព្វាន ។ ដូច្នេះ បានជាលោកប្រាប់ថា យើងមានកម្មជាកំណើត ។

កម្មពន្ធុ មានកម្មជាផៅពង្ស ។ មនុស្សសត្វ តែងមានម៉ែឪ បងប្អូន មីងមា . . . ជាផៅពង្សពិតមែនហើយ, តែផៅពង្សនេះ ពុំបានកៀកកិត ឬស្និតស្នេហ៍ជានិច្ចកាលដូច កម្ម ដែលខ្លួនបានធ្វើហើយនោះទេ ។ ម្យ៉ាងទៀត ផៅពង្សរបស់មនុស្សសត្វ ខ្លះជាអ្នកឧត្តមខ្ពង់ខ្ពស់, ខ្លះខ្សត់ខ្សោយ, ខ្លះប្រកបដោយសុខភាព, ខ្លះសម្បូរដោយជម្ងឺតំកាត់, ខ្លះមានប្រាជ្ញាច្រើន, ខ្លះអាប់អន់ប្រាជ្ញា ។ល។

ដូច្នេះ បើយើងមានផៅពង្សល្អ, យើងក៏បានទទួលការឧត្តុង្គឧត្តម

បើយើងមានផៅពង្សអាក្រក់ ក៏ត្រូវបានទទួលការថោកទាបអាប់ឱនដែរ យ៉ាងណាមិញ, យើងជាអ្នកមាន កម្មៗ នោះល្អ ឬអាក្រក់យ៉ាងណា ៗ យើងបានភាពឧត្តុង្គឧត្តមថ្លៃថ្លា ឬ អាប់ឱនទន់ខ្សោយនោះៗ ដូចគ្នា ។

៥– កម្មប្បដិសរណា: យើងមានកម្មជាទីពឹងពំនាក់ ។ សេចក្តីនេះ ជាការងាយដឹងយល់ណាស់ ព្រោះការអ្វីក៏ដោយ បើយើងមិនធ្វើ ក៏ពុំកើតការនោះដែរ, ការធ្វើហ្នឹងឯង ដែលហៅថា កម្ម ព្រោះវាត្រូវកម្រើកកាយ - វាចានិងចិត្តជាប្រថម ដូចជា ចង់ដើរ ទាល់តែកម្រើកជើងឈានទៅ, ចង់ចាប់ ទាល់តែកម្រើកដៃឡើងជាដើម ។ ប៉ុន្តែ មានការពិសេសហើយសំខាន់ជាងនេះទៅទៀត គឺកម្មនេះ ជាយានយ៉ាងចាំបាច់បំផុតរបស់មនុស្សសត្វ សម្រាប់ឲ្យធ្វើដំណើរផ្លាស់ប្តូរសភាពទូទៅគឺ កម្ម អាចដឹកនាំមនុស្សឲ្យល្អនិងអាក្រក់, ឲ្យសុខឲ្យទុក្ខ, ឲ្យខ្ពស់ឲ្យទាប . . . ។ មនុស្សសត្វ កាលបើមាន កម្ម ជាយានហើយ តែងឆ្លងកាត់ពីទីមួយទៅទីមួយតាមយាន គឺ កម្មនោះ ៗ, កម្មអាក្រក់ ដឹកនាំមនុស្សសត្វពីភាពខ្ពង់ខ្ពស់ទៅថោកទាប, ពីមានទៅក្រ, ពីល្អទៅអាក្រក់, ពីសភាពជាមនុស្សទៅជាសត្វតិរច្ឆាន, ជាប្រេត, ជាអសុរកាយ, ជានរក ៗ ខាង កម្មល្អ វិញ ដឹកនាំមនុស្សសត្វ ពីថោកទាបទៅខ្ពង់ខ្ពស់, ពីក្រទៅមាន, ពីអាក្រក់ទៅល្អ, ពីភាពជាមនុស្សទៅភាពជាទេវតា ជាព្រហ្ម រហូតឲ្យមនុស្សឆ្លងទៅដល់

ព្រះ និព្វាន ជាអាសានបានទៀត ។ បានសេចក្តីថា មនុស្សចង់ប្រែ
ភាពអ្វី ៗ ចង់សម្រេចអ្វី ៗ ក្នុងលោកនេះ សុទ្ធតែត្រូវពឹងពាក់ទៅលើ
កាម្មរបស់ខ្លួន ទាំងអស់, ជាពិសេសទៅទៀត, ដើម្បីឲ្យបានដល់
ព្រះ និព្វាន ក៏ត្រូវអាស្រ័យ កាម្ម នេះដែរ ។

ដូច្នេះ អានុភាពរបស់កម្មទាំង ៤ យ៉ាងនេះ ជាអានុភាពខ្លាំងក្លា
ណាស់ រកអានុភាពដទៃមកជាគូប្រៀបពុំបានឡើយ ពោះជាអានុភាព
នៃមនុស្សវិសេស, អានុភាពនៃទេវតា ឥន្ទ្រ ព្រហ្ម យម យក្ស អារក្ស
អ្នកតា ឬអានុភាពនៃព្រះពុទ្ធបរមគ្រូនោះក៏ដោយ ។ ព្រោះថា អានុ-
ភាពនៃឥទ្ធិឫទ្ធិផ្សេង ៗ ក្នុងលោក ជាអានុភាពផ្សាយចេញបានតែមួយ
ពេលមួយខណៈប៉ុណ្ណោះ ហើយមិនអាចបំបែរអានុភាពនៃកម្មនេះបាន
ផង, ឯអានុភាពកម្មទាំង ៤ នេះវិញ ជាអានុភាពផ្សាយចេញចំពោះអ្នក
ធ្វើគ្រប់ពេលគ្រប់ខណៈ តាំងពីលោកនេះ ទៅដល់លោកនាយ ហើយ
ថែមទាំងអាចគ្រប់សង្កត់បំបែរនូវអានុភាព នៃឥទ្ធិឫទ្ធិទួទៅ ឲ្យងាកប្រែ
ទៅតាមខ្លួនបានទៀតផង ។

## ផលនៃអភិណ្ហប្បច្ចវេក្ខណធម៌

ពាក្យថា អភិណ្ហប្បច្ចវេក្ខណធម៌ ប្រែថា ធម៌ដែលត្រូវគិតទឹក
ពិចារណាឲ្យញឹកញយ ។ ធម៌នេះ គឺព្រះពុទ្ធបរមគ្រូទ្រង់សំដែងទុក

ដើម្បីបង្កើតចិត្តក្លាហានចំពោះហេតុភ័យដ៏ចាំបាច់ របស់មនុស្សសត្វ ។ ព្រោះថា ពួកមនុស្សសត្វ ទោះបីដឹងថា ហេតុភ័យណា ១ ដែលចៀសមិនផុតក៏ដោយ, ក៏នៅតែតក់ស្លុត ខ្វះចិត្តក្លាហាន ចំពោះហេតុភ័យនោះ ១ ជាធម្មតា ។ ដូច្នេះ កាលបើមនុស្ស នឹកគិតធម៌ទាំង ៥ គឺ ជរា ការចាស់គ្រាំគ្រា, ព្យាធិ ជម្ងឺតំកាត់, មរណៈ ការស្លាប់, នានាភាវវិនាភាវៈ ការព្រាត់ប្រាសនិរាស និង កម្ម អំពើដែលយើងធ្វើ នេះឲ្យញឹកញាប់ទៅ :

ចំពោះមនុស្សដែលត្រូវជួបនឹងធម៌ទាំង ៥ នេះហើយ រមែងបានផលយ៉ាងឧត្តុង្គឧត្តម គឺចិត្តក្លាហាន ចំពោះហេតុភ័យទាំង ៥ នោះ គឺ មិនភ័យព្រួយចំពោះការចាស់គ្រាំគ្រា, មិនរន្ធត់ចិត្តព្រោះជម្ងឺតំកាត់, មិនតក់ស្លុតចំពោះការស្លាប់, មិនខ្សឹកខ្សួលព្រោះការព្រាត់ប្រាសនិរាស ហើយនិងមិនតូចចិត្តចំពោះផលកម្ម ដែលខ្លួនធ្វើហើយ ។ កាលបើចិត្តមនុស្ស មានសេចក្តីក្លាហានដូច្នេះ មនុស្សនឹងមិនរញ្ញក ហើយអាចនៅតែបំពេញករណីយកិច្ចរបស់ខ្លួនយ៉ាងតស៊ូប្តូរផ្តាច់ជាធម្មតា ។

ចំពោះអ្នកដែលមិនទាន់ត្រូវធម៌ទាំង ៥ នេះ ចេញមុខមកយាយី, រមែងបានផលយ៉ាងប្រសើរ គឺមិនហ៊ានចណ្តែតបណ្តោយឲ្យពេលវេលាកន្លងហួសទៅឥតអំពើ, ខំប្រឹងសម្រឹតសម្រាំងធ្វើតែកម្មដ៏ល្អថ្លៃថ្លា ដើម្បីជាយាន

ទៅកាន់ទីខ្ពស់ប្រសើរ, ជាពិសេស ដើម្បីជាយានជូនឆ្លងវដ្តសង្សារ ទៅកាន់ត្រើយនិព្វាន, កុំឲ្យការចាស់គ្រាំគ្រា, ជម្ងឺតំកាត់, ការស្លាប់, ការព្រាត់ប្រាសនិពសនេះ បេញមុខមកប្រហាររូបកាយ ជាមុនទាន់ឡើយ ។

កាលបើឃើញភ័យ ពីចម្ងាយ
ត្រូវគេចឲ្យឆ្ងាយ កុំបងយល់
តែបើភ័យភិត មកជិតដល់
ត្រូវតស៊ូទល់ ឲ្យក្លាហាន ។
– ការពារទុកមុន ជាគុណទ្វេ
ចាំកែជាក្រោយ បានដោយស្មាន
អ្នកប្រាជ្ញលោកប្រាប់ ជនគ្រប់ប្រាណ
ថាត្រូវឲ្យមាន កិច្ចការពារ ។



សម្តេចព្រះពោធិវង្ស ហួត-តាត

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មង់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ក.

# ជីវប្រវត្តិ

នៃ

# សម្ដេចព្រះពោធិវង្ស ហួត-តាត

លោក ជា-ទន់ សាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត រៀបរៀង

*សម្ដេចព្រះពោធិវង្ស មានទិន្ននាម គឺព្រះនាមដែលមាតាបិតាឲ្យថា ហួត-តាត ។ ព្រះមហាថេរអង្គនេះ កើតនៅថ្ងៃអាទិត្យ ១៥ កើត ខែបុស្ស ឆ្នាំរោងចត្វាស័ក ពុទ្ធសករាជ ២៤៣៤ គឺក្នុងគ្រិស្តសករាជ ១៨៩១ នៅភូមិផ្សារឧដុង្គ ឃុំវាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។ បិតានៃព្រះថេរៈអង្គនេះឈ្មោះ ហុកសេង ហៅ ហួត, មាតាឈ្មោះ ង៉ែត ។ សម្ដេចមានបងប្អូន ៤ នាក់ (រួមទាំងអង្គសម្ដេចផង) គឺទី ១- អ្នកស្រីស៊ុន, ទី២- អ្នកស្រីហួយ, ទី ៣- សម្ដេច (ហួត-តាត), ទី៤- លោក ហួត-គ្រុយ ។*

*ក្នុងឆ្នាំ ១៨៩៨ គឺក្នុងកាលដែលសម្ដេចមានអាយុ ៧ ឆ្នាំ, មាតាបិតា*

បាននាំកុមារ តាត ទៅឲ្យរៀនអក្សរសាស្ត្រជាតិ និងលេខនព្វន្តគុណហារ ជាអាទិ ក្នុងសំណាក់លោកគ្រូ ព្រះធម្មឃោសាចារ្យ ព្រះនាម មាស គង់នៅវត្តប្រាង្គ ។ លោកគ្រូព្រះធម្មឃោសាចារ្យ មាស ស្រឡាញ់ពេញចិត្ត អានកុមារ តាត ណាស់ ព្រោះកុមារនេះ ជាអ្នកមានបញ្ញា, ខ្សោហ៍ធ្វើការ, មានកិរិយាមារយាទរមទមប្លែកពីក្មេងដទៃទៀត ។ មិនយូរប៉ុន្មាន កុមារ តាត បានចេះអាន-សរសេរអក្សរសាស្ត្រជាតិ យ៉ាងពិតប្រាកដ ដែលគេសន្មតថាប្រើការបានក្នុងសម័យនោះ ។ លុះដល់មកក្នុងឆ្នាំ ១៩០៤, កុមារ ហួត-តាត មានវ័យវឌ្ឍនាការចម្រើនបាន ១៣ ឆ្នាំ មានគំនិតគិតចង់បួសជាសាមណេរ ដើម្បីបន្តការសិក្សាឲ្យបានជ្រៅជ្រះតទៅទៀត ។ ពេលនោះ កុមារ តាត បានសូមអនុញ្ញាត ពីមាតាបិតាចូលសូមបព្វជ្ជា ក្នុងសំណាក់លោកគ្រូព្រះធម្មឃោសាចារ្យ មាស នៅវត្តប្រាង្គនោះឯង ។

សាមណេរ ហួត-តាត, ក្រោយដែលបានបព្វជ្ជាហើយ, បានសិក្សារៀនសូត្រធម្មវិន័យបំពេញកិច្ចវត្ត ដែលហៅថា ខបដ្ឋាយវត្ត ក្នុងឋានៈនៃខ្លួនជាសទ្ធិវិហារិក បានត្រឹមតែមួយវស្សាប៉ុណ្ណោះ, លោកគ្រូព្រះធម្មឃោសាចារ្យ មាស បានទទួលអនិច្ចធម្មទៅដោយជរាពាធ ។ ដោយក័ព្ទសំណាងល្អរបស់សាមណេរ តាត, លោកគ្រូធម្មឃោសាចារ្យ មាស មានព្រះថេរៈមួយអង្គព្រះនាម ស្បូវ ដែលត្រូវជាក្មួយរបស់លោក ដែលពេលនោះ លោកគង់នៅក្នុងវត្តខណ្ឌាលោម ក្រុងភ្នំពេញ ។ ព្រះថេរៈ

ព្រះនាម សួរ មានសមណសក្តិជាព្រះសិរីសម្មតិវង្ស ហើយតមក លោក បានឡើងឋានន្តរស័ក្តិជា ព្រះធម្មលិខិត ។ ព្រះថេរៈអង្គនេះ តែងនិមន្ត ទៅមកកាន់វត្តប្រាង្គជារឿយ ៗ ក្នុងកាលដែលលោកគ្រូព្រះធម្មឃោសា-ចារ្យ មាស គង់ព្រះជន្មនៅឡើយ ។ ថ្ងៃមួយ លោកគ្រូព្រះធម្មឃោ-សាចារ្យ មាស មានថេរដីកាទៅកាន់លោកគ្រូព្រះធម្មលិខិត សួរ កាល ឋិតនៅក្នុងឋានន្តរស័ក្តិជា ព្រះសិរីសម្មតិវង្ស នៅឡើយថា «ឥឡូវចែនចាស់ ណាស់ហើយ, បើអំណឹះតពីចែនទៅ សូមយកនេន តាត នេះ ឲ្យទៅ នៅរៀនសូត្រនឹងគេឯទីក្រុងភ្នំពេញផង ត្បិតនេននេះ មានបញ្ញាណាស់, ចែនប្រមើលមើលទៅ នេននេះ ប្រហែលជានឹងរៀនព្រះត្រៃបិដកចេះ ហើយអំណឹះតទៅ នឹងបានជាអ្នកប្រាជ្ញពជបណ្ឌិតពុំខានឡើយ» ។

កាលក្រោយដែលលោកគ្រូ ព្រះធម្មឃោសាចារ្យ មាស ទទួល អនិច្ចធម្មទៅ, សាមណេរ តាត ក៏បានទៅនៅរៀនឯក្រុងភ្នំពេញ ក្នុង សំណាក់លោកគ្រូព្រះធម្មលិខិត សួរ ដែលគង់នៅក្នុងវត្តឧណ្ណាលោម ក្នុងកាលដែលលោកមានសមណសក្តិជា ព្រះសិរីសម្មតិវង្ស នៅឡើយ ។

សាមណេរ ហួត-តាត បានរៀនសូត្របម្រើនតាមលំដាប់ ថ្វី បើនៅសម័យនោះមិនសូវមានអ្នកប្រាជ្ញ ដែលចេះដឹងព្រះត្រៃបិដកច្រើន ហើយមិនមានសាលារៀន និងរបៀបបង្រៀនដូចសព្វថ្ងៃនេះក៏ដោយ ៗ ដោយសេចក្តីព្យាយាមមិនដាច់ និងដោយបញ្ញាមុះមុតរបស់ខ្លួន, សាម-

ណេរ ហ្លួត-តាត បានរៀនក្នុងសំណាក់លោកគ្រូអាចារ្យណា សុខុសឹន តែបានទទួលនូវការសរសើរពីគ្រូអាចារ្យនោះជាដរាប ។ ព្រោះគេជាព្រះគុណព្រះធម្មលិខិត ស្នួរ គ្រប់គ្រងទំនុកបម្រុងសាមណេរ តាត មិនបានយូរប៉ុន្មាន, ដោយជរាពាធបៀតបៀន, ក៏ទទួលអនិច្ចធម្មទៅទៀត ។ ឯសាមណេរ តាត ក៏អស់ពំនឹងពំនាក់ដូចមុនម្ដងទៀត ។ ប៉ុន្តែ ម្ដងនេះ សាមណេរ តាត បានអាយុ ១៧ ឆ្នាំ មានចិត្តស៊ូត់តញ្ញាក បានជំរះចិត្តប្រឹងរៀនតទៅទៀត គ្រាតែដល់អាយុ ១៩ ឆ្នាំ ។ ពេលនោះ សាមណេរ តាត មានការចេះដឹងព្រះត្រៃបិដកល្មម អាចធ្វើជាអាចារ្យបង្រៀនបាន ។ លោកបានធ្វើជាអាចារ្យបង្រៀនព្រះត្រៃបិដក ចំពោះភិក្ខុសាមណេរជាច្រើន ។ សាមណេរ តាត បង្រៀនព្រះត្រៃបិដកដល់ភិក្ខុសាមណេរទាំងឡាយផង ទៀតនុកាសរៀនខ្លួនឯងតទៅទៀតផង ។ តមក កិត្តិសព្ទរបស់លោក បានល្បីរន្ទឺទៅឆ្ងាយ រហូតដល់ពតិមាននេះ បានជ្រាបដល់សម្ដេចព្រះមហាសង្ឃរាជព្រះនាម ទៀង ។ សម្ដេចព្រះមហាសង្ឃរាជទ្រង់មានព្រះរាជហឫទ័យ សន្ដោសប្រោសប្រណី ចំពោះសាមណេរ ហ្លួត-តាត ជាច្រើន ។

នៅឆ្នាំ ១៩១២ សាមណេរ តាត មានអាយុគ្រប់ ២០ ឆ្នាំបរិបូណ៌ ហើយក៏ពុំងាប់ចិត្តក្នុងការរៀនព្រះត្រៃបិដកយ៉ាងខ្លាំងដោយកម្លាំងសទ្ធា-ចិត្ត ដ៏បរិសុទ្ធពិតក្នុងពុទ្ធសាសនា ក៏បានចូលទៅទូលសូមឧបសម្បទា

ជាភិក្ខុគង់ពន្ធសីមាវត្តឧណ្ណាលោម ក្រុងភ្នំពេញ ក្នុងសំណាក់សម្តេចព្រះមហាសង្ឃរាជព្រះនាម ទៀង ជាព្រះឧបជ្ឈាយ៍ ដោយមានលោកគ្រូព្រះវិនតេព្រះនាម ចន្ទ ជាកម្មវាចា និងលោកគ្រូព្រះមហាវិមលធម្មព្រះនាម គង់(១) ជាអនុសាវនាចារ្យ ដែលហៅតាមលោកវោហារថា លោកគ្រូសូត្រស្តាំ-ឆ្វេង ។ លុះសម្រេចកិច្ចឧបសម្បទាដោយញត្តិចតុត្ថកម្មវាចាជាភិក្ខុភាពហើយ, ភិក្ខុ ហួត តាត បានទទួលនូវបព្វជិតនាម ដែលព្រះឧបជ្ឈាយ៍ប្រទានថា វជិរប្បញ្ញោ ដែលមានន័យថា « ភិក្ខុមានបញ្ញាដូចជាពេជ្រ » ។

ចាប់តាំងពីឧបសម្បទកាលរៀងមក, ភិក្ខុ ហួត-តាត (វជិរប្បញ្ញោ) បានខំប្រឹងប្រែងរៀនសូត្ររឹងរឹតតែទ្វេឡើងទៀត ពុំមានធ្វេសប្រហែសឡើយ ដែលជាហេតុនាំឲ្យគ្រូអាចារ្យអ្នកបង្ហាត់បង្ហាញ ខានស្ងើចសរសើរពុំបាន ។ នៅថ្ងៃទី ២២ នៃខែកក្កដា ឆ្នាំ ១៩១២, ដោយហេតុថា ភិក្ខុ ហួត-តាត ជាអ្នកព្យាយាមឧស្សាហ៍ និង មានកិរិយាមារយាទរមទម សមឋានៈជាភិក្ខុអ្នកទ្រទ្រង់ធម្មវិន័យក្នុងព្រះសាសនា, សម្តេចព្រះមហាសង្ឃរាជា ទ្រង់ក៏បានប្រោសព្រះរាជទានឋានន្តរសក្តិជា ព្រះគ្រូ

---

១ ព្រះមហាវិមលធម្ម គង់ បានជាចៅអធិការវត្តឧណ្ណាលោម មុនសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ ព្រះនាម ជួន-ណាត ចៅអធិការវត្តឧណ្ណាលោមសព្វថ្ងៃនេះ ។

សង្ឃវិជ្ជា[១]ទីឋានានុក្រម ជាព្រះគ្រូរបស់សម្តេចព្រះមហាសង្ឃរាជ ក្នុងពេលដែលលោកបានឧបសម្បទាហើយ បានត្រឹមតែ ១៥ ថ្ងៃប៉ុណ្ណោះ ។ នៅឆ្នាំ ១៩១៣ ព្រះគ្រូសង្ឃវិជ្ជា តាត បានសូមចូលប្រឡង ប្រែបាលីផ្ទាល់មាត់ ក្នុងមហាសន្និបាតនៃព្រះមហាថេរទាំងឡាយ ដែលជាមេប្រយោគ ហៅថា ប្រឡងដេញប្រយោគ ដែលបានធ្វើនៅព្រះវិហារព្រះកែវមរកតក្រុងភ្នំពេញ ។ ព្រះគ្រូសង្ឃវិជ្ជា បានប្រឡងជាប់ជាមហា៤ប្រយោគ ដែលជាប្រយោគផុតថ្នាក់ក្នុងសម័យនោះ ។ ( នៅកម្ពុជរដ្ឋ នាសម័យនោះ ការប្រឡងប្រដែង គេធ្វើតែដោយវិធីប្រឡងដេញប្រយោគផ្ទាល់មាត់ ត្រឹមតែ ៤ ប្រយោគប៉ុណ្ណោះ ដែលទុកដូចជាការប្រឡងយកសញ្ញាប័ត្រពុទ្ធិកសិក្សា ក្នុងសម័យបច្ចុប្បន្ននេះ ។ លោកអ្នករៀនព្រះត្រៃបិដកក្នុងសម័យនោះ កាលណាលោកបានប្រឡងដេញប្រយោគ ជាប់ ៤ ប្រយោគហើយ លោកបានទទួលឋានន្តរជាមហា ៤ ប្រយោគ ឬ ហៅដោយខ្លីថា មហា ) ។ ព្រះគ្រូសង្ឃវិជ្ជា ហ្លួត-តាត បានប្រឡងជាប់ជាមហា ៤ ប្រយោគ ដែលនាំឲ្យមហាសន្និបាតនៃមន្ត្រីសង្ឃ និងគ្រូអាចារ្យទាំងឡាយ ស្ញើចសរសើរគ្រប់គ្នា ។

---

១ ព្រះគ្រូសង្ឃវិជ្ជា ជាគូគ្នានឹងព្រះគ្រូសង្ឃសត្ថា ជាសមណសក្តិទីឋានានុក្រម របស់សម្តេចព្រះសង្ឃរាជព្រះនាម ទៀង ។ ក្រោយពេលដែលសម្តេចព្រះសង្ឃរាជ ព្រះរាជទានទីព្រះគ្រូសង្ឃវិជ្ជាដល់ភិក្ខុ ហ្លួត-តាត ១៥ ថ្ងៃ, សម្តេចព្រះមហាសង្ឃរាជ ក៏បានព្រះរាជទានងារព្រះគ្រូសង្ឃសត្ថា ដល់ភិក្ខុ ជួន-ណាត ( ជោតញ្ញាណោ ) សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ វត្តឧណ្ណាលោមសព្វថ្ងៃនេះ ។

ព្រះគ្រូសង្ឃវិជ្ជា ហួត-តាត ក្រោយដែលបានសម្រេចក្នុងការសិក្សាព្រះត្រៃបិដកហើយ, បានខំប្រឹងអានគម្ពីរដីកាសាស្ត្រាបាលីក្បួនច្បាប់ក្រឹត្យក្រម ខាងពុទ្ធសាសនាផ្សេង ៗ ផ្ទាល់ខ្លួនផង បង្ហាត់បង្រៀនពួកសមណសិស្ស ដែលចូលមកសុំរៀនផង ។ ក្រៅពីនេះ ព្រះគ្រូសង្ឃវិជ្ជា តាត មានការៈដ៏ធំមួយទៀត ក្នុងការប្រកាសពុទ្ធសាសនានៅតំបន់ខ្លះនៃប្រទេសកម្ពុជា ក្នុងឋានៈនៃលោកជា ព្រះគ្រូសង្ឃវិជ្ជា ។ តមក, ដោយលោកមានការចេះដឹង និងមានគេរាប់អានច្រើន, ព្រះគ្រូសង្ឃវិជ្ជា តាត ក៏បានទៅជាព្រះថេរៈមួយអង្គ មានកិត្តិស័ព្ទលេចឮខ្ទរខ្ទាយទៅ ក្នុងកម្ពុជរដ្ឋទាំងមូល ។

នៅឆ្នាំ ១៩១៩, ព្រះគ្រូសង្ឃវិជ្ជា តាត បានត្រូវរាជការតែងតាំងជាក្រុមជំនុំរៀបចំបង្កើតវចនានុក្រមខ្មែរ ដើម្បីធ្វើឲ្យភាសានេះមានរបៀបរៀបរយប្រសើរឡើង ។

នៅឆ្នាំ ១៩២២ រាជការបានចាត់បញ្ជូនព្រះគ្រូសង្ឃវិជ្ជា តាត ឲ្យទៅរៀនវិជ្ជាសំស្ក្រឹត, អក្សរថ្មខ្មែរបុរាណ និងប្រវត្តិនៃពុទ្ធសាសនានៅបរទេស ក្នុងសំណាក់លោក ល្វី ហ្វីណូត៍ ចាងហ្វាងសាលាបារាំងសែសនៅអាស៊ីភាគអាគ្នេយ៍ ដែលស្ថិតនៅនាក្រុងហាណូយ ជាមួយនឹងសម្តេចព្រះសង្ឃរាជថ្នាក់ទី ១ វត្តឧណ្ណាលោម ដែលកាលនោះព្រះអង្គទ្រង់នៅជាព្រះគ្រូសង្ឃសត្ថានៅឡើយ ។

នៅឆ្នាំ ១៩២៤, ក្រោយដែលលោកបានវិលត្រឡប់ពីក្រុងហាណូយមកកាន់កម្ពុជាវិញ, ព្រះគ្រូសង្ឃវិជ្ជា តាត បានត្រូវរាជការតែងតាំងជាសាស្ត្រាចារ្យបង្រៀនភាសាសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់ ដែលសព្វថ្ងៃបានត្រូវផ្លាស់ឈ្មោះទៅជា ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

ក្នុងឆ្នាំ ១៩២៩, រាជការ បានតែងតាំងព្រះគ្រូសង្ឃវិជ្ជា តាត ជាសមាជិកពិនិត្យវិញ្ញាសានៃសៀវភៅតាំងឡាយ ដែលគ្រឹះស្ថាននោះត្រូវបោះពុម្ពផ្សាយ ។ ក្នុងឆ្នាំបន្ទាប់បន្តមកទៀត, ព្រះគ្រូសង្ឃវិជ្ជា តាត បានទៅជាព្រះថេរៈមានធុរៈយ៉ាងច្រើន ក្នុងពុទ្ធសាសនា និងក្នុងប្រទេសដូចជាលោកបានត្រូវតែងតាំងជាសមាជិក នៃគណៈកម្មការពិនិត្យសម្រេចហើយនិងបោះពុម្ពផ្សាយ នូវវចនានុក្រមខ្មែរ,–នៃគណៈកម្មការប្រែព្រះត្រៃបិដកពីភាសាបាលីមកជាភាសាខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ រួមនិងមុខការបង្រៀនសំស្ក្រឹត នៅសាលាបាលីជាន់ខ្ពស់ផង ។

នៅឆ្នាំ ១៩២៨ ព្រះតេជព្រះគុណព្រះគ្រូសង្ឃវិជ្ជា តាត បានត្រូវរាជការចាត់ឲ្យធ្វើបរិវត្តគមនាគមន៍ក្នុងដែនកូសាំងស៊ីន ជាមួយនឹងលោកអធិបតីនៃព្រះរាជបណ្ណាល័យកម្ពុជា ដើម្បីបំពេញបេសកកម្ម ខាងការពន្យល់ដល់ព្រះសង្ឃនិងគ្រហស្ថជាតិខ្មែរ ឲ្យពេញចិត្តក្នុងការសិក្សាអក្សរសាស្ត្រជាតិខ្មែរជាអាទិ៍, លុះតមកទៀត ព្រះតេជព្រះគុណ បានត្រូវរាជការចាត់ឲ្យធ្វើដំណើរទៅដែនកូសាំងស៊ីនម្ដងទៀត ជាព្រះរាជតំណាង

យ៉ាងខ្ពង់ខ្ពស់ នៃព្រះករុណាជាម្ចាស់ជីវិតលើត្បូង ជាមួយនឹងលោកអធិបតី នៃប្រទេសឥណ្ឌូចិនបារាំងសែស ដើម្បីប្រកាសពន្យល់ដល់បណ្ដារាស្ត្រ អំពីការបង្កើតពុទ្ធសាសនបណ្ឌិត្យ និងប្រយោជន៍ នៃពុទ្ធសាសនបណ្ឌិត្យនេះ ។

នៅឆ្នាំ ១៩៣១, ព្រះករុណាព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ មុនីវង្ស ទ្រង់បានព្រះរាជទានសមណសក្ដិដល់ព្រះគ្រូសង្ឃវិជ្ជា ហ.តាត ឲ្យឡើងទីជារាជាគណៈ មានឋានន្តរសក្ដិជាព្រះវិសុទ្ធិវង្ស រាជាគណៈកិត្តិយស, ហើយក្នុងឆ្នាំនោះ រាជការបានបញ្ជូន ព្រះតេជព្រះគុណ ព្រះវិសុទ្ធិវង្ស ហ.តាត ឲ្យនិមន្តទៅកាន់ក្រុងវៀងចន្ទន៍ និងហ្លួងព្រះបាងនៃប្រទេសលាវ ជាមួយនឹងសម្ដេចព្រះសង្ឃរាជថ្នាក់ទី ១ ដែលកាលនោះ ព្រះអង្គទ្រង់នៅក្នុងព្រះឋានន្តរសក្ដិជា ព្រះសាសនសោភណ នៅឡើយ ។ ឯគោលបំណងនៃដំណើរនោះ គឺ ការនិមន្តទៅជាតំណាងនៃប្រទេសកម្ពុជា ក្នុងឱកាសនៃមហាសន្និបាត នៃពិធីបុណ្យឆ្លងពុទ្ធ-សាសនបណ្ឌិត្យ នៃប្រទេសលាវផង នៃការប្រជុំ ដើម្បីនឹងបង្កើតនូវសាលាបាលីជាន់ខ្ពស់ ក្នុងប្រទេសលាវផង ។

នៅឆ្នាំ ១៩៣៥ ព្រះថេរៈអង្គនេះ បានត្រូវរាជការចាត់ ឲ្យទៅបង្រៀនភាសាសំស្ក្រឹត និង ភាសាខ្មែរ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រុងភ្នំពេញ ។ ក្នុងឆ្នាំដដែលនោះ លោកបានទទួលមុខការថ្មីមួយទៀត ជាអធិបតីរង នៃក្រុមជំនុំប្រែព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ។

ចាប់តាំងពីឆ្នាំ ១៩៤០ រៀងមក, ជីវប្រវត្តិនៃសម្តេចព្រះពោធិវង្ស ហួត-តាត មិនសូវកំបាំងនឹងចក្ខុ នៃលោកអ្នកអានទាំងឡាយឡើយ, ប៉ុន្តែអ្នកនិពន្ធ សូមដកស្រង់យកតែគោល ៗ ខ្លះ មកជូនជាពត៌មានដូចតទៅនេះ :

ក្នុងឆ្នាំ ១៩៤០, ព្រះតេជព្រះគុណព្រះវិសុទ្ធិវង្ស ហួត-តាត បានឡើងសមណសក្តិជា ព្រះសាក្យវង្ស ទីកជាគណៈសម្រាប់ត្រី ។

ក្នុងឆ្នាំ ១៩៤៤, ព្រះថេរៈអង្គនេះ បានទទួលងារ ជាគ្រូសូត្រស្តាំនៃវត្តឧណ្ណាលោម ។

ក្នុងឆ្នាំ ១៩៤៥, ព្រះមហាថេរបាន ឡើងព្រះសមណសក្តិជា ព្រះមហាវិមលធម្ម ទីរឿនហ្វូង ។ ក្នុងពេលជាមួយគ្នានោះ លោកបានត្រូវតែងតាំងជាអធិបតី នៃថេរសភាជាន់ខ្ពស់ ដែលលោកធ្លាប់បានធ្វើជាសមាជិក ចំនួនច្រើនឆ្នាំមកហើយ ។

ក្នុងឆ្នាំ ១៩៤៧, ព្រះតេជព្រះគុណព្រះមហាវិមលធម្ម ហួត-តាត បានត្រូវបានតាំងជាសមាជិកនៃគណៈកម្មការវប្បធម៌ ផ្នែកអក្សរ "គ្រៈ" ហើយខាងក្រោយមក លោកបានធ្វើជាអនុប្រធាន នៃគណៈកម្មការវប្បធម៌នោះ ជំនួសសម្តេចព្រះសង្ឃរាជថ្នាក់ទី១ (ជ.ណា.) ដែលបានលាឈប់ ក្នុងពេលដែលព្រះអង្គ មានព្រះរាជករណីយកិច្ចច្រើនពេក ។

នៅថ្ងៃទី ២៦ ឧសភា ១៩៤៨, ព្រះតេជព្រះគុណ ព្រះ

មហាវិមលធម្ម ហ.តាត បានឡើងសមណសក្តិជាទី ព្រះពោធិវង្ស ក្នុងគណៈសំរាប់ឯក ។

នៅក្នុងខែសីហា ១៩៤៨, ព្រះតេជព្រះគុណព្រះពោធិវង្ស ហ.តាត បានត្រូវតែងតាំង ជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ និង ជាអធិបតី នៃក្រុមជំនុំប្រែព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ។

នៅថ្ងៃទី ២៥ វិច្ឆិកា ១៩៥៥, លោកបានត្រូវពេជការតាំង ជាអគ្គាធិការនៃពុទ្ធិកសិក្សា ក្នុងព្រះរាជអាណាចក្រ ។

នៅថ្ងៃសុក្រ ១៥ កើតខែទុតិយាសាឍ ឆ្នាំរោងឆស័កព.ស.២៥០៧ ត្រូវនឹងថ្ងៃទី ២៤ កក្កដា ១៩៦៤, ព្រះតេជព្រះគុណព្រះពោធិវង្ស បានទទួលឋានន្តរស័ក្តិដ៏ខ្ពង់ខ្ពស់ ជាទី សម្តេចព្រះពោធិវង្ស តាមព្រះរាជក្រឹត្យលេខ ២៥ ន.វ. ចុះថ្ងៃទី ២៤ កក្កដា ឆ្នាំ១៩៦៤ ។

## ការបំរើពុទ្ធសាសនា

សម្តេចព្រះពោធិវង្ស ហ.តាត, តាំងពីបានទទួលតំណែងដ៏ខ្ពង់ខ្ពស់ជាចាងហ្វាងនៃសាលាបាលីជាន់ខ្ពស់ រៀងរហូតមក, បានទំយកព្រះហឫទ័យទុកដាក់ ក្នុងកិច្ចការមុខក្រសួងជានិច្ច, បានរិះរកមធ្យោបាយពង្រីកការសិក្សាខាងពុទ្ធចក្រ ឲ្យបានចំរើនលូតលាស់ទៅអនាគត ជាលំដាប់ ។ ព្រោះហេតុនេះហើយ បានជាអ្នកណាក៏អាចឃើញប្រត្យក្ស នូវកិច្ចការដ៏ពិបាក ៗ ដែលសម្តេចបានបំពេញក្នុងមុខក្រសួងរបស់លោក ។

ដើម្បីញុំាងកិច្ចការខាងពុទ្ធចក្រ ដែលជាភារៈដ៏ធ្ងន់ផ្ទាល់ខ្លួន ឲ្យបានចំរើនដូចអារ្យប្រទេសនានា, សម្តេចព្រះពោធិវ័ង្ស បាននិមន្តទៅពិនិត្យសង្កេតរបៀប នៃការសិក្សាខាងពុទ្ធចក្រ និងអាណាចក្រក្នុងប្រទេសធំៗខ្លះ ដូចខាងក្រោមនេះ :

## ការធ្វើដំណើរទៅបរទេស
## ក្នុងគតិបំណងបំរើពុទ្ធសាសនា

១- នៅថ្ងៃទី ៩ កញ្ញា ១៩៥២, សម្តេចព្រះពោធិវ័ង្ស ហ.តាត បានត្រូវរាជរដ្ឋាភិបាល តែងតាំងជាប្រធានគណៈប្រតិភូ តំណាងពុទ្ធ-សាសនិកជនជាតិខ្មែរកម្ពុជប្រទេស ទៅកាន់ប្រទេសជប៉ុន ដើម្បីចូលរួមក្នុងការធ្វើសន្និសីទលើកទី ២ នៃពុទ្ធិកសមាគមពិភពលោក ដែលធ្វើនៅក្រុងតូក្យូ ( ប្រទេសជប៉ុន ) និងក្រុងឯទៀតនៃប្រទេសនេះ ។ រួមរយៈពេលធ្វើដំណើរ ចំនួន ១ ខែ និង ២០ ថ្ងៃ ។

២- នៅថ្ងៃទី ១៦ មិថុនា ១៩៥៣, សម្តេចព្រះពោធិវ័ង្ស បាននិមន្តទៅកាន់ប្រទេសថៃ ជាមួយព្រះមហា ប៉ាង-ខាត់ ដើម្បីពិនិត្យសង្កេត នូវការសិក្សា នៅពុទ្ធិកមហាវិទ្យាល័យនានា ក្នុងប្រទេសនោះ ដោយមានព្រះបរមរាជានុញ្ញាត ពីព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ជាម្ចាស់ជីវិតលើត្បូង ។ កាលលោកត្រឡប់មកកាន់មាតុប្រទេសវិញ, សម្តេចព្រះពោធិវ័ង្ស ហ.តាត បានធ្វើ

សេចក្ដីពយការណ៍ថ្វាយព្រះករុណា ដើម្បីព្រះអង្គទ្រង់ជ្រាប អំពីការសិក្សាខាងពុទ្ធសាសនានៅប្រទេសថៃ ។ ក្រោយដែលបានទ្រង់យល់នូវពត៌មានផ្សេង ៗ តាមការទូលថ្វាយ នៃសម្ដេចព្រះពោធិវ័ង្ស ហើយ, ព្រះករុណាព្រះបាទ នរោត្ដម សីហនុ ដោយព្រះអង្គទ្រង់ជាព្រះអគ្គពុទ្ធសាសនិក និងជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៏ បានទ្រង់សព្វព្រះរាជហឫទ័យព្រះរាជានុញ្ញាត ឲ្យបង្កើតនូវពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ សម្រាប់បព្វជិតជាតិខ្មែរ ជាទីស្នេហានៃព្រះអង្គ ដោយព្រះរាជក្រមលេខ ៨៧៩ ន.ស. ចុះថ្ងៃទី ១ កក្កដា ១៩៥៤ ។

៣- នៅថ្ងៃទី ២៦ មីនា ១៩៥៤ សម្ដេចព្រះពោធិវ័ង្ស បាននិមន្តនៅកាន់ប្រទេសជប៉ុនម្ដងទៀត ក្នុងឋានៈជាប្រធានគណៈប្រតិភូខ្មែរ ក្នុងសន្និសីទអន្តរជាតិ ដែលបានប្រជុំធ្វើឡើង ដើម្បីស្វែងរកសន្តិភាពក្នុងពិភពលោក ។ ដំណើរលើកទី ២ នៅកាន់ប្រទេសជប៉ុន បានអស់វេលា ១ ខែ និង ២០ ថ្ងៃ ដូចមុនដែរ ។

៤- នៅថ្ងៃទី ១២ វិច្ឆិកា ១៩៥៤, សម្ដេចព្រះពោធិវ័ង្ស បាននិមន្តនៅកាន់ប្រទេសភូមា ដើម្បីចូលរួមប្រជុំក្នុងការធ្វើ ឆដ្ឋសង្គាយនា ហើយនឹងចូលរួមក្នុងសន្និសីទលើកទី ៣ នៃពុទ្ធិកសមាគមពិភពលោក ដែលគេបានធ្វើនៅក្រុងរ៉ង់គូន នៃប្រទេសភូមា ។

៥- នៅថ្ងៃទី ៧ ធ្នូ ១៩៥៥, សម្ដេចព្រះពោធិវ័ង្ស បាន

ធ្វើដំណើរ ទៅកាន់ប្រទេសថៃម្ដងទៀត ជាមួយលោក យឹម វ៉ែន ទីប្រឹក្សាបច្ចេកទេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត និង លោក តាំង-ម៉េងកោ ជាវេយ្យាវច្ចករ ក្នុងដំណើរទស្សនាពិនិត្យការសិក្សា ជាលើកទី ២ ក្នុងពជាណាចក្រថៃ ។ ក្នុងដំណើរនេះ អង្គការមូលនិធិ អាស៊ី នៅក្រុងភ្នំពេញ បានចេញសោហ៊ុយទាំងអស់ ។

៦– នៅថ្ងៃទី ៣ វិច្ឆិកា ១៩៥៦, តាមសេចក្ដីនិមន្តនៃរដ្ឋាភិបាល សហរដ្ឋអាមេរិក ដោយរាជរដ្ឋាភិបាលនៃកម្ពុជាយល់ព្រមផង, សម្ដេចព្រះពោធិវ័ង្ស ហ.តាត ដោយមានលោក ជា-ធង់ ជាសាស្ត្រាចារ្យ នៅពុទ្ធិកវិទ្យាល័យ ជូនដំណើរផង បានធ្វើដំណើរយ៉ាងវែងមួយ ទៅកាន់សហរដ្ឋអាមេរិក ជាទីដែលសម្ដេចបានធ្វើដំណើរទស្សនា អស់កាលចំនួន ៣ ខែ ។

៧– នៅថ្ងៃទី ២ វិច្ឆិកា ១៩៥៧, សម្ដេចបាននាំគណៈប្រតិភូខ្មែរ ទៅកាន់ប្រទេសលាវ ដើម្បីចូលរួមក្នុងពិធីបុណ្យពុទ្ធសតវត្សរ៍ទី ២៥ នៅក្រុងវៀងចន្ទន៍ និងក្រុងហ្លួងព្រះបាង ។

៨– នៅថ្ងៃទី ១៥ មិថុនា ១៩៥៨, សម្ដេចព្រះពោធិវ័ង្ស បានធ្វើដំណើរទៅកាន់ប្រទេសចិន ដោយពុទ្ធិកសមាគមចិនបាននិមន្តទៅ ដើម្បីទស្សនា អស់រយៈវេលា ១ ខែកន្លះ ។

៩– នៅក្នុងគ្រិស្តសករាជ ១៩៥៩, សម្ដេចព្រះពោធិវ័ង្ស ហ.តាត

បាននិមន្តទៅ កាន់ប្រទេសភូមាម្តងទៀត ដោយព្រះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានបាត់ឲ្យនិមន្តទៅជាតំណាង ក្នុងពិធីបុណ្យអនុ-ឆដ្ឋសង្គាយនា នៅទីក្រុងរ៉ង់គូន ជាមួយនឹងលោក ជា-ឧង ដែលជាសាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។ ដំណើរនេះ បានអស់ពេលតែ ២ សប្តាហ៍ប៉ុណ្ណោះ ។ បន្ទាប់ពីនោះ សម្តេចបាននិមន្តបង្ហួសទៅទស្សនា និងគោរពពុទ្ធបូជនីយដ្ឋាននានា នៅប្រទេសឥណ្ឌាចំនួន ១ ខែ ហើយបានចូលទៅកាន់កោះសិរីលង្កា ដើម្បីធ្វើអភិវន្ទនាការចំពោះព្រះចង្កូមកែវ និងទស្សនាសាលាសិក្សាខាងពុទ្ធសាសនា នៅទីនោះ អស់ចំនួន ២ សប្តាហ៍ទៀត ។ ក្នុងដំណើរនេះ មូលនិធិអាស៊ីនៅក្រុងភ្នំពេញ បានចេញថ្លៃទាំងអស់ ។

ដំណើរទាំងប៉ុន្មានលើក ដូចបានរៀបរាប់មកខាងលើនេះ សុទ្ធតែជាដំណើរទាក់ទងនឹងបរទេស ខាងផ្លូវពុទ្ធសាសនា ក្នុងគោលបំណងដើម្បីរៀបចំការសិក្សា ខាងពុទ្ធចក្រក្នុងកម្ពុជរដ្ឋ ឲ្យបានចំរើនរុងរឿងជាកំយោគភាព ។ រីឯកិច្ចការដែលជាប្រយោជន៍ដល់ពុទ្ធសាសនា និងដល់គ្រឹះស្ថានពុទ្ធិកសិក្សា ក្នុងព្រះរាជអាណាចក្រ តាំងពីលោកបានទទួលភារៈជាចាងហ្វាងពុទ្ធិកវិទ្យាល័យ និងជាអគ្គាធិការ នៃពុទ្ធិកសិក្សារៀងរាបមកដល់សព្វថ្ងៃនេះ អ្នកនិពន្ធសូមធ្វើសេចក្តីរៀបរាប់ដោយសង្ខេបដូចតទៅនេះ :

ក – ក្រោយពេលដែលលោកបានឡើងកាន់តំណែងជាចាងហ្វាង ពុទ្ធិកវិទ្យាល័យ មិនបានទាំង ១ ខែផង, សម្តេចព្រះពោធិវ័ង្ស ហ.តាត បានសុំឲ្យបង្កើតគិលានដ្ឋានមួយ សម្រាប់សមណនិស្សិត នៃពុទ្ធិក-វិទ្យាល័យ ដើម្បីកុំឲ្យសមណនិស្សិតពិបាកនិមន្តទៅ ឲ្យពេទ្យព្យាបាលរោគ នៅគិលានដ្ឋាននានា ប្រឡូកប្រឡល់ជាមួយគ្រហស្ថ ។

ខ – សម្តេចព្រះពោធិវ័ង្ស បានសុំឲ្យរាជរដ្ឋាភិបាលបង្កើនថ្នាក់បង្រៀន ឲ្យបានច្រើនឡើងទៀត ។ កាលមុនលោកកាន់តំណែងជាចាងហ្វាង សមណនិស្សិត មានចំនួនតែត្រឹម ៥០ រូបប៉ុណ្ណោះ ដែលត្រូវបានជ្រើសរើសឲ្យចូលរៀន ក្នុងពុទ្ធិកវិទ្យាល័យក្នុង ១ ឆ្នាំ ៗ ។ សព្វថ្ងៃនេះ ក្នុង១ ឆ្នាំ ៗ, គ្រឹះស្ថានសិក្សានេះ អាចទទួលសមណនិស្សិតឲ្យចូលរៀន បាន ២០០ រូប ។

គ សម្តេចព្រះពោធិវ័ង្ស បានផ្តើមសុំកែប្រែឈ្មោះសាលា ដែលពីដើមហៅថា „សាលាបាលីជាន់ខ្ពស់” ឲ្យទៅជា „ពុទ្ធិក-វិទ្យាល័យព្រះសុរាម្រឹត” ដើម្បីឲ្យមានឋានៈខ្ពស់ឡើងជាងមុនផង ហើយឲ្យសមតាមឋានៈរបស់ប្រទេសឯករាជ្យផង ។ ក្រោយដែលសាលានោះ បានត្រូវកែប្រែឈ្មោះរួចហើយ, សម្តេចព្រះពោធិវ័ង្ស ក៏បានផ្តើមសុំឲ្យរាជការកែប្រែកម្មវិធីបង្រៀនក្នុងពុទ្ធិកវិទ្យាល័យ ឲ្យបានចំរើនឡើងជាលំដាប់ ដើម្បីនឹងញ៉ាំងព្រះសង្ឃជានិស្សិត នៃវិទ្យាល័យនេះ

ដែលបានចម្រើន ខាងវិជ្ជាផ្លូវសាសនានិងផ្លូវលោក ឲ្យបានទទួលឋានៈខ្ពស់ឡើង ឲ្យសមដល់តម្លៃនៃពុទ្ធសាសនាក្នុងប្រទេសឯករាជ្យ អព្យាក្រឹត ហើយដើម្បីឲ្យពួកនិស្សិត ដែលប្រឡងចេញពីពុទ្ធិកវិទ្យាល័យ មានសមត្ថភាព អាចនឹងចូលទៅសិក្សាក្នុងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជបានទៀតផង ហើយពិសេសជាងនេះទៅទៀត ឲ្យសមតាមព្រះរាជបំណងដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះឧបយុវរាជ ឧកេត្តម សីហនុ ព្រះអគ្គប្រមុខរដ្ឋ ដែលព្រះអង្គទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលទ្រង់សព្វព្រះរាជហឫទ័យ ឲ្យសម្តេចព្រះពោធិវង្ស រៀបចំការសិក្សាខាងពុទ្ធសាសនាឲ្យបានប្រសើរឡើងផង ។

ឃ- ខាងផែកអគ្គាធិការដ្ឋាន, សម្តេចព្រះពោធិវង្ស បានស្នើយោបល់សុំឲ្យរាជការបង្កើតអគ្គាធិការដ្ឋានមួយនៅក្រុងភ្នំពេញ ហៅថា "អគ្គាធិការដ្ឋាននៃពុទ្ធិកសិក្សា ក្នុងព្រះរាជាណាចក្រ" សម្រាប់ត្រួតពិនិត្យទូទៅការសិក្សាខាងពុទ្ធសាសនា ក្នុងព្រះរាជាណាចក្រឲ្យមានរបៀបប្រសើរឡើងតាមសម័យនិយម ។ ក្នុងពេលបន្ទាប់គ្នានោះ សម្តេចបានស្នើសុំឲ្យកែរៀបចំកែប្រែឈ្មោះសាលា ដែលពីដើមហៅថា " សាលាបាលីរង " ឲ្យទៅជា " សាលាពុទ្ធិកបឋម-សិក្សា " វិញ ឯកម្មវិធីទាំងអស់សម្រាប់បង្រៀន នៅសាលាពុទ្ធិកបឋមសិក្សា ក្នុងព្រះរាជាណាចក្រ ក៏ត្រូវសុំឲ្យកែប្រែដែរ ។ លុះដល់

ដល់មកឆ្នាំ ១៩៦៤ បានរើរៀបចំកែប្រែទម្រង់សាលាពុទ្ធិកបឋមសិក្សាមួយទៀត ដើម្បីឲ្យសាលានេះមានដំហររឹងប៉ឹង មានដំណើរប្រព្រឹត្តទៅស្រួល។

អំពីបំណេភវិជ្ជា

សម្ដេចព្រះពោធិវ័ង្ស ហ.តាត មានចំណេះគឺការចេះដឹងនូវវិជ្ជាខាងផ្លូវលោក និងផ្លូវសាសនា ដែលគេអាចកប់បានដូចតទៅនេះ :

១- ចេះភាសាបាលីពិតប្រាកដ;

២- ចេះអក្សរទេវនាគរី និងភាសាសំស្ក្រឹតល្អិតល្អន់;

៣- ចេះភាសាបារាំងល្មមប្រើការបាន;

៤- ចេះភាសាថៃ, លាវ អាចនិយាយបាន និងសរសេរបាន;

៥- ចេះអានអក្សរបុរាណខ្មែរបូរាណ ។

ដោយចំណេះខាងលើនេះ, តាំងតែពីកាលដែលលោកនៅជាព្រះគ្រូសង្ឃវិជ្ជា រៀងរហូតមក, សម្ដេចព្រះពោធិវ័ង្ស ហ.តាត បាននិតខំយកព្រះហឫទ័យទុកដាក់ក្នុងការបំរើសាសនា, ព្រះរាជបល្ល័ង្ក និងប្រទេសជាតិជានិច្ច ។ កិច្ចការដែលលោកបានបំពេញរួចហើយនោះខ្ញុំបានពណ៌នាដោយសង្ខេបរួចហើយ ។ ក្រៅពីនេះ ដើម្បីជាកិច្ចជួយអប់រំខាងផ្លូវចិត្តនៃពុទ្ធសាសនិកជនទាំងឡាយ ទាំងបព្វជិត ទាំងគ្រហស្ថ ដែលពេញចិត្តគាប់អធ្យាស្រ័យ ក្នុងការប្រតិបត្តិធម្មវិន័យពុទ្ធសាសនា,

សម្តេចព្រះពោធិវង្ស ហួត - តាត បានឆ្លៀតពេលដែលលោកមាន មិនច្រើនប៉ុន្មាន ប្រែគម្ពីរដីកាពីភាសាបាលីមកជាភាសាខ្មែរ ហើយរៀបរៀងជាសៀវភៅ ដែលមានសារប្រយោជន៍ជាអនេក ដល់ជនានុជនទូទៅជាច្រើនច្បាប់ ដែលព្រះរាជបណ្ណាល័យកម្ពុជា, ពុទ្ធសាសនបណ្ឌិត្យ និងបណ្ណាគារខ្លះទៀត បានបោះពុម្ពផ្សាយរួចហើយគឺ :

១– សៀវភៅ សាមណេរវិន័យ

២– " បកិណ្ណកបរិត្ត

៣– " សត្តបរិត្ត និងទ្វាទសបរិត្ត

៤– " សុរាទោសកថា

៥– " សីមាវិនិច្ឆ័យ

៦– " អក្ខទោសកថា

៧– " សិង្គាលោវាទសូត្រ

៨– " សារទេសនា

៩– " ធម្មសង្គហៈ

១០– " វេយ្យាករណ៍សំស្ក្រឹត

១១– " ពុទ្ធសាសនាសង្ខេបក្នុងផ្នែកយុវពុទ្ធិកសិក្សា សម្រាប់យុវជនសិក្សា ។

១២- សៀវភៅ អបរិហានិយធម្មសូត្រ

១៣- " ឥទ្ធិបាទបរិយាយ

១៤- " អរិយទ្រព្យបរិយាយ

១៥- " សាមគ្គីធម៌

១៦- " ឧបក្កិលេសធម៌

១៧- " ពុទ្ធសាសន៍សង្ខេប

១៨- " រដ្ឋបាលសូត្រ

ចំណែកខាងសំណង់តាំងឡាយ ដែលសម្តេចព្រះពោធិវង្ស ហ.តាត បានជួយឧបត្ថម្ភក្នុងការកសាង និងកាន់ការកសាងផ្ទាល់ព្រះអង្គលោក គឺកុដិ សាលាធម្មមន្ទីរ សាលាពុទ្ធិកបឋមសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យជាដើម នៅក្នុងស្រុកខុង ដែលជាមាតុភូមិរបស់លោក ។ សំណង់ដែលទើបនឹងសង់ហើយក្នុងពេលថ្មី ៗ នេះ នៅវិត្តប្រាង្គ គឺវិហារជាវិការៈនៃបេតុងអារម៉េ ដែលសាងឡើងដោយស្នាព្រះហស្តរបស់សម្តេចព្រះពោធិវង្ស ហ.តាត ។

ដល់មកក្នុងឆ្នាំ ១៩៦៦ នេះ សម្តេចព្រះពោធិវង្ស បានចាប់ផ្តើមកសាងមណ្ឌលសុខភាព ១ នៅក្នុងទីប្រជុំជនខុង ដើម្បីទុកជាកន្លែងសម្រាប់ជួយរំដោះទុក្ខនៃប្រជានិករខ្លះទៅ ។ ប៉ុន្តែកិច្ចការនេះ បានរួបរួម

កម្លាំងជាមួយនឹងអ្នកដែលមានសទ្ធាជ្រះថ្លាជាច្រើន ។

ក្នុងវត្តឧណ្ណាលោម ក្រុងភ្នំពេញ ជាអារាមដែលសម្តេចព្រះពោធិវង្សគង់នៅ អស់កាលជំនួនហាសិបប្រាយឆ្នាំហើយ, សម្តេចបានចាត់ចែងកសាងសេនាសនៈជាច្រើន គឺឧបដ្ឋានសាលា, កុដិ និងសាលាពុទ្ធិកបឋមសិក្សាជាដើម ទុកជាសម្បត្តិក្នុងព្រះពុទ្ធសាសនា ។

ក្នុងបរិវេណនៃពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត, សម្តេចព្រះពោធិវង្ស បានចាត់ការស្ថាបនាអគារសិក្សាឲ្យកើតឡើងយ៉ាងសមរម្យ ដោយសម្តេចព្រះនរោត្តម សីហនុ ព្រះអគ្គប្រមុខរដ្ឋ ទ្រង់បានឧបត្ថម្ភបរិច្ចាគព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ។

ដោយស្នាព្រះហស្ត ដែលសម្តេចព្រះពោធិវង្ស បានធ្វើទាំងប៉ុន្មានតាំងពីអតីតកាល រហូតមកដល់បច្ចុប្បន្នកាល ហើយនិងដោយគុណសម្បត្តិរបស់លោក, សម្តេចព្រះពោធិវង្ស បានទទួលនូវគ្រឿងឥស្សរិយយសជាច្រើន ជាកតញ្ញុតានៃការនឿយលំបាកក្នុងការបំរើជាតិ សាសនា និងព្រះរាជបល្ល័ង្ក ។

គ្រឿងឥស្សរិយយសដែលសម្តេចបានទទួលរួចហើយ មានដូចខាងក្រោមនេះ ៖

នៅថ្ងៃទី ១៨ កុម្ភៈ ១៩៣២ មេដាយ មុនីសារាភរណ៍ នៃប្រទេសកម្ពុជា ។

នៅថ្ងៃទី ១៩ កុម្ភៈ ១៩៣២ ដោយ សឹវ៉ាលីយេរ អស្ស-ឫទ្ធិ ដំរីមួយលាននិងស្វេតច្ឆត្រ នៃក្រុងហ្លួងព្រះបាង, ប្រទេសលាវ ។

នៅថ្ងៃទី ១ មករា ១៩៤៤ ដោយ អស្សឫទ្ធិ នៃប្រទេស កម្ពុជា ។

នៅថ្ងៃទី ២៧ មករា ១៩៤៥ ដោយ សឹវ៉ាលីយេរដឺឡា-ឡេស្យុងដូណើរ នៃប្រទេសបារាំងសែស ។

នៅថ្ងៃទី ៦ វិច្ឆិកា ១៩៥១ ដោយ សេនា

នៅថ្ងៃទី ៤ មេសា ១៩៦២ ដោយ វរសេនា នៃ មុនីសារា-ភករណា ( Grand Officer de Munisaraphon )

នៅថ្ងៃទី ១៩ ឧសភា ១៩៦៤ ដោយ មហាសិរីវឌ្ឍន៍ មុនីសារាភករណា ( Grand Croix de Munisaraphon ) ។

ដ៏ប្រាត្ថិនៃសម្តេចព្រះពោធិវង្ស ហា.តា.ត

ចប់ដោយសង្ខេបប៉ុណ្ណេះ

---

# វចនានុក្រមសំស្រ្កឹត-ខ្មែរ

(ត)

*ព្រះមហា ចាំង-ទាត់ រៀបរៀង*

អនុន្នត គុ. ដែលមិនបោងឡើង ។ —គាត្រ គុ. ដែលមាន អវយវៈមិនលេចឡើង ។

អនុន្មាទ អនុន្មត្ត គុ. ដែលមិនឆ្កួត ។

អនុបការិន៍ គុ. ដែលមិនមានឧបការៈ ។

អនុបគីត គុ. ដែលមិនសូត្រតាម ។

អនុបឃាត គុ. ដែលមិនបៀតបៀន ។

អនុបយុត្ត គុ. ដែលមិនឲ្យរួចប្រយោជន៍ ។

អនុបប ធាតុ. ទុកឲ្យទុំ។

អនុបបយិ គុ. ដែលមិនតាមៈល្មោភ ។

អនុបបិត គុ. ដែលមិនទោមុះ ។

អនុបបិ ធាតុ. និយាយស្រំដែល ។

អនុបបិត គុ. ដែលអានះហួត, ដែលជាតាមគ្រូ ។

អនុបរិភិនី គុ. អ្នកជាតាមគ្រូ ។

អនុបភិ ធាតុ. ដើរតាមក្រោយ, ដេញតាម ។

អនុបត្តិកា ស្ត្រី. សំបុត្រ ។

អនុបថ គុ. ដែលដើរតាមក្រោយ, បច្ឆាប្រវេណ៍, បច្ឆាបុរស ។

បុំ.អនុបថ, អ្នកបំរើ, ផ្លូវអាក្រក់ ។

អនុបទ ធាតុ. តាម, ដើរតម្រង់ ។ រកឃើញ ។

អនុបទម៌ ក្រិ.វិ. តាមប្រកិត ។

អនុបទវី ស្ត្រី. អនុបទវី, ផ្លូវដែលគេដើរតាមក្រោយ ។

អនុបទិន៍ គុ. ដែលដើរតាមផ្លូវក្រោយ ។

អនុបធិ គុ. ដែលមិនល្បួច, ដែលមិនបន្លំ ។

អនុបបត្តិ គុ. ដែលមិនកើតឡើង ។

អនុបបន្ន គុ. ដែលមិនចុះសម្រុងគ្នា ។ អនុបបន្នាបិ គុ.

ដែលមិនមានអាថ៌ប្រាកដ ។

អនុបភោគ្យ គុ. ដែលមិនគប្បីប្រើប្រាស់បាន ។

អនុបម គុ. ដែលប្រៀបធៀបមិនបាន ។

អនុប្រយុក្ត គុ. ដែលប្រកបមិនបាន, មិនប្រកប ។

អនុបភាគ គុ. ដែលមិនល្មះក្នុងភាគៈ ។

អនុបរិក្រមិ ធាតុ. ដើរបន្តតាមក្រោយ ។

អនុបរិគា ធាតុ. ដើរព័ទ្ធ, ដើរប្រទក្សិណ ។

អនុបរិវត្តិ ធាតុ. ប្រែតាម ។

អនុបរិស្រុ ធាតុ. រត់តាម។

អនុបរី ធាតុ. ព័ទ្ធ ។

អនុបឝ៑ ធាតុ. មើល, បើក, ត្រិះរិះ ។

អនុបស្ការ គុ. ដែលមិនមែនជារបស់អាយ ។

អនុបស្កុត គុ. សរល, ច្បាស់ ។

អនុបស្ថិណិ គុ. (ដី) ទទេ ។

អនុបស្ថាន នបុំ. កិរិយាមិនតាំងនៅជិត, កិរិយាមិនបំរើ ។

អនុបហត គុ. ដែលមិនមានគេប្រកែក, ដែលមិនដល់, ថ្មី ។

អនុបា ធាតុ. ផឹករឿយៗ ។

អនុបាក្រុត គុ. ដែលមិនសមដល់ការបូជា, ដែលគេមិនប្រើ ។

អនុបាត បុំ. កិរិយាដេញតាម ។

អនុបាតក នបុំ. ទោសធំ ។

អនុបាតិន៑ គុ. ដែលដេញតាម ។

អនុបទេ ក្រិ.វិ. តាមស្នាមជើង។

អនុបាធ្យាយ បុំ. អនុបាធ្យាយ បុគ្គលមិនមែនជាគ្រូ ។

អនុបាន នបុំ. កិរិយាផឹករឿយ ៗ ។

អនុបាយ បុំ. អនុបាយ ។

អនុបារត គុ. ដែលមិនបោះបង់ ។

អនុបាលក គុ. អនុបាល ។ -បាលិន៑ ដែលរក្សា ។

អនុបាលន នបុំ. កិរិយារក្សា, ការប្រតិបត្តិតាមសាសនបញ្ញត្តិ ។

អនុបាល្យ គុ. ដែលគប្បីតាមរក្សា, ដែលជាមិត្រ ។

អនុបីត គុ. ដែលផឹករឿយៗ ។

អនុបូជ៑ ធាតុ. បូជារឿយ ៗ ។

( នៅមានត )

# ឥទ្ធិពលនៃកង់

ចក្រ មានទ្រង់ទ្រាយជារង្វង់មូល ខ្មែរហៅថាកង់ ។ កង់នេះប្រហែលមានកំណើតតាំងពី ៣០១០ ឆ្នាំ មុនគ្រិស្តសករាជ ។ កង់ជាវត្ថុតាំងដើមនៃអរិយធម៌ ក្នុងលោកយើងនេះ ។ អ្នកប្រាជ្ញទាំងឡាយពោលថា កង់ជាមូលហេតុនៃអរិយធម៌ដែរ ។ ឥទ្ធិពលនៃកង់ដូចម្ដេចខ្លះ? និងនាំរៀងកង់ដូចតទៅ ជា ៣ សម័យ គឺសម័យមុនពុទ្ធកាល, សម័យពុទ្ធកាល, សម័យស្តុតទីក ឬថា សម័យកង់ឈើ, សម័យកង់ចិត្ត, សម័យកង់ដែកនិងកង់កៅស៊ូ ៖

## ក– កង់សម័យមុនពុទ្ធកាល ឬ សម័យកង់ឈើ

កាលដែលមនុស្សចេះធ្វើផ្ទះនៅហើយ – ចេះលើកថ្មជាបន្ទប់បន្ទើតធ្វើជាគុហា – ប្រាសាទលំអវិចិត្របែបបុរាណបំផុត បានធ្លងផុតយុគថ្មគ្រើម, ថ្មលើង, យុគស្ពាន់ខ្លះហើយ ប៉ុន្តែមិនទាន់ចេះធ្វើកង់នៅឡើយទេ ។ កំណើតកង់នោះគឺ ដើមឡើយ មានកុលសម្ព័ន្ធមួយរស់នៅលើខ្ពង់រាបប៉ាមីរ ( Pamir ) ដែលគេទុកជាដំបូលនៃពិភពលោកយើងនេះ បានចុះពីខ្ពង់រាបប៉ាមីរ ចូលមកលុកលុយ ដល់ប្រទេសឥណ្ឌា ដណ្ដើមយកទឹកដីអ្នកស្រុក ធ្វើជារបស់ខ្លួន ចាប់អ្នកស្រុក ធ្វើជាខ្ញុំកំដរ ហើយឲ្យឈ្មោះភូមិលំនៅ ដែលខ្លួនដណ្ដើមបាននោះថា « ភារតវស: » (លំនៅនៃពួកភារត:) រហូតដល់សព្វថ្ងៃនេះ ។ ជនជាតិទ្រាវីឌ (Dravid)

ឬ មន្ទ (Manda) ជាអ្នកដើមកំណើតឥណ្ឌា មានសេចក្ដីចំរើនខ្លះហើយ មិនមែនទុនថយជាងពួកអ្នកមកដល់ថ្មីៗនោះទេ ប៉ុន្តែពួកអ្នកមកថ្មីនេះ បេះចិត្តក៏ បង្កើតជារទេះទឹមសេះ បរឡើងលឿនសម្រុកចូលទៅក្នុងសមរ-ភូមិ ទាំងរយទាំងពាន់ ប្រយុទ្ធកំចាត់ពួកព្រៃខ្មៅបានដោយងាយ ៗ ពួកព្រៃខ្មៅ ភ័យខ្លាចរទេះសេះកិន . ជាន់ ក៏ចុះញមចាញ់ពួកអ្នកចំណូលថ្មី ៗ កន្លែងនេះ ក៏បានហៅនៈជាស្វស្តិក គឺជារូបសញ្ញាត្រាសីលធម៌នៃមនុស្សលោកនាបច្ចុប្បន្ន ៗ អ្នកចំណូលថ្មី ហៅពួកព្រៃខ្មៅឈ្លើយសង្គ្រាម ថា "ទស្យុ" ប្រែថាសត្រូវនៃព្រះឥន្ទ្រ ព្រោះព្រះឥន្ទ្រជាទេពតារបស់ខ្លួន តមក ពាក្យថា ទស្យុ ក៏ក្លាយជាទាសៈ ប្រែថា "ខ្ញុំកំដរ" ទៅវិញ តាមដំណើរដែលពួកអ្នកឈ្នះដាក់ឲ្យ ៗ អ្នកប្រាជ្ញខ្លះ និយាយថា គេហៅពួកចាញ់ថា "ម្លេច្ឆៈ" ន័យដើមថា "អ្នកក្អំ" ៗ ចំណោរតមក ពួកអ្នកឈ្នះ បេះតែមានប្រៀបជាងអ្នកចាញ់, ពាក្យនោះ ក៏ក្លាយទៅជាមានន័យថា "ថោកទាប" ថា "មនុស្សព្រៃ" ទៅវិញ ៗ ពេលនោះ ពួកអ្នកឈ្នះ ក៏អួតអាងជាក់ឈ្មោះខ្លួនថាជា "អរិយជន" បានសេចក្ដីថា អ្នកប្រសើរ ៗ រីឯពួកអ្នកចាញ់ ក៏ទៅជា "ទាសៈ" គឺខ្ញុំកំដរ តាមដំណើរការណ៍ ៗ ដូចជាជាតិចិនដំនាន់បុរាណ ហៅខ្លួនឯងថា "ទិនស្ល" ប្រែថា អ្នកឋានសួគ៌ ឬ ទេពតា ហៅអ្នកមិនមែនជាចិនថា "ហួន" ប្រែថា មនុស្ស ឬក៏ ដូចជា ពួកអ្នកប្រទេសខាងលិច ហៅខ្លួនឯងថា

«ស៊ីវីលីហ្សេ» (Civilisé) ប្រែថា អ្នកប្រសើរ ហៅអ្នកដទៃថា «សូវ៉ាហ្សេ» (Sauvage) អ្នកមិនស៊ីវិល្ស ឬ មនុស្សព្រៃ ។

ពួកកុលសម្ពន្ធ មកពីខ្ពង់របប៉ាមីរ រុកចូលទន្ទ្រានលើពួកទ្រាវិឌ ដណ្តើមយកដីទឹករបស់ទ្រាវិឌ ហើយហៅខ្លួនឯងថា ពួកអរិយៈ អ្នកមានអរិយធម៌ ដោយសារតែចេះធ្វើកង់ ។ ពួកទ្រាវិឌ ម្ចាស់ទឹកដី ចេះធ្វើភូមិ ផ្ទះលំនៅ នៅហើយ ចុះចាញ់ ចោកចាប ជាងពួកមកថ្មី ព្រោះតែខ្លួនមិនទាន់ចេះធ្វើកង់ ។ ពួកអ្នកអរិយធម៌ ក៏មានឥទ្ធិពលគ្របដណ្តប់ទៅលើម្ចាស់ស្រុក ហើយផ្សាយអរិយធម៌-វប្បធម៌ របស់ខ្លួន មានភាសាជាដើម រីកបែកសាយទៅក្នុងពិភពលោកទាំងមូល ជាពីរមែកយ៉ាងធំ គឺមួយមែក បែកទៅខាងអឺរ៉ុប មួយមែក បែកទៅខាងអាស៊ី តាំងពី ៣០០០ ឆ្នាំ មុនគ្រិស្តសករាជម្ល៉េះ ។ សាខាបែកទៅខាងអឺរ៉ុប បានទៅជាជាតិសេលត៍ ( Celtes ) ក្រិក (Grecs) ឡាតាំង ( Latin ) ហ្សែរម៉ាំង ( Germain ) និងស្លាវ ( Slaves ) ។ សាខា ដែលបែកទៅអាស៊ីបានជាជាតិប៉ារស៊ី ( Parse ) នៅប្រទេសអៀរ៉ង់ និយាយភាសា ហ្សេនដ ( Zend ) និងជាតិហិណ្ឌូ នៅប្រទេសឥណ្ឌា ប្រើភាសាសំស្ក្រឹត ព្រមទាំងបែកជាអម្បូរភាសា តូចៗ ជាច្រើនទៀត ទាំងសាខាខាងអឺរ៉ុប ទាំងសាខាខាងអាស៊ី ។ វណ្ណនការ មានប្រៀបជាងគេនេះ ដោយសារតែចេះធ្វើកង់មុនគេបង្អស់នោះឯង ។

## ១- កង់សម័យពុទ្ធកាល ឬ សម័យកង់បិដ្ឋ

ព្រះសិទ្ធត្ថមហាក្សត្រ ទ្រង់បំពេញទុក្ករកម្មអស់ ៦ ឆ្នាំ ហើយបានត្រាស់សម្មាសម្ពោធិញ្ញាណ ។ ក្រោយការត្រាស់ដឹង ៥៦ ថ្ងៃ ត្រូវជា ៥៨៨ ឆ្នាំ មុនគ្រិស្តសករាជ គឺពេលដែលពុទ្ធសាសនា កើតឡើងក្នុងលោក ។ ព្រះពុទ្ធមានបំណងដឹកនាំសត្វ ឱ្យរួចផុតចាកទុក្ខក្នុងវដ្តសង្សារ តាមអធ្យាស្រ័យជាពុទ្ធវេនេយ្យ ។ ព្រះអង្គឃើញច្បាស់នូវពពួកសត្វ កំពុងងប់ក្បាលក្នុងអន្ធធម៌ ដែលជាធម៌ថោកទាបរកច្រកចេញឱ្យផុតពីទុក្ខពុំរួច ទើបព្រះអង្គផ្តើមទេសនាជាដំបូង, ដែលមានបញ្ចវគ្គិយភិក្ខុ ទៅស្តាប់ផ្ទាល់ ។ ព្រះអង្គទ្រង់យល់ច្បាស់ថា គ្មានបុគ្គលណាម្នាក់ បានដឹងនូវធម៌ដ៏ប្រសើរជាផ្លូវគេចឱ្យផុតពីគំនរទុក្ខឡើយ ។ បឋមទេសនា ព្រះអង្គសំដែងពីកង់គឺធម៌ ជាគ្រឿងវិលទៅកាន់សេចក្តីចំរើន នូវអរិយមគ្គ ឈ្មោះថា ធម្មចក្កប្បវត្តនសូត្រ ប្រែថាកង់គឺធម៌ដ៏ប្រសើរ ជាហេតុញុំាងអ្នកប្រព្រឹត្តប្រតិបត្តិ ឱ្យរួចផុតពីគំនរទុក្ខ ។ ធម្មចក្ក កង់គឺធម៌ដ៏ប្រសើរនេះ ព្រះអង្គចាត់ទុកជាអរិយធម៌ របស់អរិយបុគ្គលជាន់ខ្ពស់ ក្នុងពុទ្ធសាសនា ដូចមានបទថា ម្នាលភិក្ខុទាំងឡាយ ហេតុ ២ ប្រការគឺ កាមសុខល្លិកានុយោគ កិរិយាធ្វើខ្លួនឱ្យជាប់ជំពាក់ក្នុងកាមទាំងឡាយមួយ, អត្តកិលមថានុយោគ កិរិយាធ្វើខ្លួន ឱ្យនឿយលំបាកឥតប្រយោជន៍មួយ, ហេតុទាំងពីរនេះ

បព្វជិតមិនគួរសេពគប់ទេ ព្រោះជាអំពើថោកទាប, ជាធម៌សម្រាប់អ្នកស្រុក, ជាធម៌របស់បុថុជ្ជន, មិនប្រកបដោយប្រយោជន៍, ជាហេតុនាំឲ្យលំបាកកាយទទេ, មិនមែនជាអរិយធម៌ របស់អរិយបុគ្គលទេ ។ ព្រះអង្គហៅហេតុទាំងពីរនេះថាជាអន្តធម៌ គឺធម៌ដ៏ថោកទាបគំរក់បំផុត ។ ចុះអ្វីទៅអរិយធម៌? មជ្ឈិមា បដិបទា ការប្រតិបត្តិតាមផ្លូវកណ្តាលក្រៅពីអន្តធម៌ទាំងពីរនេះ ជាផ្លូវឲ្យកើតបញ្ញាចក្ខុ, ធ្វើឲ្យកើតសេចក្តីដឹងច្បាស់នូវកងទុក្ខ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់, ដើម្បីសេចក្តីដឹងចំពោះដោយប្រពៃ, ដើម្បីសេចក្តីរលត់ទុក្ខទាំងពួង ។ ចុះផ្លូវប្រតិបត្តិកណ្តាលនោះ ដូចម្តេចខ្លះ? អរិយោ អដ្ឋង្គិកោ មគ្គោ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ ហៅថា សេចក្តីប្រតិបត្តិជាកណ្តាល ៖

១- សម្មាទិដ្ឋិ ប្រាជ្ញាយល់ឃើញត្រូវ

២- សម្មាសង្កប្បោ សេចក្តីត្រិះរិះត្រូវ

៣- សម្មាវាចា សំដីត្រូវ

៤- សម្មាកម្មន្តោ ការងារត្រូវ

៥- សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ

៦- សម្មាវាយាមោ សេចក្តីព្យាយាមត្រូវ

៧- សម្មាសតិ សេចក្តីរឭកត្រូវ

៨- សម្មាសមាធិ ការតំកល់ចិត្តឲ្យនឹងត្រូវ

អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង ឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ ព្រះអង្គទ្រង់សំដែង នូវកងទុក្ខទាំង ១៣ កង មានជាតិជាដើម ហៅថាទុក្ខអរិយសច្ច, នូវហេតុដែលនាំឲ្យកើតទុក្ខ គឺកាមតណ្ហា, ភវតណ្ហា, វិភវតណ្ហា ហៅថា ទុក្ខសមុទយអរិយសច្ច, នូវវិធីរលត់កងទុក្ខ និង កំណើតទុក្ខទាំងនោះ ហៅថា និរោធអរិយសច្ច, នូវការត្រាស់ដឹងនូវអរិយមគ្គ ហៅថា មគ្គអរិយសច្ច ។ អរិយសច្ចទាំង ៤ នេះហើយ ដែលព្រះអង្គបានត្រាស់ដឹងចំពោះ ដោយព្រះអង្គឯងគ្មាននរណាម្នាក់ក្រៅពីព្រះអង្គបេះដឹងឡើយ ។ ព្រះអង្គតាត់ទុកជាកង់គឺអរិយធម៌ដ៏ប្រសើរខ្ពស់ផុត កម្រែបុគ្គលណាត្រាស់ដឹងបាន (សេចក្ដីពិស្ដារគួរជម្មចក្កប្បវត្តនសូត្រស្រាប់) ។ ធម្មចក្កប្បវត្តនសូត្តំ និដ្ឋិតំ កង់គឺធម៌ដ៏ប្រសើរបេបុភាម មនុស្សនិងទេវតាទាំងឡាយ បន្លឺជយឃោសន៍ថ្វាយពរសព្ទសាធុការព្រឺកកង់ពេញ លាន់ឮខ្ទរខ្ទារតាំងពីភុម្មទេវតា រហូតដល់ព្រហ្មលោកជាបន្តបន្ទាប់ ដោយបញ្ចេញសំឡេងថា កង់គឺធម៌ដ៏ប្រសើររបស់អរិយបុគ្គលនេះ គ្មានកង់ឯណាមួយក្រៅលែងជាង ពោះសមណៈក្ដី, ព្រាហ្មណ៍ក្ដី, ទេវតាក្ដី, មារក្ដី, ព្រហ្មក្ដី, អ្នកឯណាដទៃក្ដីក្នុងលោក សំដែងពុំបានឡើយ មានតែព្រះសម្ពុទ្ធមួយព្រះអង្គគត់ ទ្រង់បានសំដែងហើយ ជាដំបូងបង្អស់ នៅក្នុងឥសិបតនមិគទាយវន័ ជិតក្រុងពារាណសី ។

## គ - កង់សម័យស្ពុតនិក ឬ សម័យកង់ដែកនិងកង់កៅស៊ូ

កង់ជាវត្ថុធាតុមួយយ៉ាង ជួយសម្រេចប្រយោជន៍ ជាច្រើនប្រការ ដល់មនុស្សជាតិ ។ ទារកទារិកាប្រសូតមកភ្លាម ហើយអាចចេញពីបន្ទប់ប្រសូតទៅនៅផ្ទះឆ្ងាយ ទៅបន្ទប់ថែកុមារសម្ភព បានដោយរទេះមានកង់ ជួយទ្រុញជូនទៅ ។ មនុស្សប្រសូតមកហើយ កង់ចក្រនាឡិកាដ៏តូចល្អិត ក៏ផ្តើមវិលរាប់អាយុ ចាប់តាំងពីវិនាទីរហូតដល់ឆ្នាំ ។ កង់មួយជីវិតមនុស្ស, គេវាស់កិច្ចការមនុស្សធ្វើនិងពេលមនុស្សសម្រាក ដោយសារតែកង់ចក្រនាឡិកានេះដែរ ។ កសិករនាំគ្រាប់ពូជនានា និងជី ទៅកាន់ស្រែចំការ រួចនាំត្រឡប់មកវិញ នូវផលពីស្រែចំការ មកគេហដ្ឋាន បានដោយសាររទេះដែលមានកង់នេះដែរ តែនេះជាមតិកពីបុរាណកាល ។ មនុស្សបង្កើតកង់ ឲ្យជួយកម្លាំងខ្លួន ដើម្បីស្វែងរកប្រយោជន៍ លើអាកាស, ព្រះធរណីនិងលើទឹក ។ រថយន្តតូច - ធំ ដែលមានកង់កៅស៊ូ បានដឹកនាំមនុស្សនិងប្រដាប់ប្រដាប្រើប្រាស់ របស់មនុស្ស ទៅគ្រប់ទិសតំបន់ តាមបំណង ។ កង់ជួយមនុស្សក្នុងការលើកទំនប់ - សង់ផ្ទះ - សង់ស្ពាន - ជីកស្រះ - ជីកអណ្តូង - ធ្វើថ្នល់ - ធ្វើមណ្ឌលអគ្គិសនី - ជីកព្រែក - បឹង - វេញខ្សែ - បកកប្បាស - ហូតអម្បោះ - ត្បាញសំពត់ជាដើម ។ កង់ធំ ៗ នៃម៉ាស៊ីន ក៏ផ្តល់ពន្លឺកំដៅឲ្យថែមទៀត ។ អយស្ម័យយាន រត់លើរេណូបថ បាន ១៦០ ទៅ ២០០ គីឡូម៉ែត្រ

ក្នុង ១ ម៉ោង ដោយមានកង់ជួយទ្រ ៗ កង់តូច - ធំអាចបង្វិលម៉ាស៊ីនទាក់ឲ្យមានល្បឿនយ៉ាងលឿន ធ្វើការកាត់មហាសាគរដ៏ធំល្វឹងល្វើយ បានដោយងាយ ៗ លោក ដ. សាស្ត្រារូហ្វ ជាតិរុស្ស៊ី បានពោលក្នុងទស្សនាវដ្ដីឈ្មោះ «ប្រទេសសូវៀត» លេខ ២ (៤) ខែកុម្ភៈ ១៩៦៥ ថា យន្តហោះ " ទូ- ១១៤ ,, នៃកងអាកាសចរស៊ីវិលសូវៀត ធ្វើដំណើរពីមូស្គូដល់ខាបារ៉ូហ្វ តែក្នុងរយៈ ៨ ម៉ោងប៉ុណ្ណោះ (ចម្ងាយ ៦.៩៨០ គ.ម ) ហើយយន្តហោះទាំងនោះ ចុះនិងឡើងបាន ក៏ដោយសារកង់ដែរ កង់ទាំងឡាយតូច - ធំ បេះតែវិលអស់មួយជីវិត ក្នុងគ្រឿងម៉ាស៊ីនតូច-ធំ ៗ កិច្ចការរបស់កង់នៀយលំបាកក្រៃលែង ហើយគ្មានពេលកំណត់ផង ដើម្បីជួយទ្រទ្រង់ជីវិតរបស់កង់និងបង្កើនល្បឿនរបស់វា ឲ្យលឿនទៅមុខ ព្រមទាំងដើរបានស្រួល មនុស្សបានបង្កើតឃ្នី ជាជំនួយកង់ឲ្យវិលបានស្រួល ៗ បណ្ដាឃ្នីទាំងនោះ ឃ្នីខ្លះតូចល្អិតប៉ុនគ្រាប់អង្រ្កឹមអង្រ្កឹម, ខ្លះទៀតធំប៉ុនកង់រថយន្តមួយ ៗ ក៏មានដែរ ៗ ពេលណាមួយ, គេនឹងឃើញ កង់អវកាសមួយវិលជុំវិញផែនដីជាមិនខាន ៗ មានកង់មួយ សណ្ឋានដូចរ៉ូ ក៏ប៉ុន្តែ មិនមែនជាគ្រឿងល្បែងក្មេងលេងទេ គឺជាគំរូ " ស្ពុតនិក ,, នាអនាគតកាល ។ កង់រ៉ូនេះ អណ្ដែតដូចជាព្រះធរណី ហើយវាអាចញាំងមនុស្ស ដែលជិះលើវា ឲ្យជួបប្រទះនឹងលក្ខណភាព ដូចជានៅលើពសុធាយើងនេះដែរ ៗ សម័យនេះ

អវកាសចរ មិនមែនទើបចាប់ផ្តើមទេ, មនុស្សបានឈានចូលទៅក្នុងអវកាស ជាច្រើនជំហានរួចទៅហើយ ដោយបានទាំងនាំយក នូវប្រវត្តិរបស់កង់ទៅជាមួយផង ។

ដោយហេតុកង់មានឥទ្ធិពល ក្នុងការជួយមនុស្សយ៉ាងនេះ បានជាក្នុងបច្ចុប្បន្នកាលនិងអតីតកាល គេយកកង់នេះ ទុកជាតំណាងនៃសេចក្តីក្លាហាន, ខ្លាំងពូកែ ដូចជាព្រះមហារាជជំនាន់ដើម ផ្សាយអំណាចចេស្តាទៅលើប្រទេសរាជបាន ដោយមានចក្ករ័ត្នគឺកង់ទិព្វ ឬកង់អំណាចចេស្តាបារមី ដែលខ្លាំងពូកែស័ក្តិសិទ្ធិ ប្រកបដោយចតុរង្គសេនា ។ មហារាជអង្គណា មានចក្ករ័ត្ន មហារាជអង្គនោះ មាននាមថា "ចក្កវត្តិរាជ" ឬមហាចក្រពត្រាធិរាជ" (ចក្កវត្តិសូត្រ-សុត្តន្តបិដក ទីឃនិកាយ ភាគ ១៨) ។

កម្ពុជរដ្ឋ, ធ្លាប់មានអរិយធម៌ និង អាណាចក្រទូលំទូលាយ នាអតីតកាល ក្នុងឧបទ្វីបឥណ្ឌូចិន ដូចប្រវត្តិសាស្ត្របានប្រាប់ ។ គេឃើញមានយកចក្កសព្ទ មកប្រើតំណាងឈ្មោះប្រទេស ដូចពាក្យថា "អាណាចក្កកម្ពុជា „ ប្រែថា "កង់គឺអំណាចនៃប្រទេសកម្ពុជា" ខ្មែរប្រើចក្កសព្ទ ជាពីរផ្នែកគឺ អាណាចក្ក កង់គឺអំណាចរដ្ឋ ១, ពុទ្ធចក្ក កង់គឺពុទ្ធសាសនា ១ ។ កម្ពុជរដ្ឋ ធ្លាប់មានអាណាចក្កជាមហាអំណាច ក្នុងសម័យមហានគរ ។ ឯពុទ្ធចក្កបានចូលមកបោះគ្រឹះ ចាក់ឫស សាយសុសក្នុងកម្ពុជរដ្ឋ តាំងពីពុទ្ធសតវត្សរ៍ទី ៣ ម៉្លេះ ។ រថគឺប្រទេសកម្ពុជា

មិនឃ្លើសឃ្លោង, មិនផ្អៀងខ្វាន ៗ, មិនភ្លូក, មិនក្រឡាប់ ដោយមានកង់ទាំងពីរ ជួយទប់ទ្រ ហើយវិលទៅស្របគ្នា ធ្វើឲ្យអ្នកជិះ គឺពលរដ្ឋបានសុខក្សេមក្សាន្ត ចាកគ្រោះភ័យគ្រប់ប្រការ ។ ដូច្នេះហើយបានជាសម្តេចព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់តាំងបដានមាំ ដំរះច្រេះ ខាត់សំអាតកង់ទាំងពីរ មិនឲ្យរង្គោះរង្គើ ឲ្យមានភាពរឹងប៉ឹង គឺសាមគ្គីវិញជាធ្លុងមួយរវាងប្រជាជាតិខ្មែរ ដរាបបាននូវឯករាជ្យសម្បូណ៌ ហើយទ្រង់ញាក់ខ្សែ បររថកម្ពុជា ឲ្យរត់ត្រង់ផ្លូវកណ្តាល ឥតពាសប៉ះទង្គិចទង្គុកនឹងដង្គត់ផ្សេងៗ ឡើយ ។

សរុបសេចក្តីទៅ ឃើញថាឥទ្ធិពលនៃកង់ មានបែបផែនប្លែក ៗ គ្នាតាមសម័យ ប៉ុន្តែ នៅតែរក្សានូវអានុភាពរបស់ខ្លួនហូរហែដរាប ។

ពុធ - សារឿន

សាលាដំបូង កំពង់ចាម

---

រីអាណាចក្រ វិលទៅឥតអាក់ ឥតភ្លូកប្រឡាប់
ដោយធម្មចក្រ ជាកង់បំណាប់ គាំទ្រជាប្បាប់
វិលទៅស្របគ្នា ។

ញ.ស.

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១០

( ត )

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

ព្រះរាជនិពន្ធរាមកេរ្តិ៍ភាគ ១០ នេះ និយាយតាំងតែព្រះ សុតប្រុត ល្បងសិល្ប រហូតដល់ទៅព្រះភិរុត និងព្រះសុតប្រុតទៅគ្រងនគរកៃកេស ហើយព្រះជនកតាំងពិធីលើកខ្ទមហាមោលីឯនគរទិចិលាបុរីរាជធានីហោង ។

*កាលណោះ ទើបអង្គព្រះ សុតប្រុត ស្តេចក៏ចាប់យកសរសិល្ប ហើយក៏ផ្លែងទៅដោយបុត្ញា ។ សរ ១ នោះ កើតជាព្យុះខ្យល់បក់ផាត់មក សរ ១ ទៀត កើតជាភ្លៀងធ្លាក់ចុះមកច្រើនណាស់ ដាសផែនដី សរ១ទៀតទី៣ ក៏កើតជាភ្លើងឆេះ ហើយក៏ត្រឡប់មកកើតជាមាលីមាលា ។ កាលណោះ រីអស់ហ្វូងទេវគ្រប់ពសី តាំងគន្ធព្វគិន្នរសុបណ្ណគ្រុឌាវិជ្ជាធរ តាំងក្សត្រគ្រប់នគរ ផែនត្រៃលោកនោះ លុះបានឮស័ព្ទសម្លេងគឹកកងរំពងកោលាហល តាំងមណ្ឌលពសុធាអាកាស ក៏កក្រើកអំពើកងងឹតអ័ព្ទអស់ បិទបាំងតាំងសែងអរុណោទ័យ ភ័យភិតតិតគ្រប់ផែនដី, តែទេវគ្រប់ពសីនោះ លោកជ្រាបហេតុថា គឺព្រះវង្សទេវេសល្បងលងសិល្ប ដូច្នោះចំពោះ លោកមានសេចក្តីត្រេកអរសោមនស្ស រហូតទូទៅដល់ទេវិន្ទព្រហ្មិន្ទ្រា ហើយក៏មានវាចាថា អស់ពួកអសុរតាំងប៉ុន្មាន គង់តែអន្តរធាន ទីងស្លាប់វិនាសអន្តរាយ ដោយសិល្បសាយអំណាចបារមី*

ព្រះអង្គ, ទេវអង្គខ្លះ ក៏បាចសាចមាលាបុប្ផជាតិសុគន្ធ ធ្លាក់ចុះមកមីរ ដេរដាសពាសពេញធរណី ហើយទេពទេវនិងទេពនារី ក៏បើកបង្អួច ប្រាសាទវិមាន ស្រែកឲ្យសព្ទសាធុការ គង់គ្រប់ ៗ វិមានរហោង ៗ កាលណោះ ព្រះបាទធតរដ្ឋាធិបតី ទាំង ៣ ព្រះអគ្គជាយា ព្រះវង្សានុ-វង្ស ពង្សស្នំកំណាន់ទាំងពួង មួយទៀត ទាំងក្រសួងសេនាមុខមន្ត្រី គរុព្រាហ្មណ៍ព្រឹទ្ធាចារ្យ ហោរា អាមាត្យ ប្រជាជន ទូវអស់ទាំងសកល យោធាទាហាននោះ លុះបានឃើញឫទ្ធិព្រះរាជកុមារទាំង ៤ អង្គ ទ្រង់ ល្បងសិល្បសាស្ត្រ លាន់ឮទាំងធាត្រៃលោកាហើយ អ្នកទាំងអស់នោះ ក៏សែនសោមនស្ស នាំគ្នាថ្វាយព្រះពរមង្គលសួស្តីសិរីអឹងកង រំពងទាំង ផែនដី ផ្ទាំងរាជស្ថាន សូមឲ្យព្រះអង្គបានគម្រង់រាជធានី គពង្សវង្ស ក្សត្រាទៅមុខ ទឹងបានជាទីពឹងពំនាក់នៃត្រៃលោកា ៗ កាលណោះ ព្រះមហាតាបសទាំងពីរអង្គនោះ ក៏បានឃើញ ៤ ព្រះនត្តា ល្បងសិល្ប សាស្ត្របានដូចព្រះទ័យ ហើយព្រះឥសីនោះ ក៏សែនត្រេកសោមនស្ស ហើយសើចញឹម ៗ ស្រេចស្តេចក៏ទ្រង់ឲ្យសព្ទសាធុការ អំណាយឲ្យ ជ័យថា ចូរចៅតា ទាំង ៤ នាក់ មានឫទ្ធិក្រៃ ដូចភ្លើងប្រល័យកល្ប ហោង ៗ ស្រេចហើយ ព្រះតាបសផង ក៏ថ្វាយព្រះពរ លាព្រះបាទ ធតរដ្ឋ វិលទៅអាស្រមវិញហោង ៗ

ទីនេះពណ៌នាពោលពីព្រះបាទកៃកេសបុរី ស្តេចបានជ្រាបសេចក្តីថា

ព្រះរាជបុត្រី ដែលទៅនគរស្រីអយុធ្យាផ្កាកដែតនោះ មានរាជទូតសេប្រុស ១ វិសេស ហើយចេះសិល្បសាស្ត្រ ដ៏មានឫទ្ធានុភាពពន់ក្រៃ ទើបអគ្គព្រះភូវន័យ ស្ដេចគិតក្នុងព្រះចិន្ដាថា ខ្លួនអញនេះ ក៏ជរាភាពណាស់ហើយ, បើដូច្នេះ មានតែអញនឹងឲ្យទៅសូមរាជនត្តា មកឲ្យជួយរក្សាអាណាចក្រ ក្រៃក្រុងមានពួកអសុរយក្ស បច្ចាមិត្រពាលពាលា រាមកប្រមាថយកនគរបូរី ហើយ នឹងបានទៅអញ ជួយរាំងពាំងពារការពារចម្បាំងរាំងជល់ មិនឲ្យអន្ដរាយ ៗ គិតហើយ ព្រះចក្រាក៏មានព្រះរាជទីបង្គាប់ទៅនឹងសេនាបតី ឲ្យតែងរាជសារ ទៅសុំយកព្រះរាជកុមារនត្តាអញ មកទុកក្នុងព្រះរាជបុរី ៗ គ្រានោះ វិសេនាបតីលើកដៃបង្គំហើយ ក៏ចេញចាកទីគាល់មក ហើយក៏ប្រើឲ្យអាលក្សរសេររាជសារ ចុះដាក់ក្នុងសន្ទឹកមាសដែស្រេចហើយ ក៏ច្រកដាក់ក្នុងបំពង់កែវវង្ស៍ ឲ្យសេនិយនាំទៅបូរីអយុធ្យា ៗ គ្រានោះ វិសេនិយតាំងបីរាជទូត ទទួលព្រះរាជសារ ចេញចាកវៀងរាំងជ័យទៅ ឆាប់ ៗ ប្រញាប់យាត្រា តាមដោយមគ្គមាគ៌ពនាលីទីហេមវន្ត ៗ ដល់ហើយ ក៏ចូលកាន់អយុធ្យាធានី ជាទីទ្វារ ល្អដូចឋានត្រៃត្រឹង្សសួគ៌ទេវលោក ហើយក៏ចូលទៅរកសេនាបតី ជម្រាបសេចក្ដីសុមន្ទនអគ្គសេនា រាយតាមវៀងរាជសារ ៗ

កាលណោះ វិសុមន្ទនសេនានោះ បានថែងកិច្ចាពាក្យពីរាជទូត ហើយ ក៏នាំគ្នាលីលាចូលកាន់ព្រះរាជវាំងគាល់, លុះបានដល់ហើយ

កំក្រាបថ្វាយបង្គំទូល ព្រះចមកំពូលចក្រពង្សវង្សទេវាថា ព្រះបាទកៃ-
កេសនគរ ស្ដេចប្រើទូលបង្គំជាខ្ញុំ នាំព្រះរាជសារ មកថ្វាយទ្រង់ព្រះ
ករុណាវិសេស ជាមហៃមហិស្សរា, ទូលហើយ ក៏បើកបំពង់កែវរតនា
ហើយក៏លើកដាក់លើសិរសា ទើបចាប់យកសាររាជសុវណ្ណនោះ ហើយក៏
ក្រាបថ្វាយបង្គំ ថ្វាយទៅសម្ដេចព្រះជ័យទ្រង់ធម៌ ព្រះអង្គឲ្យទៅសេនាមើល
ថ្វាយព្រះអង្គ ក្នុងន័យព្រះរាជសារថា ព្រះបាទកៃកេស សោយនគររស
រដ្ឋ ជាមហាសុវណ្ណសម្ពន្ធមិត្រ រួមផែនមាសមួយនឹងគ្នាជាប់ជាខេត្តខណ្ឌ
ពន្ធសីមាអយុធ្យាបុរី ចម្រើនសិរីសុវត្ថិស្ថាពរ ចូរឲ្យនាងដល់មកព្រះចក្រ-
ពង្សពិនពិភពជានិទ្ទបុរីវៀងជ័យអយុធ្យា សូមជ្រាបសេចក្ដី ដ្បិតបុរីក្រុង
កៃកេសភាព ក៏គ្មានរាជទុរសានត្តាណាមួយសោះឡើយ ហើយខ្ញុំសុំ
យកអង្គព្រះកុតទៅទុកនៅរក្សានគរ ហើយនឹងបានគតពង្សវង្សា អាណា
ប្រជារាស្ត្រសេនាបតីមន្ត្រីតូចធំ នឹងបានជាទីពឹងពំនាក់នគ្គា ដូចឆត្រ
កែវបើកបាំងសែងព្រះទិនករ ជាមហាចមកំពូលលោកាអាណាចក្រ ក្នុង
នគរបុរីកៃកេសហោង ។ កាលណោះ ព្រះបាទធតរដ្ឋឫទ្ធិច្បង បាន
ស្ដាប់សេចក្ដីសារហើយ ព្រះអង្គទ្រង់ត្រេកអរសោមនស្សា ទើបស្ដេច
មានព្រះឱង្ការត្រាស់ថា ឥឡូវនេះ ព្រះអយ្យកាធិបតី ឲ្យសារមកសុំ
យមចៅទៅសោយរាជ្យឯធានី, អញនេះ នឹងឲ្យដូចចិន្តាហឫទ័យ ។
ត្រាស់ហើយ ទើបក្សត្រិយ៍ស្ដេចក៏ចុះចាកទីនៃអាសន៍ ហើយព្រះអង្គ

ទ្រង់ក្រោយចូលទៅកាន់ប្រាសាទពជមន្ទីរទៀត ដាក់អង្គគង់លើបល្ល័ង្ករតនា ព្រមទាំងពួកក្សត្រសូរ្យវង្សទាំងហ្វូងស្រីស្នំកំណាន់ គង់គាល់គ្រៀបត្រា ណាន់ណែនទាំងមន្ទីរស្ថាន ទើបអាតាណាត្រាស់ប្រាប់ទៅនាងកៃកេសីថា ម្នាលនាងកល្យាណីដ៏ចម្រើនអើយ! ឆោមអើយ ឥឡូវនេះ ព្រះបុត្រ របស់អង្គអនុជនាង ស្តេចមានសារ មកសុំពជនុរសារបស់នាងយៅវរេត ទៅទុកតាំងព្រះនេត្រតាំងព្រះកាយ កែវកាយ បើមិនឲ្យ ក្រែងកើត ទោមនស្ស ទាស់ព្រះទ័យព្រះអង្គ ។

កាលណោះ រីនាងកែវឆោមយង់កៃកេសីសោភ បានស្តាប់ព្រះឧង្ការស្វាមីហើយ ក៏លើកដៃថ្វាយបង្គំទូលទៅថា រីអង្គសម្តេចព្រះបិតាទ្រង់យស ស្តេចក៏គ្មានពជនុរសារនត្តាសោះឡើយ, ហើយដែលនឹងឲ្យកូនសម្លាញ់របស់ខ្ញុំម្ចាស់ ដូចជូនជីវិតទៅនៅនឹងអង្គព្រះអយ្យកា, ការនេះ ក៏ស្រេចលើព្រះអង្គទ្រង់តេជ មេត្តាប្រោសលើសិរសាខ្លួនខ្ញុំម្ចាស់ ជាខ្ញុំក្រោមល្អងធូលីព្រះបាទ នឹងរឹងក្រែងភាស់ព្រះអធ្យាស្រ័យព្រះអង្គ សូមទ្រង់ជ្រាប ។

កាលណោះ ព្រះបាទធតរដ្ឋ រឿងឫទ្ធអានុភាពធិបតី បានស្តាប់អគ្គមហេសីស្តីទូលហើយ ព្រះអង្គសែនសោមនស្ស ដូចបានពរទិព្វមក សេពសោយស្រេច ។ ទើបព្រះអង្គ មានព្រះឧង្ការទៅនឹងព្រះកិរុត

រាជទូលថា ឥឡូវនេះ ដីកាអ្នក ឲ្យមកសុំយកអ្នកទៅឲ្យតស្សូវង្សពង្ស, គួរតែរ ល្មមអ្នកនឹងទៅស្នង រង់ព្រះបាទព្រះអយោធ្យាធិរាជ តាំងព្រះនេត្រា ទាំង ២ ជាទីបមកំពូលពិនត្នូបូរកៃកេសនគរ ។

កាលណោះ ព្រះកិរុតកុមារ បានស្ដាប់សម្ដេចព្រះបិតាហើយ ក៏ លើកហត្ថផ្ដូលីករប្រណម្យ បង្គំក្រាបទូលតបស្នងព្រះឱង្ការថា ដែល ទ្រង់ប្រោសមេត្តាឲ្យទៅនោះ កូនសោតមិនចង់ឲ្យឃ្លាតឆ្ងាយ ពីកាយ ព្រះករុណា និងអង្គសម្ដេចព្រះជននីទាំងបីអង្គ នូវអង្គព្រះជេដ្ឋាធិបតី នូវ ពីរអនុជស្សូវវង្ស តាមតែព្រះបិតុរង្គទ្រង់ព្រះមេត្តា ទាល់គំនិតទាល់ ប្រាជ្ញា ទូលព្រះបង្គំជាខ្ញុំ នឹងពាកឃ្លាតឃ្លាទៅ ។

កាលណោះ ព្រះបាទធតរដ្ឋបមទៅ ស្ដេចបានស្ដាប់រាជទូលទូល ពណ៌នាហើយ ក៏ទ្រង់ត្រាស់តបវិញថា ម្នាលដួងជីវអាពុកអើយ ! កូន អើយ អ្នកជាដូងព្រះ រាខុសទេ ដ្បិតហ្វូងទេពទេវសុរាល័យ អញ្ជើញ អ្នកថ្ងៃ ឲ្យចុះមកសម្រាប់នឹងជួយបង្ក្រាបអសុរពាលពាលា កូនមិនចង់បែក ឃ្លាតពង្សរាសោះ, ណ្ហើយចុះ អាពុកឲ្យព្រះសុតទ្រង់ទៅនៅជាមួយផង គ្រាន់នឹងកំដរជាគ្នា, ឯព្រះលក្ខណ៍អនុជនិងអង្គព្រះពមានោះ អញនឹង ឲ្យនៅរក្សានិវេសន៍រាំងបន្ទូ តាំងនេត្រាត្នង់ស្ដាំបិតា ។

(នៅមានត)

# កា ព្យ និ ទា ន

## រំលឹកដល់ព្រហ្ម មុខបួន នៅ អង្គរ

លោក ឡើក-អំ និស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ រៀបរៀង

“ បទ កាកគតិ ”

នុះទីប្រាសាទ ប្រសើរស្អាងស្អាត សុទ្ធសឹងផែនថ្ម
ជំណែលបុរាណ លោកបានបង្ក· បង្កើតទុកមក
រហូតសព្វថ្ងៃ ។

ក្លោងទ្វារតូចធំ មែនមានមុខព្រហ្ម ញញឹមប៉ប្រៃ
ព្រះព្រហ្មចម្លាក់ ហាក់សៅវិស័យ មើលហើយអាល័យ
អាឡោះព្រហ្មថ្ម ។

ព្រះអើយព្រះព្រហ្ម បុរាណនិយម តំកើងថាល្អ
ឆ្លាក់មុខព្រហ្មបួន ខ្វះខ្ទួនខ្វះក ឲ្យព្រហ្មទ្រាំទ្រ
យាមទ្វារតមក ។

រដូវវស្សា ភ្លៀងធ្លាក់កាលណា មនុស្សមានផ្ទះជ្រក
អនិច្ចាព្រហ្មប្រាណ ពុំមានជម្រក ហាលភ្លៀងហើយក្អក
សើចញញឹមព្រាយ ។

រដូវខែប្រាំង រស្មីថ្ងៃចាំង មនុស្សក្តៅក្រហាយ
ចំណែកប្រាណព្រហ្ម និយមរីករាយ ជួយយាមបន្ទាយ
ប្រាសាទស្ដេចស្ដែង ។

ព្រះអើយព្រះព្រហ្ម    អ្នកប្រាជ្ញនិយម    ប្រៀបព្រហ្មនោះឯង
ពោធិសត្វទ្រង់ធម៌    បវរលើសលែង    គ្រាលគ្រងរាលវែង
គឺវដ្តសង្សារ ។

ហឫទ័យខ្ជាប់ខ្ជួន    ក្ដួចកាន់នាំមួន    ធម៌ ៤ ប្រការ
ព្រោះគិតជានិច្ច    ឥតភ្លេចពេលណា    ចំពោះលោកា
លោកកើតវិបត្តិ ។

ទី ១ មែនមាន    មេត្តាកប់អាន    ស្នេហាខ្លាំងក្លាត់
ពិតពុំប្រកាន់    វង្សវណ្ណៈសត្វ    ឃើញមានវិបត្តិ
ចូលជួយរំដោះ ។

ទី ២ ពិតជាក់    ហឫទ័យដំពាក់    ករុណាចំពោះ
លោកិយកើតស្លាប់    លិចជាប់ជ្រៅជ្រោះ    ចិត្តចង់សង្គ្រោះ
ឲ្យរួចពល់ប្រាណ ។

ទី ៣ ទ្រង់ធម៌    មុទិតាបវរ    ក្នុងខ្លួនសន្តាន
ស្រទន់ស្រទាប    រៀងពបឥតខាន    ញញឹមកប់អាន
រីករាយរកសត្វ ។

ទី ៤ កាន់គិត    ឧបេក្ខាចិត្ត    ឥតបីបង់បាត់
រំពៃរំពឹង    សំឡឹងសព្វសត្វ    ប្រិតប្រុងប្រយ័ត្ន
ប្រយោជន៍ដោះស្រាយ ។

សត្វដើរខុសផ្លូវ ណែនាំតម្រូវ ឲ្យត្រូវតម្រាយ
ពុទ្ធពង្សអតីត ព្រេងព្រឹទ្ធយូរឆ្ងាយ ឆ្ពោះបានសប្បាយ
សុខក្សេមប្រពៃ ។

ព្រហ្មអើយព្រហ្មថ្ន តំណាងព្រះធម៌ ទាំង ៤ នោះនៃ
ផ្សព្វផ្សាយអំពី ពោធិសត្វថ្លៃ តម្រង់ត្រង់ៗ
ពិភពកើតស្លាប់ ។

ព្រះភក្ត្រញញឹម ព្រោះមានសង្ឃឹម បានត្រាស់ដឹងដាច់
ប្រោសសត្វគ្រប់ប្រាណ ដាក់បានគួរគាប់ រួចផុតពាក់ដាច់
អន្ទង់អវិជ្ជា ។

ព្រហ្មអើយព្រហ្មប្រាជ្ញ បុរាណបានសាង តាំងពីយូរយារ
បង្ហាញទឹកចិត្ត ខ្ពស់ឥតគណនា វប្បធម៌កម្ពុជា
សម័យអង្គរ ។

---

ប្រាង្គណ៍បាយ័នលោកសាងជាប្រាង្គណ៍មូល
មានកំពូលប្រាង្គណ៍បេញជាបួនមុម
ក្នុងកំពូលមួយៗ ឆ្លាក់រូបព្រហ្ម
បួន ៗ ជុំគ្រប់ប្រាង្គណ៍ប្រូងប្រាងក្រៃ ។

(និភសនគរវត្ត-ចកញ៉ាសុត្តន្តប្រីជា ឥន្ទ)

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( តពីលេខ ៥ ឆ្នាំ ១៩៦៦ )

បំណងរឿង "ព្រះនិព្វានសូត្រ[១]"

អ្នកនិពន្ធ *រកពុំបានឃើញ ។*

កាលបរិច្ឆេទ *គ្មានបញ្ជាក់ក្នុងអត្ថបទ ។*

របៀបនិពន្ធ *ពាក្យកាព្យ : លំនាំទេសនា ។*

ប្រភពរឿង *ព្រះជីវប្រវត្តិនិងការបំពេញពុទ្ធកិច្ច ។*

លក្ខណៈឯកសារ *សាស្ត្រាស្លឹករឹត មាន ៥ ខ្សែ គឺខ្សែទី ១ មាន ២៣ សន្លឹក ខ្សែទី ២ មាន ២៦ សន្លឹក ខ្សែទី ៣ មាន ៣០ សន្លឹក ខ្សែទី ៤ មាន ២៩ សន្លឹក ខ្សែទី ៥ មាន ១៧ សន្លឹក ។*

*ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តខ្មៅ ខេត្តបាត់ដំបង ចុះលេខ ៨៦២ ។*

---

១ អត្ថបទ និព្វានសូត្រនេះ អ្នកនិពន្ធមិនបានថ្លែងរៀបរាប់អំពីដំណើរចូលព្រះនិព្វាន នៃព្រះពុទ្ធជាម្ចាស់ទេ គឺគេបានរៀបរាប់អំពីព្រះពុទ្ធកិច្ចផ្សេងៗ តាំងអំពីកាលព្រះអង្គទើបបានត្រាស់រហូតដល់ចូលនិព្វាន ។ ឯក្នុងខ្សែទី ៥ គ្មាននិយាយទាក់ទងអំពីរឿងរ៉ាវព្រះពុទ្ធជាម្ចាស់ទេ គឺគេថ្លែងអំពីព្រះមហាកស្សបត្ថេរ ចូលនិព្វានទៅវិញ រហូតដល់ព្រះស្រីអារ្យមេត្រីចុះមកត្រាស់ ទើបព្រះអង្គលើកព្រះសពព្រះមហាកស្សបត្ថេរចូលបូជា រួចបញ្ចុះក្នុងព្រះចេតិយ ។

អត្ថបទផ្ដើម នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
ឯវំ ភគវា មាតុយា គុណបច្ចុបករណត្ថាយ តេមាសេ
តាវតឹសភវនេ បារិច្ឆត្តកមូលេ ។ល។ ភគវា រីអង្គសម្ដេច
ព្រះដ៏មានព្រះភាគ កាលព្រះអង្គ ស្ដេចឡើងទៅចាំព្រះវស្សា
លើថ្មបណ្ឌុកម្ពលសិលាអាសន៍ ក្រោមម្លប់បារិច្ឆត្តកព្រឹក្សា ឰដ៏
ពិភពត្រៃត្រឹង្ស ត្រាស់ទេសនាព្រះសត្តបករណាភិធម្ម តាំង៧
គម្ពីរ សងព្រះគុណនៃសម្ដេចព្រះជននី ពុទ្ធមាតា គ្រប់ត្រៃមាស
៣ ខែហើយ . . . ។ល។

អត្ថបទបញ្ចប់ ទើបសម្ដេចព្រះអរិយមេត្រីជាអម្ចាស់ ស្ដេចចូលទៅលើក
ព្រះសពនៃព្រះមហាថេរនោះឡើង តំកើងលើបាតព្រះហស្ដ
បង្ហាញអស់បរិស័ទទាំងពួង ឲ្យបានឃើញជាក់ច្បាស់ពល់គ្នា
ស្រេចហើយ ៗ គ្រានោះមិនយូរឡើយ តេជោធាតុ ក្នុងព្រះ
សរីរនៃព្រះមហាថេរនោះ ក៏ឆេះឡើង សង្ខារសពនោះអស់
ទៅ នៅសល់តែបរមធាតុ ទើបបរមលោកនាថ អរិយមេត្រី
ជាអម្ចាស់ ស្ដេចឲ្យកសាងចេតិយបញ្ចុះទុកឲ្យអស់លោកទាំងពួង
ធ្វើសក្ការបូជាតទៅហោង ៗ អយំ មហាកស្សបត្ថេរស្ស និព្វាន-
កថា និដ្ឋិតា ៗ គាត្ថាកាពស់ដៃព្រះធម៌ទេសនា ក្នុងអាចិសេចក្ដី

នៃព្រះមហាកស្សបត្ថេរ ចូលនិព្វានក្នុងភ្នំកុក្កុដសម្បាតបព៌តនេះមិញ សូរទៅតែប៉ុណ្ណោះ ។ ឯវំ ក៏សមគួរដោយទូវវេលានេះឯង ហោង ។

+ + +

បំណងជើង "ព្រះសមោធាននិព្វានធាតុ(១)"

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យរាយ: លំនាំទេសនា ។

ប្រភពរឿង ថ្លែងអំពីព្រះពុទ្ធប្រវត្តិដោយសង្ខេប ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ផ្សែ មាន ២៤ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តខ្មៅ ខេត្ត បាត់ដំបង ចុះលេខ ៨៦២ ។

---

១ អត្ថបទ សមោធាននិព្វានធាតុនេះ ពណ៌នាដោយសង្ខេបអំពីពុទ្ធប្បវត្តិ តាំងអំពីកាលព្រះអង្គច្យុតចាកឋានតុសិត មកចាប់បដិសន្ធិនាឋានមនុស្សលោក រួចបានត្រាស់-បានបំពេញពុទ្ធកិច្ច–ទ្រង់ចូលនិព្វាន ហើយសំដែងអំពីអន្តរធាន ៥ ប្រការ ដែលនឹងកើតមានក្នុងកំឡុងចិរវេលា ៥០០០ វស្សា នាអនាគតកាល ។ បញ្ចអន្តរធាន គឺ បរិយត្តិអន្តរធាន ១ បដិបត្តិ-អន្តរធាន ១ បដិវេធអន្តរធាន ១ លិង្គអន្តរធាន ១ ធាតុអន្តរធាន ១ ។

អត្ថបទផ្ដើម នមស្សិត្វាន សម្ពុទ្ធំ ធម្មំ សង្ឃញ្ច សាធុកំ បវក្ខាមិ

សមាសេន . . . ។ ល ។ វេលានេះ អាត្មាភាព

នឹងសំដែង នូវសេចក្ដីនៃព្រះបរមធាតុ សម្ដេចព្រះពុទ្ធអង្គសមោ-

ធានចូលនិព្វាន លើគ្រែបល្លង្ក ក្រោមមណ្ឌលពោធិព្រឹក្ស ដែល

ព្រះអង្គត្រាស់នោះ ជាអនុសន្ធិកថាទៅ ទើបខ្ញុំនឹងសំដែង

បណាមគាថាដើមបទ តាមទំនងពាក្យ នៃព្រះសង្គីតិកាចារ្យ

ទាំងឡាយ . ។ ល ។

អត្ថបទបញ្ចប់ ហៃសប្បុរសជនទាំងឡាយអើយ រីអាថិសេចក្ដីដែល

ខ្ញុំបានសំដែងមកនេះ ឈ្មោះថា ធាតុអន្តរធានហោង ។

បឋមសម្ពោធ្យាទិវសានបញ្ចអន្តរធានំ និដ្ឋិតំ ។ អាត្មាភាព

សំដែងព្រះធម៌វិសេសទេសនា នូវអាថិសេចក្ដីជាសង្ខេប តាំង

អំពីរឿងបឋមសម្ពោធិជាដើម ជាប្រធាន ដរាបមកដល់អន្តរធាន

ទាំង ៥ ប្រការ ជាអវសានទីបំផុតនេះមិញ ។ និដ្ឋិតំ ក៏ចប់

បរិបូណ៌ ។ ឯវំ ក៏សមគួរដោយនូវវេលានេះឯងហោង ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

នូ-កាន

ប្រែរៀបរៀង

(ភាគ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ—អ៊ុន

ក្រឡេកមើលមុខ មើលភ្នែក ឡុកស៊ុន ហើយក៏ស្ងៀមនៅមិនឆ្លើយសោះ ៗ ឡុកស៊ុន ថា ខ្ញុំមានថ្នាំឱសថមួយយ៉ាង នឹងរក្សារោគអ្នកដែលឈឺនេះឲ្យជាសះបាន, អ្នកនឹងឲ្យខ្ញុំដាក់ថ្នាំនេះលមើល ឬ ប្រការម្ដេច? លិបង ឮឡុកស៊ុន ថាដូច្នេះ ក៏បណ្ដេញមនុស្សបម្រើឲ្យចេញទៅក្រៅទាំងអស់ ហើយសួរថា អ្នកនឹងឲ្យថ្នាំខ្ញុំយ៉ាងដូចម្ដេច? ឡុក-ស៊ុន អស់សំណើចហើយថា ជម្ងឺអ្នកនេះ ខ្ញុំដឹងថា ព្រោះហេតុតែស្រុកកេងជីវឲ្យពោស, ដោយខ្ញុំឮគេថា វេលានេះ គេកំពុងបម្រុងរៀបទាហាន ហើយធ្វើភ្លើង ពាយ័ហៃក្បែរមាត់ទឹកវៀងទៅ ដើម្បីនឹងការពារស្រុកគេជាមាំមួនណាស់ បានជាអ្នកបង្កើតបរិវិតក្កជាទុក្ខព្រួយឲ្យកើតជារោគក្នុងចិត្ត ដ្បិតរឿងនេះឯង, ខ្ញុំនៅមានថ្នាំមួយ ជាឧបាយជម្រះរោគនេះបាន គឺត្រូវធ្វើឲ្យទាហានស្រុកកេងជីវ ដែលធ្វើការ

រក្សាស្រុកនោះ ឲ្យមកចំណុះចុះចូលដល់អ្នក មិនឲ្យលំបាកឡើយ, តើអ្នកនឹងឃើញប្រការម្ដេច ? ។

លិបង បានឮឡុកស៊ុននិយាយដឹងដល់គំនិតរបស់ខ្លួន ដោយល្បិចដូច្នោះ ក៏គួរឲ្យភ័យស្លុតក្នុងចិត្ត, ទើបសួរថា ចុះផ្លូវជាឧបាយរបស់អ្នកដែលនឹងគិតឲ្យពួកអ្នកស្រុកកេងជីវមកចំណុះយើងនោះ តើដោយប្រការយ៉ាងដូចម្ដេច ? ។ ឡុកស៊ុនឆ្លើយថា អ្នកស្រុកកេងជីវដែលបានប្រុងប្រៀបរៀបចំបម្រុងទាហាន ព្រមទាំងមានការបាត់បែងស្រុកទុកដូចម្ដេចៗនោះ មកពីគួនអ៊ូមានសេចក្ដីព្រួយបារម្ភនឹងអ្នក ដែលមកតាំងនៅទីនេះ ហើយមិនទុកចិត្ត, បើអ្នកដឹងឧបាយហើយធ្វើជាឈឺដើរចេញពីទីនេះទៅ ចាត់តម្រូវឲ្យអ្នកឯទៀតមកឈរជំនួសអ្នកវិញ ហើយឲ្យបញ្ចេញបរិហារសំដីនិយាយសរសើរគួនអ៊ូ ។ ក៏នឹងទ្រទន់ចិត្ត គិតតែប្រាំងយកស្រុកអ៊ូនសៀឲ្យបាន មិនមាននឹករាំងទៅខាងក្រោយទេ ទើបយើងនឹងគិតគេចត្រឡប់ ទៅវាយយកស្រុកកេងជីវឲ្យបានដោយងាយ ។ លិបងឮដូច្នោះ ក៏សប្បាយក្នុងចិត្តណាស់ និយាយនឹងឡុកស៊ុនថា ឧបាយរបស់អ្នកយ៉ាងនេះល្អណាស់ ។ លិបង ក៏នៅតែធ្វើជាឈឺដូចដែល ទើបឲ្យឡុកស៊ុននាំសំបុត្រ ១ ច្បាប់ ទៅជំរាបស៊ុនគួនថា ខ្ញុំបាទ លិបង នឹងសុំលាទីពជការចេញហើយ ។ ឡុកស៊ុន ក៏នាំយកសំបុត្រនោះទៅជំរាបស៊ុនគួនតាមការ ។

ស៊ិនគួន លុះដឹងដំណឹងតាមសំបុត្រហើយ ក៏ឲ្យហៅលិបង៍ត្រឡប់មកវក្សាខ្លួនដែលមានជម្ងឺ, លិបង៍ ក៏ចូលមកជួបនឹងស៊ិនគួន ៗ និយាយថា កាលពីដើម ដីវ៉េ និយាយនឹងយើងឲ្យតាំង ឡោស៊ុក ចេញទៅឈរនៅទីគយឡុកខៅ, លុះនៅយូរមក ឡោស៊ុក មកនិយាយថាឲ្យតាំងខ្លួនអ្នកឯងចេញទៅឈរជំនួសទៀត, ឥឡូវ ត្រូវអ្នកឯងមានជម្ងឺដូច្នេះ ក៏គួរឲ្យយើងនឹងពាក់មនុស្សឯទៀត ដែលមានតម្រិះប្រាជ្ញាចេញទៅឈរជំនួសខ្លួនអ្នកឯងវិញ ។ លិបង៍ ថា ដែលលោកនឹងរើសមនុស្សល្អ ឲ្យចេញទៅឈរជំនួសខ្ញុំបាទនោះ ខាងគួនអ៊ូក៏មិនទុកចិត្តគង់នឹងគិតប្រើងវក្សាស្រុកទុកយ៉ាងមាំមួនណាស់, ឯឡុកស៊ុននោះសោតនៅមិនទាន់ប្រាកដកេរ្តិ៍ឈ្មោះពុំពាក់ពិសាអ្វីនៅឡើយ, គួរលោកពាក់ប្រើឲ្យទៅឈរជំនួសខ្ញុំបាទចុះ, គួនអ៊ូ នឹងធ្វេសប្រមាទមិនរវាំងក្រោយទេ មុខជាចេញពាលស្រុកគេងដីវ៉ឲ្យនៅទំនេរ យើងនឹងវាយយកបានដោយស្រួល ។

ស៊ិនគួន ឮដូច្នោះ ក៏ពេញចិត្តណាស់ ទើបតាំង ឡុកស៊ុន ជានាយកងទ័ពធ្វេង ឲ្យទៅឈរវក្សាបន្ទាយឡុកខៅ ជាជំនួសលិបង៍ ។ ឡុកស៊ុន ថា ខ្ញុំបាទនៅក្មេងសេចក្តី ខ្ញុំគំនិតប្រាជ្ញា មិនដឹងការអ្វីសោះ ដែលលោកថា នឹងប្រើខ្ញុំបាទទៅឈរវក្សាបន្ទាយឡុកខៅនោះ ឃើញដូចមិនសមគួរសោះ ។ ស៊ិនគួន ថា លិបង៍ គេប្រាប់យើងថា ទៅ

មានគម្រិះប្រាជ្ញាជ្រៅទូលាយណាស់ មុខជាបានការពេជការខ្ទះមិនខាន, បើដូច្នេះ ត្រូវតែទៅចុះ កុំធ្វើឲ្យទាស់ខុសពីគំនិតដែលយើងគិតទៅហើយនោះឡើយ ។ ឡុកស៊ិន មិនហ៊ានរឹងទទឹង ក៏ទទួលយកត្រាចេញទៅឈរក្រោយបន្ទាយឡុកទៅ ។

លុះដល់មកថ្ងៃមួយនោះ ឡុកស៊ិន ក៏ប្រើមនុស្សឲ្យនាំសំបុត្រនិងគ្រឿងបណ្ណាការទៅគំនាប់ គួនអ៊ូ ថា ឥឡូវ ស៊ិនគួន ប្រើខ្ញុំបាទឲ្យចេញមកឈរក្រោយបន្ទាយឡុកទៅ ជំនួសលិបងហើយ, ខ្ញុំបាទទទឹងមិនបាន បានជាចេញមកឈរនៅទីនោះ, សូមលោកបានជាទីពឹងខ្ញុំបាទផងចុះ ។ គួនអ៊ូ ក៏សួរអ្នកកាន់សំបុត្រនោះថា លិបង ដែលមកឈរមុននោះ ឥឡូវទៅណាហើយ ? អ្នកកាន់សំបុត្រនោះឆ្លើយថា លិបង ឈឺ វិលទៅនៅមើលខ្លួនឯងស្រុកកាំងតាំង បានជាឲ្យ ឡុកស៊ិន មកឈរជំនួស ។ គួនអ៊ូ ថា ស៊ិនគួននោះ ជាមនុស្សបេះដូងត្រឹមត្រូវណាស់ ហេតុម្តេចបានជាប្រើកូនក្មេង ឲ្យមកឈរក្រោយបន្ទាយដូច្នោះ ? អ្នកកាន់សំបុត្រនោះថា ឡុកស៊ិន ឲ្យខ្ញុំបាទនាំសំបុត្រនិងបណ្ណាការទាំងអស់នេះ មកគំនាប់ជូនលោក ដើម្បីសូមឲ្យលោកទាំងសងខាងជាមេត្រីនឹងគ្នាទៅវិញទៅមក, សូមឲ្យលោកព្រមទទួលយករបស់ទាំងនេះឲ្យមានចុះ ។

គួនអ៊ូនោះ លុះដឹងថា ឡុកស៊ិន បន្អោនខ្លួន ជូនរបស់ទ្រព្យ និងសំបុត្រ ចូលមកដើរខ្លួនប្រណាដូច្នោះ ក៏អស់សំណើច ហើយឲ្យបាវព្រាវ

ទទួលយកដំឡូននោះទៅទុក ។ អ្នកកាន់សំបុត្រ លាត្រឡប់ទៅប្រាប់ឡុកស៊ុន ថា គួនអ៊ូ មានសេចក្ដីត្រេកអរសាទរណាស់ មុខជានឹងជឿទុកចិត្ត គិតថា ស្រុកកាំងតាំង មិនប្រុងនឹងវាយយកស្រុករបស់ខ្លួនទេ ។ ឡុកស៊ុន សប្បាយចិត្តណាស់ ទើបចាត់ទាហានឲ្យចេញទៅស៊ើបស្ដាប់ការណ៍ ដឹងថា កួងស្រុកកេងជីវនោះ គ្មានប្រុងប្រៀបរៀបចំទាហានជាមួនមាំទេ មានតែគិតលើកទាហានទៅវាយយកស្រុកអ៊ួនសៀ ហើយឃើញថា គួនអ៊ូ នឹងទៅវង់ឲ្យរបួសព្រួយនោះសះជាសិន ទើបនឹងលើកទ័ពចូលទៅវាយយកស្រុកអ៊ួនសៀតែម្ដង, ឡុកស៊ុន ក៏នាំយកពត៌មាននោះ ទៅថ្លឹងជម្រាបឲ្យស៊ុនគួនជ្រាបគ្រប់ប្រការ ។

ស៊ុនគួន ក៏ប្រឹក្សានឹងលិបម៉ងថា ឥឡូវគួនអ៊ូ គ្មានមន្ទិលពិតាល់ដល់ស្រុកយើងទេ បេះតែលើកទាហានទៅបំពេញ ដើម្បីនឹងតាំងចិត្តគិតវាយយកស្រុកអ៊ួនសៀឲ្យបាន, យើងគិតថា នឹងឲ្យអ្នកហើយនឹងស៊ុនកៀវជាកូនមាខ្ញុំ លើកទ័ពទៅវាយយកស្រុកកេងជីវ, តើអ្នកនឹងយល់ឃើញប្រការម្ដេច ? ។ លិបម៉ង ថា បើលោកនឹងប្រើ ស៊ុនកៀវ និង ខ្ញុំបាទទៅធ្វើការជាមួយគ្នានោះ ខ្ញុំបាទ យល់ឃើញថាមិនស្រួលសោះ, តែថាបើលោកនឹងឲ្យស៊ុនកៀវទៅ ក៏ឲ្យទៅតែឯងចុះ, លោកចាំមិនបានទេឬ? កាលគ្រាលោកប្រើ ជីវយី និង ធៀផៅ ដែលជាមនុស្សចាស់របស់លោក ជាមេទ័ពធ្វើស្ដាំឲ្យទៅធ្វើការជាមួយគ្នានោះ, ឯជីវយីជាមនុស្ស

មានសតិបញ្ញា ទឹងថាអ្វី ៗ បានទាំងអស់, ធៀផៅ ដែលជាមេទ័ពច្រើន គឺបង្អោនខ្លួនស្តាប់បង្គាប់ជីវយី ទើបធ្វើការផងគ្នាបាន, ឥឡូវលោកទឹងឲ្យខ្ញុំបាទទៅជាមួយទឹងស៊ុនគៀនោះ ប្រាជ្ញាខ្ញុំបាទមិនបានដូចជីវយី ទោះបីទឹងនិយាយកិច្ចការអ្វី ៗ ក៏មុខជាមិនស្រួល ព្រោះស៊ុនគៀនោះ ជាសាច់ញាតិទឹងលោក គេមានបញ្ញាច្រើនទ្វាសណាស់, សុំលោកចាត់ប្រើស៊ុនគៀឲ្យទៅម្នាក់ឯងចុះ គង់តែទឹងធ្វើការបាន មិនមានទាស់ទែងសោះឡើយ ។

ស៊ុនគួន បានឮលិបងនិយាយដូច្នោះហើយ ក៏ត្រឡប់គិតឃើញផង ទើបតាំងឲ្យលិបងជាមេទ័ពធំ ជាងនាយទាហានក្នុងអាណាខេត្ត ស្រុកកាំងតាំង សម្រាប់គិតការសឹកសង្គ្រាមទាំងពួង ហើយតាំងស៊ុនគៀឲ្យជានាយទាហានកងស្បៀង នៅក្នុងបង្គាប់លិបង ។ លិបងគំនាប់ស៊ុនគួនហើយ ក៏ប្រមូលពលទាហានបាន ៣ ម៉ឺន ឲ្យជាពួកពួនបង្កប់ក្នុងទូក ៨០ ហើយឲ្យទាហានដែលស្ទាត់ជំនាញក្នុងក្បួនទូកនោះ ពាក់អាវសធ្វើកេវជាកូនឈ្នួលជឆ្នៅ សម្រាប់ចែវទូក ទើបចាត់ឲ្យហានតុង, ជីវថាយ, ជីវយឹម, ជូហៀន, គួងជៀង, ឈីសេង, តេងហង ជានាយទាហាន ៧ នាក់ ប្រៀបប្រុងបម្រុងខ្លួនឲ្យព្រម ទឹងលើកទៅវាយយកស្រុកកេងជីវ, ឯទាហានក្រៅពីពួកដែលចុះទូកទៅនោះ ត្រូវទុកជាទ័ពជំនួយ ចាំលើកទៅជាមួយទឹងស៊ុនគួន ៗ លុះចាត់ចែងទាហានទាំងពួងរួចហើយ ស៊ុនគួន

កំមានសំបុត្រទៅដល់ចូចូ ឲ្យលើកកងទ័ពប្រញាប់ ត្រឡប់ទៅកាយទ័ព គួនអ៊ូ ដែលតាំងនៅស្រុកអ៊ូនសៀនោះឲ្យបាន ហើយឲ្យបម្រើទៅប្រាប់ ឲ្យកស៊ុនថា ឥឡូវ ការដែលគិតគ្នាទុកនោះ យើងបានបម្រុងទាហានទុកព្រមហើយ ឲ្យអ្នកស្រុកចាត់ចែងឲ្យស្រេចចុះ ហើយលើកទ័ពទូកចេញទៅតាមទន្លេជំមអៀង ត្រង់ទីកាន់កើងនៅតំបន់ហែទៅ ។

ឯទាហានល្បាតស្រែកសួរថា ពួកនេះមកពីណា? ទាហានលិបងឆ្លើយថា យើងជាកូនឈ្មួញដឹកស្រៅសំពៅ ត្រូវខ្យល់ព្យុះបក់ផាត់សាត់មក ។ លិបង កំឲ្យយកទ្រព្យទៀងទៅចែកឲ្យទាហានចាំកាន់កើង ។ ពួកចាំកាន់កើង កំជឿប្រាកដឲ្យចតទូកសម្រាកនៅទីនោះ ។ លុះពេលប្រហែលម៉ោង ១ យប់, លិបង ឲ្យទាហានពួកទូកនោះ ឡើងទៅចាប់ពួកអ្នករក្សាកាន់កើងនោះ ចុះដាក់ក្នុងទូកទាំងអស់គ្រប់កាន់ ហើយចែវទូកចូលទៅដល់ស្រុកកេងជិវ ក្នុងពេលកណ្ដាលយប់នោះ ឥតមាននរណាទឹងអាចដឹងថា លិបង លើកទ័ពចូលទៅសោះ, លិបង កំល្បួងយកចិត្តទាហានដែលចាប់បាននៅពីកាន់កើងថា អស់អ្នកពល់គ្នា ចូរនៅធ្វើជាការសឹកជាមួយនឹងយើងចុះ យើងនឹងឲ្យបំណាច់រង្វាន់ឲ្យពេញចិត្ត ហើយប្រើឲ្យហៅពួកអ្នកស្រុក ដែលជាគូកននឹងគ្នានោះ ឲ្យបើកទ្វារស្រុកទទួល ។

ឯខាងទាហានក្នុងស្រុកនោះ មិនទាន់ដឹងថាជាពួកសត្រូវ គិតថាជាគូកនជាមួយគ្នា កំបើកទ្វារទទួលឲ្យចូលទៅ ។ លិបង ឃើញដូច្នោះ

កំដេញទាហានឲ្យចូលទៅ ហើយស្រែកហៅកញ្ជៀវ យកភ្លើងដុតផ្ទះ ឡើង នឹងរកអ្នកឯណាតស៊ូច្បាំងគ្នាគ្មានសោះ ៗ វេលានោះ លិបង ក៏យកស្រុកកេងដីបានដោយងាយ, លិបង ក៏ឲ្យប៉ាវគងដល់ពួកកងទ័ព ទាំងអស់ថា បើនរណាអង់អាចកាចសាហាវទៅកាប់សម្លាប់អ្នកស្រុក ឬធ្វើ ទុក្ខបុកម្នេញ ដេញទក់ដណ្តើមយករបស់ទ្រព្យ រឹបកតត្បាតពស្ត្រ ឲ្យ បានសេចក្តីក្តៅក្រហាយ យើងនឹងយកទោសអ្នកនោះដល់ជីវិត ៗ ឯ បណ្តានាម៉ឺនមុខមន្ត្រីទាំងប៉ុន្មាន ដែលមានក្នុងស្រុកកេងដីនោះ ក៏ ទំនុកបម្រុងឲ្យគង់យសសក្តិនៅដូចដែលគ្រប់តំណែង, ឯបណ្តាកិរិយា បុត្រគួនអ៊ូនោះ លិបង ក៏ឲ្យមនុស្សនៅពិតក្តិរក្សាជាទិន្នន្ត មិនមាននរណា អាចទៅបៀតបៀនឲ្យមានសៅហ្មងឡើយ ៗ លិបងនោះ លុះបាន ស្រុកកេងដីហើយ ក៏ប្រើបម្រើឲ្យនាំសំបុត្រ បកទៅដល់ស៊ុនគួនថា វេលានេះ ខ្ញុំបាទ វាយយកបានស្រុកកេងដីហើយ សូមអញ្ជើញ លោកលើកកងទ័ពទៅចុះ ៗ

លុះកន្លងមកក្នុងថ្ងៃមួយនោះ លិបង ជិះសេះចេញទៅត្រួតត្រាមើល ស្រុកភូមិ ស្រាប់តែមានក្មៀងរំលាធំណាស់ ក្រឡេកទៅឃើញទាហាន ម្នាក់ចូលទៅឆក់ដណ្តើមយករបស់ទ្រព្យអ្នកស្រុក, លិបង ក៏ឲ្យចាប់យក ខ្លួនទាហាននោះទៅសួរថា ឯងជាពួកនរណា ម្តេចក៏ហ៊ានមកធ្វើដូច្នេះ?

(នៅមានត)

# លុយនៅប្រទេសខ្មែរ

ស្រាវជ្រាវ ដោយលោក ឌឹក-គាម

## លំនាំដើម

ឯកសារដំស្តួចស្តើងនេះ ខ្ញុំមិនគួរយកមកចុះក្នុងទំព័រទស្សនាវដ្តីកម្ពុជសុរិយាសោះ តែដោយមានលោកអ្នកស្រាវជ្រាវរកមើលឯកសារស្តីអំពីលុយ ដែលមានចាយនៅប្រទេសខ្មែរយើងនេះញឹកញាប់ពេក ខ្ញុំអត់ទ្រាំមិនបាន ទើបយកមកចុះក្នុងកម្ពុជសុរិយានេះ ដើម្បីឲ្យលោកអ្នកដែលចង់ជ្រាប បានឃើញ បានយល់ខ្លះផង ។ ឯកសារនេះ ខ្ញុំមិនបានតាំងចិត្តថា អស់ត្រឹមណេះទេ នៅមានច្រើនតទៅទៀត ។ ខ្ញុំរកឃើញត្រឹមណា ខ្ញុំចុះជូនបណ្តើរ ៗ ត្រឹមនោះ ។

ខ្ញុំសូមអភ័យទោសពីលោកអ្នក ដែលមានឯកសារ ឬរូបិយវត្ថុផ្ទាល់ ដែលខ្ញុំមិនដែលបានឃើញ បើឃើញថា អត្ថបទឯកសារនេះមិនសមរម្យទេ សូមមេត្តាជួយបំពេញ បំភ្លឺឲ្យខ្ញុំបាទផង ព្រោះការស្រាវជ្រាវរបស់ខ្ញុំពេលនេះ ទុកជាជំហានទីមួយ ឬ ពិសោធសិនទេ ។

xxx

## ជំពូកទីមួយ

### លក្ខណៈលុយ

ពិតមែនតែប្រទេសខ្មែរយើង បានតាំងសិប់ជាអាណាចក្រឡើងមាននៅក្នុងផែនដីពិភពលោកយូរណាស់មកហើយ ប៉ុន្តែប្រហែលជាពល-

រដ្ឋខ្មែរយើង នៅមិនទាន់ចេះលុយចាយនៅឡើយទេ ។ សម័យដែលខ្មែរយើង មិនទាន់ចេះលុយចាយនោះ ខ្មែរយើងទិញ ឬ លក់ទំនិញដោយប្រើវិធី " ដូរ " ដែលបារាំងហៅថា « Le troc »(១) ។

តាមន័យដែលថា " ដូរ " នេះ យើងមិនបាច់រកមើលទៅឆ្ងាយទេ សូម្បីតែនៅក្នុងសតវត្សរ៍នេះ ក៏មានការដូរដែរ ។ តែខ្ញុំបានឃើញផ្ទាល់នឹងភ្នែកនៅស្រុកខ្ញុំ ( ចំបក់ ធ្នង ខេត្តក្រចេះ ) ខ្ញុំនៅពីក្មេង ចង់បានស្ករគ្រាប់ ត្រូវយកពោតទុំ ទៅដូរយកស្ករគ្រាប់ ចង់បានថ្នាំង ក្អម ត្រូវយកគ្រាប់ពោត ទៅចាក់ឲ្យពេញថ្នាំង ក្អម ដែលត្រូវការនោះ ។ ខ្លះយកក្របី ទៅដូរនឹងគោ ខ្លះយកគោទៅដូរនឹងស្រែចំការ ។

តាមសេចក្តីកត់ត្រារបស់អ្នកប្រាជ្ញចិន "ជីវតាក្វន" ថា នៅប្រហែលរវាងសតវត្សរ៍ទី ១៣ ចិនបាននាំសំលៀកបំពាក់មកដូរនឹងមាសប្រាក់ ឬ វត្ថុដែលមានតម្លៃ ដូចជាក្រកជាដើម នៅប្រទេសខ្មែរ ។ តាមសេចក្តីកត់ត្រារបស់អ្នកប្រាជ្ញចិននេះ សឲ្យឃើញថា ប្រទេសខ្មែរយើងពីដើម សម្បូណ៌មាសប្រាក់ បានជាយកវត្ថុទាំងនេះ ទៅដូរនឹងទំនិញ ។

តាមឯកសាររបស់លោក Lt Bonifacy ថាអ្នកជំនួញនៅឥណ្ឌូចិនត្រូវដូរ ឬទិញទំនិញ ដែលខ្លួនត្រូវមានដូចជាសត្វពាហណៈ ដីធ្លីជាដើមទៅនឹងវត្ថុដែលខ្លួនមិនមាន ហើយដែលខ្លួនត្រូវការវត្ថុនោះ (២) ។

---

១— Archéologie du Delta du Mékong Tome III, et Mœurs et Coutumes khmères par Tcheou Takoun. ២— Lt Bonifacy, Cours d'Ethnograhie Indochinoise P. 48

ប្រទេសខ្មែរយើង មុនសម័យដែលមិនទាន់បោះលុយចាយ យើងឃើញមានចាយលុយបរទេសជាច្រើនបែប ។ ការដែលយើងយកលុយបរទេសមកចាយ ព្រោះនគរក្រុងកម្ពុជាសម័យនោះ មានការទាក់ទង ជាមួយនឹងបរទេសតាមផ្លូវសេដ្ឋកិច្ច ។ បើយើងមានការទាក់ទងខាងសេដ្ឋកិច្ច ដូចជាសេដ្ឋកិច្ចជាមួយប្រទេសជប៉ុន យើងមុខជាមានលុយជប៉ុនមកចាយនៅប្រទេសយើង ។ តែសម័យសព្វថ្ងៃនេះ ប្រទេសខ្មែរ បានឯករាជ្យបរិបូណ៌ខាងសេដ្ឋកិច្ច ហើយមានតាំងវិជ្ជាបានបោះលុយចាយត្រឹមត្រូវតាមច្បាប់អន្តរជាតិ លុយបរទេស លែងចូលមកចាយនៅក្នុងប្រទេសយើងជាផ្លូវការទៀតហើយ តែនរណាចាយលុយក្រៅពីលុយខ្មែរ អ្នកនោះទុកជាជាមនុស្សគេគយ ។

ប្រទេសកម្ពុជាយើង យ៉ាងហោចណាស់មានលុយចាយសំរាប់ប្រទេសយើង តាំងពីសតវត្សរ៍ទី ១៥ម្ល៉េះ ។ លោក (G.Groslier) ថា " តាមឯកសារដែលគេឃើញថា នៅសតវត្សរ៍ទី ១៣ ខ្មែរមិនទាន់បោះលុយចាយទេ ខ្មែរចាយពាយ ឬ ទិញតែស្មើ ១ ដោយវិធី " ប្តូរទំនិញ " ។

តាមពង្សាវតារខ្មែរ មិនឃើញមានឯកសារជាភាសាខ្មែរស្តីអំពីលុយទេ មានតែតាមឯកសារជាភាសាបរទេសខ្លះថា ស្តេចខ្មែរយើងបោះលុយចាយតាំងពីដើមសតវត្សរ៍ទី ១៦ ។

លោក A. LecLère ថា ស្តេចកន[1] ( ១៤៩៨ - ១៥០៥ ) ជា

1— A. Leclère, Histoire du Cambodge p. 251.

ស្តេចខ្មែរទី ១ ដែលបានបោះលុយចាយមុនគេហៅថា លុយស៊ឹងមាស មានរូបនាគជាសញ្ញា ។ បើយើងពិនិត្យមើលឯកសារ របស់លោក R. Le May និងលោក G. Groslier ថាព្រះបាទសត្ថាទី ១ បានបោះលុយមួយបែប ចាយនៅក្នុង គ.ស. ១៥៩៥ (1) តែបើយើងយកគ្រិស្ត-សកពជ ស្តេចកន មកប្រៀបធៀបជាមួយផង ឃើញថា ស្តេចកន ជាស្តេចទី ១ អ្នកបោះលុយចាយ ។

លុយស៊ឹងមាស ដែលមានរូបនាគជាសញ្ញានេះ អ្នកប្រាជ្ញខ្លះថា ជាសញ្ញាពស់ ខ្លះថាសញ្ញានាគ ព្រោះសញ្ញាទាំងពីរនេះ មានសណ្ឋានស្រដៀងគ្នា ។

ក្រៅអំពីលុយខាងលើនេះ យើងឃើញមានលុយមួយបែបទៀត ដែលមានចាយគឺលុយស្តោរឬមាសស្តោរ ប្រើនៅប្រទេសកម្ពុជា ។ តែលុយមាសស្តោរនេះ មានចាយមិនយូរប៉ុន្មាន ក៏គេឈប់លែងចាយទៅ ។ មាសស្តោរមានទម្ងន់ដូចជាប្រាក់ណែនដែរ ហើយមានតារជាអក្សរចិន ។ ផុតមាសស្តោរនោះបាត់ទៅ មានមាសសន្ទឹកមួយទៀត ដែលមានទម្ងន់១ តាអែល ។ លក្ខណៈលុយដែលឃើញចាយនៅស្រុកខ្មែរ មុនចាយប្រាក់ក្រដាសគឺៈ

១– ប្រាក់

២– ស្ពាន់

៣– ស្ពាន់ក្រឡៃប្រាក់ ( នៅមានត )

1— R. Le May The Coinage of Siam P. 7 et G. Groslier

# ផ្នែកកំណត់និងប្រវត្តិការណ៍

លេខ៨៧០-៣ប

## សូមព្រះតេជះតំកល់លើត្បូង

សូមព្រះរាជទានក្រាបបង្គំទូលក្រោមល្អងធូលីព្រះបាទ
នៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត
សូមទ្រង់ជ្រាប ។

តាមរយៈសហជីវិន អនុរដ្ឋលេខាធិការក្រសួងធម្មការ

## សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ ព្រមទាំងបុគ្គលិកជាសហការីទាំងអស់ នៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យនៃក្រសួងធម្មការ, ក្រោយដែលបានទទួលព្រះឱវាទនៃសម្តេចព្រះពោធិវ័ង្ស ហួត-តាត អគ្គាធិការនៃពុទ្ធិកសិក្សាកម្ពុជរដ្ឋ និងជាអធិបតីនៃក្រុមជំនុំព្រះត្រៃបិដក ហើយនិងក្រោយដែលបានទទួលការណែនាំផ្ទាល់ ដោយសេចក្តីអបអរសាទរនៃសហជីវិន ទ្រិញ-ហ៊ីញ អនុរដ្ឋលេខាធិការក្រសួងធម្មការ, បានរួបរួមគ្នា ប្រារព្ធធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃរាជាគណៈ–ឋានានុក្រម រួមទាំងពីរគណៈចំនួន ៣៦ អង្គ ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះពោធិវ័ង្ស និង សហជីវិន ទ្រិញ ហ៊ីញ កាលពីព្រឹកថ្ងៃអាទិត្យ ទី ២៩ ឧសភា ១៩៦៦ នៅនាបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ។ ពិធីបុណ្យនេះ មានគោលបំណងសំខាន់ ដូចតទៅ គឺ :

— រំលឹកដល់ខួបទី ៣៦ នៃឆ្នាំកំណើតវិជ្ជាហ៊ានពុទ្ធសាសនបណ្ឌិត្យ ដែលបានកកើតឡើងពីខែមករា ១៩៣០ ដោយស្នាព្រះហស្តដ៏ខ្ពង់ខ្ពស់បំផុត នៃព្រះករុណាព្រះបាទសម្តេច ព្រះស៊ីសុវត្ថិ មុនីវង្ស ហើយដែលទ្រង់បានសព្វព្រះរាជហឫទ័យ បើកពិធីសម្ពោធជាផ្លូវការ យ៉ាងឧឡារិក នៅថ្ងៃទី ១៦ ឧសភា ១៩៣០ ។

— ថ្វាយព្រះរាជកុសល ចំពោះព្រះវិញ្ញាណក្ខន្ធ នៃព្រះអតីតមហាក្សត្រគ្រប់ព្រះអង្គ ដែលទ្រង់មានព្រះមហាករុណាទិគុណដ៏ធ្ងន់ ចំពោះប្រទេសជាតិ ក្នុងវិស័យនៃវប្បធម៌អក្សរសាស្ត្រ ព្រមទាំងទ្រង់មានព្រះគុណបំណាច់ឧបត្ថម្ភផ្ទាល់ព្រះអង្គ នូវមជ្ឈមណ្ឌលព្រះពុទ្ធសាសនា និង វប្បធម៌ជាតិ គឺ មានព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម, ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ, ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស, ព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត និង សម្តេចក្រុមព្រះវរបក្សរ៍ណារីវ្ធ នរោត្តម សុជាតេ ជាដើម ។

— ថ្វាយព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភ និងជាព្រះមាតានៃវប្បធម៌ សិល្បៈ និងអារ្យធម៌ជាតិ ព្រមទាំងចំពោះសម្តេចព្រះឧបយុវរាជ ព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ ។

— ថ្វាយព្រះរាជកុសល – ជូនកុសល ចំពោះកវី អ្នកប្រាជ្ញ

កជបណ្ឌិត ទាំងបព្វជិតទាំងគ្រហស្ថ (ពោះធ្វើមរណកាលទៅហើយ ឬ មានជន្មាយុនៅឡើយ) ដែលបានខិតខំបំរើវិស័យព្រះពុទ្ធសាសនា វប្បធម៌ និងអក្សរសាស្ត្រជាតិ មានសម្តេចព្រះសង្ឃរាជជាក់ទី ១ គណៈមហានិកាយ និង សម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ជាប្រធាន ។

– ជូនកុសលចំពោះវិញ្ញាណក្ខន្ធនៃបុព្វបុរសជាយុទ្ធជន អ្នកស្នេហាជាតិ ដែលបានបាត់បង់ជីវិតលើសមរភូមិ ដើម្បីការពារប្រទេសជាតិ មាតុភូមិ តាំងពីបុរាណសម័យ រហូតមកទល់សព្វថ្ងៃនេះ ។

## សូមទ្រង់ព្រះមេត្តាប្រោស

ពិធីបុណ្យនេះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ បានសម្រេចកំណត់ ទុកជាប្រពៃណីរបស់វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ដែលនឹងត្រូវធ្វើរៀងរាល់ឆ្នាំតទៅ នៅថ្ងៃទី ១២ ឧសភា នៃសុរិយគតិ ដើម្បីជាសក្ខីភាពនៃកតញ្ញុតា ចំពោះព្រះមហាករុណាធិគុណរបស់ព្រះមហាក្សត្រ និង បុព្វបុរស ដែលមានសគុណចំពោះជាតិសាសនា ព្រះរាជបល្ល័ង្ក ព្រមទាំងជាសញ្ញានៃសាមគ្គីភាពរបស់បុគ្គលិកក្នុងក្រសួង ។

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមលំអុតលំឱនកាយក្រាបបង្គំថ្វាយនូវបុញ្ញកោដ្ឋិដ៏ឧត្តម ដែលកើតអំពីពិធីបុណ្យរាប់បាត្រព្រះសង្ឃពេលនេះ ចំពោះសម្តេចជាអម្ចាស់ជីវិតលើត្បូង សូមព្រះអង្គទ្រង់គង់នៅក្នុងព្រះបរម-

សុខសួស្តី ជោគជ័យមង្គល មហាប្រសើរ មានព្រះជន្មាទីឃាយុជានិរយព្រះវស្សា មានព្រះសុខភាពបរិបូណ៌ ដើម្បីទ្រង់គង់នៅជាមហាម្លប់ដ៏ត្រជាក់ត្រជុំ ពំនាក់ពំនឹងជ្រកកោន នៃបណ្ដាកូនចៅព្រះអង្គ អស់កាលជាអង្វែង គ្រប់ ១ កាល ជានិរន្តរ៍តទៅ ។

គួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ នៅថ្ងៃទី ៣១ ធ្នូ ១៩៦៦

ទូលព្រះបង្គំជាខ្ញុំ លាង - ហ៊ាបអាន

នាយកនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ

អគ្គនាយកដ្ឋាន
នៃ
ក្រសួងនានាក្នុងព្រះបរមរាជវាំង
លេខ ៤០៩ Set

ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញនៅថ្ងៃទី៤មិថុនា គ.ស. ១៩៦៦

អ្នកឧកញ៉ាវាំងវរៈវៀងជ័យ
អគ្គនាយកក្រសួងនានានៃព្រះបរមរាជវាំង
ក្រាបបង្គំទូលមកអ្នកអង្គម្ចាស់ រដ្ឋមន្ត្រីក្រសួងធម្មការ
ភ្នំពេញ ។

សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះរាជហឫទ័យសោមនស្សណាស់ ដោយព្រះអង្គទ្រង់បានទទួលបុតហ្វាយ លេខ ៥៧០ ព.ប. ចុះថ្ងៃទី ៣១ ឧសភា ១៩៦៦ ដែលសហជីវិន នាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ និងបុគ្គលិកសហការីទាំងអស់ នៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការ បានរួបរួមគ្នាធ្វើពិធីបុណ្យខួបទី ៣៦ រំលឹកដល់ឆ្នាំកំណើតនៃវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ក្រោមអធិបតីភាព នៃសម្ដេចព្រះពោធិវង្ស ហួត-តាត និងសហជីវិន ទ្រិញ-វ៉ាញ កាលពីព្រឹកថ្ងៃអាទិត្យទី ២៩ ឧសភា ១៩៦៦ នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ ហើយបានថ្វាយព្រះរាជកុសល និងព្រះរាជសព្ទសាធុការពរ ចំពោះព្រះអង្គ ដែលក្រសួងធម្មការ បានផ្ញើទៅតាមដីកាឥមលេខ ៤១៤ ក.ធ. ចុះថ្ងៃ ៣១ ឧសភា ១៩៦៦ នោះ ។

សម្ដេចជាអម្ចាស់ទ្រង់សព្វព្រះរាជហឫទ័យ ត្រាស់បង្គាប់ឲ្យទូលបង្គំ ថ្វាយនូវព្រះរាជអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះសម្ដេចព្រះពោធិវង្ស សហជីវិន ទ្រិញ-រ៉ាញ និងសហជីវិនទាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ និងបុគ្គលិកនៅវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ នៃក្រសួងធម្មការទាំងអស់ ។

សូមទ្រង់ទទួលនូវការកិច្ចដ៏ខ្ពង់ខ្ពស់អំពីទូលបង្គំ ។

ហត្ថលេខា : សាន·យុន

# សេចក្តីជូនដំណឹងអំពី

លទ្ធផលនៃការប្រឡងប្រជែងខាងទំនៀមទម្លាប់ខ្មែរ នៅឆមាសទី ១
ឆ្នាំ ១៩៦៦ ស្តីអំពី កុលសម្ពន្ធផ្សេង ៗ និង ល្បែងប្រជាប្រិយខ្មែរ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ មានសេចក្តីរីករាយនិងផ្សាយដំណឹងចំពោះព្រះតេជព្រះគុណ អស់លោកអ្នក ជាសមាជិកឆ្លើយឆ្លងនិងបេក្ខជនទូទៅថា ៖ នៅក្នុងឆមាសទី ១ នៃឆ្នាំ ១៩៦៦ គឺពីខែមករាដល់ដំណាច់ខែមិថុនា ១៩៦៦ នេះ ក្រុមជំនុំយើង បានបើកការប្រឡងប្រជែងខាងទំនៀមទម្លាប់ខ្មែរ ២ មុខគឺ អំពីកុល-សម្ពន្ធផ្សេងៗ និងល្បែងប្រជាប្រិយខ្មែរ ដើម្បីប្រមូលឯកសារផ្នែកនេះយកមកតម្កល់ទុក ជាគោលចារិកនៃប្រពៃណីសម្រាប់ប្រទេសតទៅអនាគត ។

ក្នុងរយៈកាល ៦ ខែរួចមកហើយនេះ ក្រុមជំនុំទំនៀមទម្លាប់បានទទួលអត្ថបទជាច្រើនច្បាប់ ស្តីអំពីកុលសម្ពន្ធផ្សេងៗ និង ល្បែងប្រជា-ប្រិយខ្មែរ ជាបន្តបន្ទាប់គ្នា អំពីសមាជិកឆ្លើយឆ្លងរបស់ក្រុមជំនុំ និងអំពីបេក្ខជនក្រៅពីសមាជិក ទាំងបព្វជិតទាំងគ្រហស្ថ ។ ក្រោយដែលក្រុមជំនុំបានប្រជុំគ្នាពិនិត្យវិញ្ញាសាទាំងអស់នោះ ដោយហ្មត់ចត់ទៅ បានសម្រេចដូចតទៅនេះ :

## ក ផ្នែកកុលសម្ពន្ធផ្សេងៗ

- បានជាប់លេខ ១ : លោក យង់ - សេង អភិបាលស្រុកស្នួល ខេត្តក្រចេះ ត្រូវបានរង្វាន់ ១.០០០ ៛ ០០ ។

– បានជាប់លេខ ២ : លោក ហ៊ុន-សារី ព្រឹទ្ធបាលឯក នៅកងវរសេនាតូចដឹកនាំ គោធិចិនតុង ត្រូវបានរង្វាន់ ៨០០៛០០ ។

– បានជាប់លេខ ៣ : លោក សុះ-នៅ នៅឃុំកំពង់ហ្លួង ស្រុកពញាឮ ខេត្តកណ្ដាល ត្រូវបានរង្វាន់ ៦០០៛០០ ។

– បានជាប់លេខ ៤ : លោក ជូ-ធន គ្រូបង្រៀន នៅវិទ្យាល័យព្រះមហាក្សត្រិយានីកុសុមៈ ក្រចេះ (ក្រុង) ត្រូវបានរង្វាន់ ៤០០៛០០ ។

## ត្រូវបានរង្វាន់លួងចិត្ត ៣ រូបទៀតគឺ

១– លោក កែវ-កុល នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវ

២ – លោក វៀម-យឹម នៅឃុំដីសាង ស្រុកគេនមណ្ឌល ខេត្តបាត់ដំបង

៣– លោក សាន-ឌុយ ហៅ កែវ-សានឌី នៅផ្ទះលេខ ៦១ ក្រុងសៀមរាប អង្គរ ។

## ១ –ផ្នែកល្ខោនប្រជាប្រិយខ្មែរ

ដោយឯកសារផ្នែកល្ខោនប្រជាប្រិយ ដែលក្រុមជំនុំបានទទួលនោះ មិនមានឯកសារណាមួយ មានសេចក្ដីអធិប្បាយពិស្ដារល្អ, ហើយខ្វះន័យមានតម្លៃជាច្រើននោះ ក្រុមជំនុំក៏បានសម្រេចជូនតែត្រឹមរង្វាន់លើកទឹកចិត្តដល់ :

១– លោក ក៏ណា-គូ, ២– លោក កែវ-កុល អ្នកទាំងពីរនាក់នេះ មានទីលំនៅ ៗ ឃុំអង្គតាសោម ស្រុកត្រាំកក់ ខេត្តតាកែវទាំងអស់គ្នា ។

ឯអត្ថបទក្រៅអំពីឯកសារដែលបានជាប់លេខ និង ឯកសារ ដែលបានរង្វាន់លួងចិត្តខាងលើនេះខ្លះទៀត នឹងត្រូវបានជារង្វាន់សមាជិក ដោយយោលទៅតាមតម្លៃការណ៍ និងប្រពៃណ៍សេចក្ដីដែលឲ្យមកនោះ ។

ក្នុងឆមាសជាមួយគ្នានេះ ក្រៅអំពីការប្រឡងប្រជែង ក្រុមជំនុំបាន ទទួលឯកសារស្ដីអំពីទំនៀមផ្សេង ៗ ជាច្រើនទៀត អំពីសមាជិកផ្ញើជូន ខ្លះ អំពីអស់លោកដែលមិនមែនជាសមាជិកខ្លះ ហើយមានឧត្តមគតិល្អ យល់ច្បាស់នូវប្រយោជន៍ជាតិពិតប្រាកដ បានសរសេរឲ្យការណ៍ទៅ ក្រុមជំនុំយើង ។

ចំណែករង្វាន់ដែលត្រូវបានដល់បេក្ខជនប្រឡងជាប់ក្ដី បេក្ខជន ដែលបានរង្វាន់លើកទឹកចិត្តក្ដី និង ដល់សមាជិកក្ដី ក្រុមជំនុំនឹងចាត់ ប្រគេន-ជូន ក្នុងពេលឆាប់ ៗ ខាងមុខនេះ ។

ម្យ៉ាងទៀត នៅក្នុងឆមាសទី ២ ឆ្នាំ ១៩៦៦ នេះ ក្រុមជំនុំទំនៀម ទម្លាប់ខ្មែរ បានបើកការប្រឡងប្រជែង ២ មុខទៀតគឺ : អំពីអ្នកតាផ្សេង ៗ និងរបៀបធ្វើរទេះគោក្របី ។ ប្រកាសប្រឡងស្ដីអំពីរឿងទាំងពីរមុខនេះ ក្រុមជំនុំបានផ្សព្វផ្សាយទៅគ្រប់សាលាខេត្ត និង សាលាក្រុងទាំងអស់ ក្នុង ព្រះរាជអាណាចក្រហើយ ។ សូមអស់លោក-អ្នកស្ម័គ្រចិត្តប្រឡងទាំង ឡាយ អញ្ជើញទៅរកមើលប្រកាសប្រឡងថ្មីនេះ នៅតាមសាលាខេត្ត និងសាលាក្រុងរៀង ៗ ខ្លួនចុះ ។

ចំណែកព្រះតេជព្រះគុណ អស់លោក-អ្នកដែលជាសមាជិកថ្មីយ ថ្មូង និង អស់លោកអ្នកដែលគ្រាន់តែធ្លាប់បានសរសេរប្រឡងរួចមកហើយនោះ ក្រុមជំនុំបានផ្ញើប្រកាសប្រឡងនេះ ទៅតាមរយៈសាលាស្រុកនៃសាមីជន ។ សូមព្រះតេជព្រះគុណ អស់លោក-អ្នក និមន្តអញ្ជើញទៅទទួលយកពីសាលាស្រុករៀងៗខ្លួន ឲ្យបានរួសរាន់កុំបីខាន ដើម្បីឲ្យបានពេលច្រើនទីងរិះរកសរសេរតែងតទៅ ។

មួយវិញទៀត, យើងបានចុះផ្សាយប្រកាសប្រឡងប្រជែង សម្រាប់ឆមាសទី២ ឆ្នាំ ១៩៦៦ នៅទំព័រខាងមុខនេះថែមទៀត ដើម្បីឲ្យព្រះតេជព្រះគុណ និងអស់លោក-អ្នកបានជ្រាបពត៌មានសព្វគ្រប់ ។

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះតេជព្រះគុណ អស់លោក-អ្នក ដែលបានយកព្រះទ័យ យកចិត្តទុកដាក់ ជួយរក្សាកេរ្តិ៍ដំណែលដ៏ថ្លៃថ្លារបស់ជាតិ ។

# ប្រកាសប្រឡងប្រជែងទំនៀមទម្លាប់ខ្មែរ

## ក្នុងឆមាសទី ២ ឆ្នាំ ១៩៦៦

នៅឆមាសទី ២ គឺតាំងពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ ១៩៦៦ ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ ត្រូវការជ្រើសយកឯកសារទំនៀមទម្លាប់ខ្មែរ ដោយបើកការប្រឡងប្រជែង ២ មុខគឺ:

### ១ - អ្នកតាផ្សេង ៗ ក្នុងប្រទេសកម្ពុជា

### ២ - អំពីរបៀបធ្វើរទេះគោឬរទេះក្របី

ដូច្នេះ អស់លោកអ្នកចេះដឹងទាំងឡាយ ជាស្ត្រី ជាបុរស ឬបព្វជិត ដែលស្ម័គ្រចិត្តប្រឡង សូមសរសេរតែងអត្ថបទ តាមគោលបញ្ហាដូចរៀបរាប់ខាងមុខ ឲ្យការណ៍ទៅក្រុមជំនុំទំនៀមទម្លាប់ខ្មែរ យ៉ាងយូរបំផុតត្រឹមថ្ងៃដាច់ខែវិច្ឆិកា ឆ្នាំ ១៩៦៦ គឺមុនដាច់ខែឆមាស ១ ខែ ។

ការប្រឡងប្រជែងនេះមានរង្វាន់ ៤ ថ្នាក់ :

| | |
|---|---|
| ថ្នាក់លេខ ១ ... ១០០០ ៛ ០០ | ថ្នាក់លេខ ៣ ... ៦០០ ៛ ០០ |
| ថ្នាក់លេខ ២ ... ៨០០ ៛ ០០ | ថ្នាក់លេខ ៤ ... ៤០០ ៛ ០០ |

បើអស់លោកណាត្រូវការសរសេរអត្ថបទ ដូចខាងលើនេះ ទៅដាក់ប្រឡង សូមសរសេរលើសៀវភៅ កុំសរសេរលើក្រដាស តែ ១ សន្លឹក ២ សន្លឹកឡើយ ហើយសូមសរសេរនាមនិងទីលំនៅរបស់ខ្លួនឲ្យច្បាស់លាស់លើក្រដាស ១ សន្លឹក ដាក់ក្នុងស្រោមសំបុត្រដោយឡែក

ជាមួយទីងអត្តបទនោះ យកទៅឲ្យក្រុមជំនុំផ្ទាល់ខ្លួនក៏បាន ផ្ញើទៅតាមប្រៃសណីយ៍ក៏បាន ដោយការខ្ទង់សំបុត្រថា : ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ (ផ្នែកទំនៀមទម្លាប់ខ្មែរ)

## គោលបញ្ហានៃការប្រឡង

## ១- អ្នកតាផ្សេង ៗ ក្នុងប្រទេសកម្ពុជា

អ្នកតា មាននៅស្ទើរគ្រប់តំបន់ក្នុងប្រទេសកម្ពុជា ប៉ុន្តែអ្នកតាទាំងនោះ មិនមានឥទ្ធិពលលើអ្នកស្រុក អ្នកភូមិដូចគ្នាទេ ។ អ្នកតាខ្លះមានតែរូប ដែលគេយកដុំថ្មមកសន្មត អ្នកតាខ្លះមានរូបធ្វើដោយឈើ ឬស៊ីម៉ង់ត៍ អ្នកតាខ្លះទៀត មានរូបរបៀបជាបុគ្គលវត្ថុ ដែលគួរឲ្យគោរពបូជា ។ អ្នកតាខ្លះទៀត មានឥទ្ធិពលរហូតដល់កជាការខេត្តទទួលស្គាល់ជាផ្លូវការផង ដូចអ្នកតាឃ្លាំងមឿង នៅខេត្តពោធិ៍សាត់ និងអ្នកតាដទៃទៀត ដែលគេតែងស្គាល់ឈ្មោះច្រើនដែរនោះ ដូចជា : អ្នកតាក្រហមក អ្នកតាគណេស អ្នកតាដំបងដែក អ្នកតាព្រះចៅ អ្នកតាមេសរ យាយទេព អ្នកតាកំហែង . . . ។ ល ។

សូមអស់លោកអ្នក អធិប្បាយអំពីអ្នកតា ដែលមាននៅក្នុងស្រុកភូមិរបស់អស់លោកអ្នក ។ សូមអធិប្បាយ អំពីទីកន្លែងអ្នកតាឲ្យច្បាស់លាស់ថា អ្នកតានោះឈ្មោះអ្វី មានខ្ទម ឬ សាលានៅកន្លែងណា? មានរូបសំណាកបែបណាខ្លះ ?

ឡើងអ្នកតា.–អ្នកតានោះ មានឥទ្ធិពលដូចម្តេចខ្លះ លើអ្នកស្រុក អ្នកភូមិ ? គេបន់អ្វីខ្លះ ? មានពិធីដែលត្រូវធ្វើប្រចាំឆ្នាំចំពោះអ្នកតានោះ ឬទេ ? បើមាន, តើគេធ្វើនៅថ្ងៃណា ខែណា ? មានរបៀបយ៉ាងម្តេចខ្លះ ? មានភ្លេងភ្ជាត់ឬទេ ? សំណែនមានអ្វីខ្លះ ? មានរូបចូលឬទេ ? ស្រីឬប្រុស? អាយុប្រហែលប៉ុន្មាន? សូមអធិប្បាយ អំពីពិធីឡើងអ្នកតានោះឲ្យបានសព្វគ្រប់; បើក្នុងពិធីនោះ មានបូជាសត្វរស់ សូមប្រាប់ផង; ពិធីនោះគេធ្វើរាល់ឆ្នាំនៅឡើយ ឬឈប់ធ្វើអស់ទៅហើយ ? គេធ្វើនៅកន្លែងណា? ក្នុងវត្ត ឬ នៅមុខរូបអ្នកតា ឬ នៅផ្ទះរូបសំណឹង?

អំពីប្រវត្តិអ្នកតា.– អ្នកតាដែលអស់លោកអធិប្បាយនោះ កើតឡើងពីឆ្នាំណា? ដោយហេតុអ្វី? មានរឿងរ៉ាវអំពីដើមកំណើតអ្នកតានោះដូចម្តេចខ្លះ ? បើមានចម្រៀងអ្វីពិសេសសំរាប់អ្នកតានោះ ក៏សូមប្រាប់មកផង !

រឿងអ្នកតានេះ បើលោកអ្នកចង់សរសេរតែមួយក៏បាន ចង់សរសេរអំពីអ្នកតាពីរបីក៏បាន តែសូមអធិប្បាយឲ្យបានពិស្តារ ។

## ២_ ការធ្វើរទេះគោឬរទេះក្របី

រទេះគោ ឬ រទេះក្របី ជាយានជំនិះយ៉ាងសំខាន់របស់ខ្មែរបុរាណ ។ ដោយហេតុថា ស្រុកខ្មែរយើងកាន់តែចំរើន, រទេះគោឬរទេះក្របីបុរាណនេះ ក៏នឹងត្រូវបានជាឧបករណ៍បែបថ្មីមកជំនួសវិញមិនខាន ។ អំណោះ

គេទៅ កូនចៅយើងនឹងមិនស្គាល់រូបរទេះរបស់ខ្មែរបុរាណឡើយ ។ ដូចនេះ ទើបក្រុមចំនៀមទម្លាប់ចង់ប្រមូលការណ៍ អំពីរបៀបធ្វើរទេះ មកទុកជាឯកសារ សម្រាប់អ្នកត្រូវការចង់ដឹងនាអនាគត ។

អស់លោកអ្នកសរសេរតែង ដែលបានចេះដឹងការអ្វី ៗ ទាក់ទងនឹងរឿងរទេះ អាចសរសេរទៅក្រុមជំនុំបានទាំងអស់ ជាពិសេស គឺការណ៍ដែលក្រុមចំនៀមទម្លាប់ជូនជាលំនាំ ដូចតទៅ ៖

១– រទេះគោបុរាណ.– របស់ខ្មែរមានប៉ុន្មានយ៉ាង ? មានឈ្មោះអ្វីខ្លះ? រទេះគោនិងរទេះក្របីខុសគ្នាយ៉ាងម្ដេច? សូមអធិប្បាយអំពីប្រភេទរទេះនីមួយ ៗ ដោយជាក់លាក់ ហើយបើអស់លោកអ្នកអាចគូរ ឬរកគេឲ្យគូររូបរទេះមួយបែប ៗ បាននោះ ជាការប្រពៃណាស់ ព្រោះគំនូរជាជំនួយមួយយ៉ាងធំ ដល់សេចក្ដីអធិប្បាយរបស់លោកអ្នក ។

២– របៀបធ្វើរទេះ.– សូមលោកអ្នកអធិប្បាយតាំងពីការរកឈើ ទំហំឈើដែលត្រូវយកមកធ្វើផ្នែកនីមួយ ៗ ខ្នាតដែលត្រូវវែយក ឲ្យរទេះនោះមានកង់ពៅសមរម្យ ៗ ល ៗ គេមានវិធីយ៉ាងណា ដើម្បីឲ្យរទេះបានស្រាល ហើយលឿនល្អឬទេ ? អំពីការរចនាជារូបសត្វផ្សេង ៗ នៅចន្ទោលរទេះ ឬការលាបពណ៌ ដាក់ចង្កំ ចង្ក្រង់រយោល... ៗល ៗ បើលោកអ្នកជ្រាបថា ការធ្វើរទេះ មានបែបគ្នាតាមស្រុកយ៉ាងណា ៗ ក៏សូមប្រាប់ផង ។

ពិធីទាក់ទងនឹងរនេះ.– តើគេមានធ្វើពិធីសម្ពោធរនេះថ្មីទេ? បើមានសូមអធិប្បាយ ។ សំណែនមុននឹងចេញធ្វើដំណើរ ការបូជាចំពោះជំនាងរនេះ គ្រឿងណាមផ្សេង ៗ ។ គេត្រូវការប្រើរនេះ ដឹកមនុស្ស ដឹកទំនិញ បរប្រណាំង ដឹកអ្នកជម្ងឺ ដឹកខ្មោច . . . ។ល។ តើក្នុងរបៀបប្រើទាំងនោះ គេត្រូវមានពិធីកំចាត់ចង្រៃ បង្ក័ក់ប្រសិទ្ធិ សែនព្រេនអ្វីដែរ ឬមានរនេះប្រើដោយឡែកពីគ្នា ? ។ ប្រសិនជាមានមនុស្សឆ្លងទន្លេក្នុងរនេះ គេមានរៀបពិធីអ្វីទេ ? ។

អំពីរឿងព្រេង - ចម្រៀង - ពាក្យទំនៀមផ្សេង ៗ ទាក់ទងនឹងរនេះ.- បើមានចម្រៀង, រឿងព្រេង ឬពាក្យទំនៀមទាក់ទងនឹងរនេះ ក៏សូមអធិប្បាយមកផង ។ បើកាលណាលោកអ្នកសរសេរតែង សូមកុំភ្លេចប្រាប់ថា លោកអ្នកបានចេះដឹងរឿងទាំងនោះពីអ្នកណា ឬលោកអ្នកធ្លាប់បានធ្វើដោយខ្លួនឯង ។ ឯចំណែកការធ្វើរនេះ ក៏សូមបញ្ជាក់ថា តើលោកអ្នកចេះធ្វើដោយខ្លួនឯង ឬមានអ្នកណាប្រាប់ ។ អ្នកប្រាប់នោះនៅស្រុកណា ? អាយុប៉ុន្មាន? ។ គេនៅធ្វើរបររនេះ ឬឈប់ធ្វើហើយ? ប៉ុន្មានឆ្នាំហើយ? ។

សេចក្ដីបញ្ជាក់ ; អត្ថបទដែលបេក្ខជនសរសេរទៅដាក់ប្រឡង ទោះបីជាប់ក្ដី មិនជាប់ក្ដី ត្រូវទុកជាសម្បត្តិរបស់ក្រសួងតទៅ មិនបង្វិលឲ្យសាមីខ្លួនវិញទេ ។

ក្រុមទំនៀមទម្លាប់ខ្មែរ

# ប្រជុំការងារនៅថ្ងៃទី ២១ - ៣ - ៦៦

ក្រោមអធិបតីភាពនៃសហជីវិន លាង-ហ៊ាបអាន

នាយកពុទ្ធសាសនបណ្ឌិត្យ

អង្គប្រជុំបានសម្រេចសេចក្ដីនៃបញ្ហាផ្សេង ៗ ដូចខាងក្រោម :

១– អនុញ្ញាតឲ្យមហាវិទ្យាល័យអក្សរសាស្ត្រ យកអត្ថបទដើមទាំងស្រុង នៃរឿងកម្រតេង្គ ដែលមានក្នុងសាស្ត្រាស្លឹករឹត របស់ពុទ្ធសាសនបណ្ឌិត្យ ខ្សែ ១ ដល់ ១០ និង ៧៩ ដល់ ៨០ ជូនទៅលោកគេងវ៉ាន់សាក់ ជួយពិនិត្យសម្រួល ដើម្បីបោះពុម្ពផ្សាយ ព្រមទាំងអនុញ្ញាតឲ្យបញ្ចូលនាមលោកអ្នកជួយពិនិត្យ នៅទំព័រដើមនៃសៀវភៅទីមួយ ។ (តាមលិខិតរបស់មហាវិទ្យាល័យអក្សរសាស្ត្រលេខ ៧៩ ម.អ. ចុះថ្ងៃទី ១៦-៣-៦៦) ។ តែការបោះពុម្ពនិងសិទ្ធិគ្រប់យ៉ាង ត្រូវនៅក្នុងបន្ទុកនៃពុទ្ធសាសនបណ្ឌិត្យដដែល ។ ចំណែកមហាវិទ្យាល័យអក្សរសាស្ត្រ បើត្រូវការសៀវភៅនេះមានចំនួនច្រើនប៉ុន្មានចប់ក្ដី, ពុទ្ធសាសនបណ្ឌិត្យនឹងជាវជូន ដោយគិតតែត្រឹមតម្លៃដើម ឥតគិតចំណេញឡើយ ។

២– ថ្វាយសៀវភៅព្រះត្រៃបិដក ស្រោបក្របជ័រទឹខ្យង មួយចប់ចំពោះសម្ដេចព្រះមហាក្សត្រត្រិយានីជាអម្ចាស់ជីវិតលើត្បូង និងមួយចប់ទៀត ចំពោះសម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ ។

៣– ជូនជាអំណោយ នូវសៀវភៅផ្សេង ៗ របស់វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ចំពោះសមាគមនិស្សិតខ្មែរទៅ នៃប្រទេសកម្ពុជា, សមាគមបុគ្គលិកសិក្សា, សមាគមអ្នកនិពន្ធខ្មែរ និង អធិការដ្ឋានបច្ចេកទេសខាងមធ្យមសិក្សា នៃក្រសួងអប់រំជាតិ ដើម្បីផ្សាយនិងពង្រីកនូវសកម្មភាព ឆ្នាំ ១៩៦៦ នៃវិជ្ជាឋាននេះ ។